ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២៤ លេខ ៤ | ខែធ្នូ ឆ្នាំ២០២០ | តម្លៃ ១.៥០០៛

30th ANNIVERSARY
CDRI 1990 - 2020

# ការរាំងស្ទះ និងកាលានុវត្តភាពក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩ ក្នុងឧត្តមសិក្សានៅកម្ពុជា៖ ទស្សនៈរបស់បុគ្គលិកបង្រៀន[១]

## សេចក្ដីផ្ដើម

បញ្ហាប្រឈមមិនធ្លាប់ជួប បង្កឡើងដោយជំងឺឆ្លងរាលដាលកូវីដ១៩ បាននាំឲ្យមានការរាំងស្ទះធំធេង និងយ៉ាងគំហុកលើគ្រប់វិស័យក្នុងពិភពលោក ហើយវិស័យអប់រំក៏ស្ថិតក្នុងចំណោមវិស័យដែលទទួលរងការប៉ះពាល់ខ្លាំងជាងគេ។ ការបិទសាលារៀន និងសាកលវិទ្យាល័យក្នុង ១៧៥ប្រទេស នៅដើមខែមេសា ឆ្នាំ ២០២០ ក្នុងគោលដៅទប់ស្កាត់ការឆ្លងវីរុស បានប៉ះពាល់ដល់ការសិក្សារបស់និស្សិតថ្នាក់ក្រោយមធ្យមសិក្សា ចំនួន ២២០លាននាក់ (World Bank 2020)។ ការបិទសាលារៀននេះបានធ្វើឲ្យវិសមភាពអប់រំកាន់តែធ្ងន់ធ្ងរឡើង និងរុញច្រានឲ្យនិស្សិតដែលមានស្ថានភាពសេដ្ឋកិច្ចទន់ខ្សោយ ឲ្យប្រឈមនឹងភាពយឺតយ៉ាវក្នុងការសិក្សាថែមទៀត។ ប្រទេសជាច្រើនបានបង្ខំចិត្តអនុវត្តការបង្រៀន និងរៀនពីចម្ងាយ។ ទោះបីមាននិស្សិតពី ៨០% ទៅ ៨៥% នៅក្នុងប្រទេសអភិវឌ្ឍន៍ទទួលបានការអប់រំ តាមរយៈការរៀនសូត្រពីចម្ងាយក៏ពិតមែន ប៉ុន្តែនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺមាននិស្សិតតិចជាង ៥០% ដែលអាចទទួលបានការអប់រំពីចម្ងាយ (UNESCO, UNICEF and World Bank 2020)។

ដោយបានយល់ដឹងពីកំណើនគម្លាតការសិក្សា រវាងនិស្សិតមានស្ថានភាពសេដ្ឋកិច្ចខ្ពស់ នឹងនិស្សិតមានស្ថានភាពសេដ្ឋកិច្ចទាប វិធានការជាច្រើនត្រូវបានអនុវត្តក្នុងគោលដៅកាត់បន្ថយការឆ្លងវីរុស និងបញ្ឈប់ការបាត់បង់ការរៀនសូត្រ ដោយសារផលប៉ះពាល់នៃកូវីដ១៩។ វិធានការណ៍ឆ្លើយតបដែលមានភាពលេចធ្លោ និងខ្លាំងក្លាជាងគេ គឺការផ្លាស់ប្ដូរភ្លាមៗពីការរៀនក្នុងថ្នាក់ ទៅកាន់ការអប់រំពីចម្ងាយ។ បែបបទបង្រៀននិងរៀនពីចម្ងាយដែលបានអនុវត្តច្រើន រួមមាន ការប្រើក្រដាសសម្រាប់ធ្វើលំហាត់ ការផ្សាយតាមវិទ្យុ និងទូរទស្សន៍ និងវេទិការៀនពីចម្ងាយផ្សេងៗ រួមមាន ការបង្រៀនតាមអនឡាញ និងការសិក្សាដោយខ្លួនឯង (Azevedo et al. 2020; Huang et al. 2020)។ គ្រឹះស្ថានឧត្តមសិក្សាភាគច្រើន បានដាក់អនុវត្ត បច្ចេកវិទ្យាអប់រំ (edtech) ដែលមានជាអាទិ៍ វីដេអូថតទុក និងវគ្គបង្រៀនបន្តផ្ទាល់តាមរយៈសន្និសីទវីដេអូនៅតាមវេទិកាសម្រាប់ការរៀនតាមអ៊ីនធើណិតផ្សេងៗ ដើម្បីកាត់បន្ថយភាពរឹករវរក្នុងវិស័យអប់រំ។

ដោយសារ ស្ថានការណ៍ដូចខាងលើ ការសិក្សានេះមានគោលដៅពីរ រួមមាន ការកំណត់បញ្ហាប្រឈម និងកាលានុវត្តភាពផុសចេញពី ការឆ្លើយតបភ្លាមៗទៅនឹង ការបិទសាលារៀន និងសាកលវិទ្យាល័យ និងការវាយតម្លៃភាពត្រៀមលក្ខណៈផ្នែកបច្ចេកវិទ្យាអប់រំ នៃបុគ្គលិកបង្រៀននៅកម្រិតឧត្តមសិក្សា។ ការសិក្សានេះ ជាផ្នែកមួយនៃការសិក្សាស្ដីពី ការអនុវត្តការសិក្សាពីចម្ងាយ និងការប្រើប្រាស់បច្ចេកវិទ្យាអប់រំ នៅតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ដើម្បីឆ្លើយតបនឹងជំងឺឆ្លងរាលដាលកូវីដ១៩។ អត្ថបទនេះចែកចេញជាប្រាំផ្នែក។ ផ្នែកពីរបន្ទាប់នេះនិយាយពីការរាំងស្ទះ និងកាលានុវត្តភាពក្នុងពិភពលោក ក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩ និងការឆ្លើយតបរបស់គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា។ ផ្នែកទី៤ និងទី៥ បង្ហាញពី វិធីសាស្ត្រនៃការសិក្សា និងលទ្ធផលរកឃើញ។ ផ្នែកចុងក្រោយជាការសន្និដ្ឋាន ដោយមានការផ្ដល់មតិផ្នែកគោលនយោបាយ ដើម្បីឲ្យកម្ពុជាអាចត្រៀមខ្លួនបានកាន់តែប្រសើរ នៅពេលមានវិបត្តិផ្សេងៗនាអនាគត។

១ ការសិក្សានេះជាចំណែកមួយនៃ កម្មវិធីសហការជាដៃគូរយៈពេលបីឆ្នាំរវាង CDRI នឹងអង្គការមូលនិធិអាស៊ី ហៅថា "ថ្នាលឧត្ដមចំណេះ - ការលើកកម្ពស់នវានុវត្តន៍ក្នុងឧត្តមសិក្សានៅកម្ពុជា"។ ក្រុមអ្នកនិពន្ធ សូមថ្លែងអំណរគុណដល់ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី ដែលបានផ្ដល់មូលនិធិដល់គម្រោងនេះ។

អត្ថបទនេះរៀបរៀងដោយបណ្ឌិត ជា ផល អ្នកស្រាវជ្រាវ ហ៊ុន សីហគន្ធីជំនួយការស្រាវជ្រាវ និង ជៀម ស៊ីវគីម ជាអ្នកហាត់ការ នៃមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍អប់រំ នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Dr Chea Phal, Hun Seyhakunthy, and Cheam Sivkim. 2020. “Disruption and Opportunities during the Covid-19 Pandemic in Cambodian Higher Education: Perspective from Teaching Staff.” *Cambodia Development Review* 24 (4): 1–7.

## មាតិកា

ការរាំងស្ទះ និងកាលានុវត្តភាពក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩ ក្នុងឧត្តមសិក្សានៅកម្ពុជា៖ ទស្សនៈរបស់បុគ្គលិកបង្រៀន ........ ១
ការទូតក្នុងការគ្រប់គ្រងទឹកនៅអាងទន្លេមេគង្គ ........ ៨
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ........ ១៥
– ស្ថានភាពក្នុងប្រទេស ........ ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៨

## ការរាំងស្ទះក្នុងវិស័យអប់រំ និងការលាទុវត្តភាពពេលមានជំងឺកូវីដ១៩

ដោយសារ កង្វះហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស និងធនធានមនុស្ស ក្នុងការបង្កើតសម្ភារ និងវេទិកាសិក្សាពីចម្ងាយ គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនបានពន្យាការបង្រៀន និងរៀនដោយពុំមានការកំណត់ថ្ងៃច្បាស់ សម្រាប់ឲ្យនិស្សិតត្រឡប់មករៀននៅតាមថ្នាក់រៀនវិញ។ Marinoni, Land and Jensen (2020) បានរំលឹកថា ការសម្របខ្លួនទៅតាមការបិទសាលារៀន និងការផ្លាស់ប្ដូរភ្លាមៗ ទៅអនុវត្តការរៀនពីចម្ងាយ វាអាស្រ័យលើភាពត្រៀមលក្ខណៈផ្នែកបច្ចេកវិទ្យារបស់និស្សិត និងសមត្ថភាពរបស់សាស្ត្រាចារ្យក្នុងការប្រើបច្ចេកវិទ្យាអប់រំ ដើម្បីផ្ដល់ និងគ្រប់គ្រងសកម្មភាពរៀនសូត្រតាមអ៊ីនធើណិត។ Lapada et al. (2020) បានសង្កត់ធ្ងន់លើ បញ្ហាប្រឈមផ្សេងៗដែលផុសចេញពី ការបង្ខំឲ្យក្រុមសាស្ត្រាចារ្យ ចាប់អនុវត្តបច្ចេកវិទ្យាអប់រំភ្លាមៗ និងពីសម្ពាធដ៏ធំធេង បណ្ដាលមកពីការសម្រុកទៅរកការរៀនពីចម្ងាយ។ បញ្ហាប្រឈមធំជាងគេ គឺចំណេះដឹង និងជំនាញដែលអ្នកអប់រំត្រូវមាន សម្រាប់ដឹកនាំការរៀនសូត្រពីចម្ងាយ ការវាយតម្លៃលទ្ធផលសិក្សារបស់និស្សិត និងជាពិសេស ការរក្សាឲ្យមានការចូលរួមយ៉ាងសកម្មពីនិស្សិត និងអន្តរកម្មរវាងគ្រូ នឹងនិស្សិតពីចម្ងាយ។

ក្នុងការបង្រៀនពីចម្ងាយ បញ្ហានៃការឲ្យនិស្សិតចូលរួមសកម្ម និងលើកទឹកចិត្តឲ្យមានអន្តរកម្ម រវាងគ្រូនឹងនិស្សិតប្រកបដោយប្រសិទ្ធភាព ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ដោយ Neuwirth, Jović and Mukherji (2020) ដែលបានសង្កេតឃើញថា មានការបែកអារម្មណ៍ និងការមិនយកចិត្តទុកដាក់ របស់និស្សិតក្នុងពេលរៀនពីចម្ងាយ ក៏ដូចជាកង្វះការចូលរួមសកម្ម និងការបិទកាម៉េរាវីដេអូក្នុងពេលរៀន ជាដើម។ ដោយសារអាកប្បកិរិយាបែបនេះ សាស្ត្រាចារ្យមិនអាចវាយតម្លៃការយល់ដឹងរបស់និស្សិតលើមេរៀន ឬទប់ស្កាត់ការបាត់បង់ការរៀនសូត្របានទេ។ ឧបសគ្គរាំងក្នុងវិស័យអប់រំទាំងនេះ បានក្លាយជាសញ្ញាសំគាល់សំខាន់មួយនៃ "គន្លងថ្មី" (De Giusti 2020) នៅពេលដែលគេរំពឹងថា បច្ចេកវិទ្យាអប់រំ ដើរតួនាទីកាន់តែសំខាន់ ទោះបីនៅពេលជំងឺឆ្លងរាលដាលលែងជាវិបត្តិទៀតក្ដី។ ប៉ុន្តែ ការរៀនពីចម្ងាយមិនអាចជំនួសការរៀនផ្ទាល់តាមថ្នាក់រៀនបានទាំងស្រុងទេ។ បច្ចុប្បន្នពុំទាន់មានភស្តុតាងបង្ហាញថា ការរៀនពីចម្ងាយ អាចបង្កើនចំណេះដឹងបានល្អប្រសើរជាងការរៀនតាមថ្នាក់នោះទេ (Azevedo et al. 2020)។

ដោយឡែក ឥរិយាបថគ្រូ ចំពោះការប្រើបច្ចេកវិទ្យាក្នុងការអប់រំ មិនមែនជាបញ្ហាថ្មីទេ។ ការសិក្សាសកល បានបង្ហាញពី ឥរិយាបថ និងបទពិសោធន៍វិជ្ជមានក្នុងចំណោមបុគ្គលិកបង្រៀន លើការអនុវត្តបច្ចេកវិទ្យាអប់រំ។ ជាក់ស្ដែង អ្នកអប់រំបានទាញយកប្រយោជន៍ពីឱកាសដ៏វិសេសនេះ ដើម្បីធ្វើការស្រាវជ្រាវពីវិធីសាស្ត្របង្រៀនផ្សេងៗ ដូចជាការរៀនសូត្រដែលមានភាពបត់បែន បែបចម្រុះ ឬកូនកាត់ ជាដើម និងបានរៀន និងសាកល្បងជំនាញផ្នែកបច្ចេកវិទ្យា និងវេទិការៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិក (ប្រព័ន្ធគ្រប់គ្រងការរៀនសូត្រ) និងសម្ភារៈ និងឧបករណ៍បច្ចេកទេសផ្សេងៗ (Donitsa-Schmidt and Ramot 2020)។

លទ្ធផលនៃការស្ទង់មតិជាសកលស្ដីពីផលប៉ះពាល់នៃជំងឺកូវីដ ១៩ នៅថ្នាក់ឧត្តមសិក្សាបានបង្ហាញថា សាស្ត្រាចារ្យរំពឹងថា ការរៀនសូត្រពីចម្ងាយ នៅតែជាចំណែកមួយយ៉ាងសំខាន់នៃការធ្វើផែនការមេរៀន នាពេលអនាគត និងសង្ឃឹមថានឹងមាននវានុវត្តន៍អប់រំ និងវិធីសាស្ត្រថ្មីៗ ក្នុងការបង្រៀន និងរៀនថែមទៀត (Marinoni, Land and Jensen 2020)។ ពួកសាស្ត្រាចារ្យ ក៏បានសង្កត់ធ្ងន់ផងដែរពី បញ្ហាសំខាន់នៃក្របខ័ណ្ឌសមស្របមួយសម្រាប់វាយតម្លៃការរៀនសូត្រ ដែលអាចប្រើប្រាស់សម្រាប់ជួយគាំទ្រ និងធ្វើតេស្ដលទ្ធផលរៀនសូត្រឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

## ការឆ្លើយតបរបស់ឧត្តមសិក្សាកម្ពុជាទៅនឹងកូវីដ១៩

ករណីទី១នៃអ្នកមានផ្ទុកកូវីដ១៩នៅកម្ពុជា ត្រូវបានរកឃើញនៅថ្ងៃទី២៧ មករា ២០២០ លើបុរសម្នាក់ដែលត្រឡប់មកពីក្រុងវូហាន់ ប្រទេសចិន (WHO 2020a) ហើយករណីទី២ នៅថ្ងៃទី៧ មីនា ២០២០ ជាអ្នករស់នៅសៀមរាប។ នៅថ្ងៃទី១៦ មីនា ២០២០ គឺមួយថ្ងៃបន្ទាប់ពីការរកឃើញ អ្នកផ្ទុកវីរុសកូវីដ១៩ ប្រាំករណីថ្មីទៀត ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្ដីណែនាំឲ្យបិទសាលារៀនទាំងអស់ ក្នុងទូទាំងប្រទេសរហូតដល់មានការជូនដំណឹងជាថ្មី ហើយនេះជាវិធានមួយក្នុងការកាត់បន្ថយការឆ្លងរាលដាលវីរុស (UNESCO 2020a)។

កម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ឯទៀតដែរ ត្រូវប្រឈមមុខនឹងបញ្ហាធំៗជាច្រើនក្នុងវិស័យអប់រំ ក្នុងពេលមានវិបត្តិនេះ។ ជាក់ស្ដែង ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា ត្រូវចាប់អនុវត្តការរៀនសូត្រពីចម្ងាយយ៉ាងលឿន ដោយថ្នាក់រៀនត្រូវបិទទ្វារភ្លាមៗនៅពាក់កណ្ដាលខែមីនា។ បើទោះជាក្រសួងអប់រំ យុវជននិងកីឡា បានចេញសេចក្ដីណែនាំមួយចំនួនសម្រាប់ការអប់រំទូទៅ ដូចជា គំនិតផ្ដួចផ្ដើមផ្សាយការបង្រៀនតាមទូរទស្សន៍ និង វគ្គបង្រៀនតាមបណ្ដាញសង្គម ជាដើម ក៏ការរៀនសូត្រនៅកម្រិតឧត្តមសិក្សា នៅតែស្ថិតក្រោមសេចក្ដីសម្រេចរបស់ គ្រឹះស្ថានឧត្តមសិក្សានីមួយៗ (WHO 2020b)។ គ្រឹះស្ថានឧត្តមសិក្សានានាពុំមានជម្រើសអ្វីផ្សេងក្រៅពីការចាប់យកបច្ចេកវិទ្យានោះទេ ក្នុងការធានាឲ្យការរៀនសូត្រ អាចបន្តទៅមុខបាន ទោះបីជាធនធានមានកម្រិតក្ដី។

សាលារៀននិងសាកលវិទ្យាល័យទាំងអស់ត្រូវបានបិទក្រោយពីក្រសួងអប់រំ យុវជននិងកីឡា បានចេញសេចក្ដីណែនាំ នៅថ្ងៃ ១៦ មីនា ២០២០ ហើយបានងាកទៅរកការបង្រៀនពីចម្ងាយ ប៉ុន្តែការបង្រៀនពីចម្ងាយនេះ មិនបានចាប់ផ្ដើមដំណាលគ្នានោះទេ។ សាកលវិទ្យាល័យឈានមុខ និងសាលារៀនអន្តរជាតិមួយចំនួន មានបំពាក់ឧបករណ៍ និងគ្រឿងបរិក្ខារចាំបាច់ និងមានប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) នៅក្នុងកម្មវិធីសិក្សារបស់ខ្លួនរួចជាស្រេច។ គ្រឹះស្ថានទាំងនេះអាចផ្ដល់ការណែនាំ និងធ្វើការបណ្ដុះបណ្ដាលបុគ្គលិកបង្រៀនរបស់ខ្លួន ស្ដីពីការប្រើបច្ចេកវិទ្យាអប់រំ រួចហើយក៏អាចចាប់អនុវត្តការបង្រៀនពីចម្ងាយបានយ៉ាងលឿន។

សាលារៀន និងសាកលវិទ្យាល័យដែលមានធនធានតិច ជាពិសេស វិទ្យាស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) នៅក្រៅរាជធានីភ្នំពេញ ជួបបញ្ហាប្រឈម

ដោយសារមិនមានឧបករណ៍ និងសេចក្តីណែនាំគ្រប់គ្រាន់ ក្នុងការអនុវត្តការងារទៅមុខ។ ការអនុវត្តការបង្រៀន និងរៀនពីចម្ងាយរបស់គ្រឹះស្ថានទាំងនោះ មានការយឺតយ៉ាវជាងគេ។ អង្កេតមួយធ្វើឡើងដោយ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ (CERI) នៃ CDRI បានរកឃើញថា មានតែគ្រឹះស្ថានឧត្តមសិក្សាចំនួន ៨ប៉ុណ្ណោះ ដែលចាប់ផ្តើមបង្រៀនពីចម្ងាយនៅថ្ងៃទី១២ ឧសភា ២០២០ ដែលជាថ្ងៃ ក្រសួងអប់រំ យុវជននិងកីឡា ចេញសេចក្តីណែនាំមួយទៀតឲ្យសាលារៀននានា ចាប់ដំណើរការថ្នាក់រៀនពីចម្ងាយ រីឯគ្រឹះស្ថានឧត្តមសិក្សាចំនួន៩ទៀត បានចាប់អនុវត្តការរៀនសូត្រពីចម្ងាយ ក្រោយពាក់កណ្តាលខែឧសភា ពោលគឺ ២ខែ ក្រោយពីការបិទសាលា។

## វិធីសាស្ត្រ

ការសិក្សានេះ ប្រើវិធីចម្រុះរបស់ Creswell and Clark (2018) ដោយបានបញ្ចូល ការវិភាគបែបបរិមាណវិស័យផ្អែកលើអង្កេតបុគ្គលិកបង្រៀន ជាមួយនឹងការវិភាគបែបគុណវិស័យលើកំណត់ត្រានៃសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធគន្លឹះ (KII) និងសម្ភាសន៍ជាមួយបុគ្គលិកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។ ការសិក្សានេះជាផ្នែកមួយនៃការសិក្សាធំ ស្តីពី ការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន (ICT) ក្នុងការបង្រៀននិងរៀន និងការចាប់យកបច្ចេកវិទ្យាអប់រំ ក្នុងការឆ្លើយតបនឹងជំងឺឆ្លងរាលដាលកូវីដ១៩ នៅតាមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។ ការវិភាគក្នុងការសិក្សានេះ ប្រើប្រាស់តែចំណែកខ្លះនៃអង្កេតលើបុគ្គលិកបង្រៀន និងព័ត៌មានមួយចំនួន បានមកពីសម្ភាសន៍ KII ប៉ុណ្ណោះ។

ចំពោះអង្កេតលើបុគ្គលិកបង្រៀន ក្រុមអ្នកស្រាវជ្រាវបានប្រើវិធីជ្រើសរើសសំណាកពីរដំណាក់កាល ដើម្បីជ្រើសយកបុគ្គលិកបង្រៀនចំនួន ៣៧០នាក់ ក្នុង ២០គ្រឹះស្ថានឧត្តមសិក្សា។ យោងតាមរបាយការណ៍សន្និបាតអប់រំចុងក្រោយ កម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាចំនួន១២៤ ស្ថិតនៅក្រោមក្រសួង និងស្ថាប័ន ១៦ ខុសៗគ្នា ក្នុងនោះមាន គ្រឹះស្ថានឧត្តមសិក្សាចំនួន ១០១ (៨១,៤៥%) ស្ថិតនៅក្រោម ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoEYS 2020)។ ដើម្បីសម្រួលការងារភស្តុភារកម្ម ការសិក្សានេះ មិនមានបញ្ចូលគ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោម ក្រសួង និងស្ថាប័ន ១៤ ផ្សេងទៀតនោះទេ។ ក្រុមអ្នកស្រាវជ្រាវ បានទទួលបញ្ជីគ្រឹះស្ថានឧត្តមសិក្សា និងស្ថិតិនិស្សិត ពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែមិនបានទទួលបញ្ជីឈ្មោះគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនោះទេ។

ក្នុងពេលជ្រើសសំណាកដំណាក់កាលទី១ គ្រឹះស្ថានឧត្តមសិក្សាដែលមាននិស្សិតចុះឈ្មោះចូលរៀនតិចជាង ៥០០នាក់ ត្រូវបានដកចេញ ដូច្នេះគឺនៅមានសល់តែ ៧៥គ្រឹះស្ថានឧត្តមសិក្សាប៉ុណ្ណោះ។ ដើម្បីជ្រើសយក ២០គ្រឹះស្ថានឧត្តមសិក្សា ជាក្រុមសំណាកបឋម ការសិក្សានេះបានប្រើវិធីជ្រើសសំណាកជាប្រព័ន្ធតាមប្រូបាប៊ីលីតេសមាមាត្រទៅនឹងចំនួននិស្សិត។ វិធីនេះបានធានាថា គ្រឹះស្ថានឧត្តមសិក្សា ដែលមាននិស្សិតច្រើន គឺមានប្រូបាប៊ីលីតេខ្ពស់ក្នុងការត្រូវបានជ្រើសរើសជាសំណាក។ សម្រាប់ការជ្រើសសំណាកដំណាក់កាលទី២ក្រុមអ្នកស្រាវជ្រាវបានជ្រើសយកសំណាកដោយចៃដន្យ ចេញពីបញ្ជីបុគ្គលិកបង្រៀនទាំងអស់ដែលទទួលបានពីគ្រឹះស្ថានឧត្តមសិក្សា។ ការចុះប្រមូលទិន្នន័យត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ ខេត្តស្វាយរៀង កំពត និងបាត់ដំបង។ ទិន្នន័យត្រូវបានប្រមូលយកក្នុងទម្រង់ឌីជីថល ដោយប្រើ KoboToolbox តាមរយៈសម្ភាសន៍ទល់មុខគ្នាផ្ទាល់ ក្នុងចន្លោះពីថ្ងៃទី៣ សីហា ដល់ ៣ វិច្ឆិកា ២០២០។

សម្ភាសន៍ KII ជាមួយ ១៧គ្រឹះស្ថានឧត្តមសិក្សា (ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំង២០ ដែលត្រូវបានជ្រើសយកក្នុងដំណាក់កាលទី១) ត្រូវបានធ្វើឡើង ដោយប្រើកម្រងសំណួរពាក់កណ្តាលព្រាងទុក តាមរយៈសម្ភាសន៍ទល់មុខគ្នា ក្នុងចន្លោះពីថ្ងៃទី២៧ កញ្ញា ដល់ ១១ វិច្ឆិកា ២០២០ ជាមួយបុគ្គលិកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា រួមមាន សាកលវិទ្យាធិការរង ឬនាយករងទទួលបន្ទុក កិច្ចការអប់រំ ប្រធានផ្នែកសិក្សាធិការ ព្រឹទ្ធបុរសនៃមហាវិទ្យាល័យ/ដេប៉ាតឺម៉ង់ ICT និងបុគ្គលិក IT។ ទិន្នន័យបែបគុណវិស័យដែលស្រង់ចេញពីផ្នែកមួយនៃសម្ភាសន៍ KII ស្តីពីផលប៉ះពាល់នៃកូវីដ១៩ និងដំណោះស្រាយរបស់គ្រឹះស្ថានឧត្តមសិក្សា ក្នុងពេលមានជំងឺឆ្លងរាលដាលនេះ ត្រូវបានប្រើសម្រាប់បញ្ជាក់ព័ត៌មានដែលទទួលបានពីអង្កេតលើបុគ្គលិកបង្រៀន។

## លទ្ធផលរកឃើញ

មុននឹងបង្ហាញពីលទ្ធផលរកឃើញសំខាន់ៗ ផ្អែកលើការយល់ឃើញរបស់ បុគ្គលិកបង្រៀនលើការរៀនពីចម្ងាយ ផ្នែកនេះពិពណ៌នាដោយសង្ខេប ពីលក្ខណៈសំគាល់របស់ អ្នកចូលរួមក្នុងអង្កេតលើបុគ្គលិកបង្រៀនដូចមានបង្ហាញក្នុងតារាង១។ បុគ្គលិកបង្រៀនបានវាយតម្លៃថា តើគាត់យល់ទាស់ ឬយល់ស្របកម្រិតណា លើសេចក្តីមួយចំនួនទាក់ទងនឹងបញ្ហាប្រឈម និងកាលានុវត្តភាព ក្នុងការផ្តល់ការអប់រំពីចម្ងាយ ក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩ ដោយប្រើ Likert មាន ៥កម្រិត។ ក្រុមអ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរ ដោយផ្អែកលើបរិបទកម្ពុជា និងសម្ភាសន៍ជាមួយ បុគ្គលិកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន។ អ្នកនិពន្ធប្រើការវិភាគភាពញឹកញាប់ (nonparametric frequency analysis) នៃសំណាកសរុបរួម ដើម្បីញែកចេញនូវការយល់ឃើញរបស់បុគ្គលិកបង្រៀន។ ក្នុងការពិនិត្យប្រៀបធៀបលក្ខណៈខុសគ្នារវាងអនុក្រុម ស្តីពី ការយល់ឃើញរបស់បុគ្គលិកបង្រៀន ពិន្ទុ Likert ត្រូវបានចាត់ទុកជា តម្លៃលេខបន្តដែលមានចន្លោះស្មើគ្នា។ ក្នុងការវិភាគតាមអនុក្រុម បុគ្គលិកបង្រៀនត្រូវបានបែងចែកតាមយេនឌ័រ ប្រភេទស្ថាប័ន កម្មវិធី និងទីតាំងរបស់គ្រឹះស្ថានឧត្តមសិក្សា។

*លក្ខណៈសំគាល់របស់អ្នកចូលរួម*

បុគ្គលិកបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ភាគច្រើនជាបុរស។ ភាគរយជាស្រីនៃ សំណាកសរុប មានចំនួនតិច (៨,៣១%) នៅសាកលវិទ្យាល័យ និង (១៥,៧៩%) នៅវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

តារាង១៖ លក្ខណៈសំគាល់របស់អ្នកឆ្លើយសម្ភាសន៍

| | សាកលវិទ្យាល័យ | វិទ្យាស្ថាន TVET |
|---|---|---|
| **យេនឌ័រ** | | |
| - ស្រី | 8.31% | 15.79% |
| - ប្រុស | 91.69% | 84.21% |
| **អាយុ** | | |
| - < ៣០ឆ្នាំ | 6.71% | 15.79% |
| - ៣១-៤០ឆ្នាំ | 45.05% | 57.89% |
| - ៤១-៥០ឆ្នាំ | 35.78% | 21.05% |
| - > ៥០ឆ្នាំ | 12.46% | 5.26% |
| **គុណវុឌ្ឍិ** | | |
| - សញ្ញាប័ត្រខ្ពស់ជាង | 0.00% | 5.26% |
| - បរិញ្ញាប័ត្រ | 2.56% | 31.58% |
| - សញ្ញាប័ត្រជាន់ខ្ពស់ | 72.52% | 63.16% |
| - បណ្ឌិតមិនចប់ថ្នាក់* | 12.14% | 0.00% |
| - បណ្ឌិត | 12.78% | 0.00% |
| **បទពិសោធន៍បង្រៀន** | | |
| - < ៥ឆ្នាំ | 21.73% | 26.32% |
| - ៦-១០ឆ្នាំ | 26.52% | 28.07% |
| - ១១-២០ឆ្នាំ | 40.58% | 36.84% |
| - > ២០ឆ្នាំ | 11.18% | 8.77% |
| **បទពិសោធន៍បង្រៀនពីចម្ងាយ មុនពេលមានកូវីដ១៩** | | |
| - មាន | 10.90% | 1.75% |
| - គ្មាន | 89.10% | 98.25% |
| **ការបណ្ដុះបណ្ដាលស្ដីពីការបង្រៀនពីចម្ងាយ** | | |
| - មាន | 84.98% | 70.18% |
| - គ្មាន | 8.31% | 24.56% |
| - មិនបង្រៀន | 6.71% | 5.26% |

*កំណត់សំគាល់៖ *និស្សិតថ្នាក់បណ្ឌិត បេក្ខជនបណ្ឌិត រៀនចប់តែមិនទាន់បញ្ចប់និក្ខេបបទ*

រូបភាព១៖ យោបល់របស់បុគ្គលិកបង្រៀនលើបញ្ហាប្រឈម ក្នុងពេលមានវិបត្តិកូវីដ១៩



តារាង២៖ យោបល់របស់បុគ្គលិកបង្រៀនលើបញ្ហាប្រឈម ក្នុងពេលមានវិបត្តិកូវីដ១៩ គិតតាមអនុក្រុម

| | ប្រុស | ស្រី | គម្លាត | រដ្ឋ | ឯកជន | គម្លាត | សាកលវិទ្យាល័យ | TVET | គម្លាត | ភ្នំពេញ | ខេត្ត | គម្លាត |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 3.6 | 3.5 | 0.1 | 3.7 | 3.5 | 0.2 | 3.5 | 3.9 | 0.4 | 3.6 | 3.7 | 0.1 |
| បញ្ហាបណ្តាញអ៊ីនធើណិត | 3.6 | 3.7 | 0.1 | 3.7 | 3.5 | 0.2 | 3.6 | 3.7 | 0.1 | 3.5 | 3.9 | 0.4 |
| ការពិភាក្សាជាក្រុមពីចម្ងាយ | 3.5 | 3.6 | 0.1 | 3.6 | 3.4 | 0.3 | 3.5 | 3.8 | 0.3 | 3.4 | 3.7 | 0.3 |
| ការរំខាន | 3.5 | 3.3 | 0.1 | 3.5 | 3.4 | 0.0 | 3.5 | 3.5 | 0.0 | 3.4 | 3.6 | 0.2 |
| ការចំណាយពេលច្រើនរៀបចំមេរៀន | 3.3 | 3.7 | 0.4 | 3.4 | 3.4 | 0.0 | 3.3 | 3.7 | 0.4 | 3.3 | 3.5 | 0.2 |
| កំណើនគម្លាតរៀនសូត្ររវាងសិស្សធូរធារនិងសិស្សក្រីក្រ | 3.3 | 3.3 | 0.0 | 3.4 | 3.2 | 0.2 | 3.2 | 3.8 | 0.5 | 3.2 | 3.5 | 0.3 |
| អន្តរកម្មជាមួយសិស្សពីចម្ងាយ | 3.2 | 3.7 | 0.5 | 3.4 | 3.2 | 0.1 | 3.2 | 3.8 | 0.6 | 3.2 | 3.4 | 0.2 |
| ព័ត៌មានត្រឡប់ដល់សិស្សតាមការរៀនពីចម្ងាយ | 3.1 | 3.2 | 0.2 | 3.2 | 3.0 | 0.2 | 3.0 | 3.6 | 0.6 | 3.1 | 3.2 | 0.1 |
| សិស្សពុំមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ | 3.0 | 3.0 | 0.0 | 3.1 | 2.9 | 0.2 | 2.9 | 3.2 | 0.2 | 3.0 | 3.1 | 0.1 |
| សិស្សពុំមានឧបករណ៍ចាំបាច់ៗ | 2.9 | 3.0 | 0.1 | 3.0 | 2.8 | 0.2 | 2.8 | 3.0 | 0.2 | 2.9 | 3.0 | 0.1 |
| **មធ្យមសរុប** | **3.3** | **3.4** | **0.1** | **3.4** | **3.2** | **0.2** | **3.3** | **3.6** | **0.3** | **3.3** | **3.5** | **0.2** |

នៅសាកលវិទ្យាល័យ សាស្ត្រាចារ្យមានអាយុជាមធ្យម ៤១,៣៧ឆ្នាំ រីឯនៅវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បុគ្គលិកបង្រៀនមានអាយុជាមធ្យម ៣៧,៧៤ឆ្នាំ។ អ្នកស្ថិតក្នុងក្រុមអាយុ ៣១-៤០ឆ្នាំ មានចំនួនប្រហែលពាក់កណ្តាល ដោយនៅតាមសាកលវិទ្យាល័យមាន ៤៥,០៥% និងនៅតាមវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មាន ៥៧,៨៩%។

ជាង ៧២,០០% នៃសាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យ មានសញ្ញាប័ត្រជាន់ខ្ពស់ ប្រហែល១៣,០០% មានសញ្ញាប័ត្របណ្ឌិត និង ១២,១៤% បានរៀនថ្នាក់បណ្ឌិត ប៉ុន្តែមិនទាន់បញ្ចប់ការសិក្សាជោគជ័យនៅឡើយ។ នៅតាមវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បុគ្គលិកបង្រៀន មានគុណវុឌ្ឍិទាបជាងច្រើន ដោយប្រមាណមួយភាគបីនៃអ្នកឆ្លើយសម្ភាសន៍មានត្រឹម បរិញ្ញាបត្រ ឬសញ្ញាប័ត្រកម្រិតខ្ពស់ ជាង ៦៣,០០% មានសញ្ញាប័ត្រអនុបណ្ឌិត ហើយពុំមានអ្នកដែលបានចូលរៀនថ្នាក់បណ្ឌិតនោះទេ។

បទពិសោធន៍បង្រៀនរបស់អ្នកឆ្លើយសម្ភាសន៍មានតាំងពី តិចជាងមួយឆ្នាំ រហូតដល់ច្រើនជាង២០ឆ្នាំ។ នៅសាកលវិទ្យាល័យ ជាងពាក់កណ្តាលនៃអ្នកឆ្លើយសម្ភាសន៍បានបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សាចាប់ពី ១០ឆ្នាំឡើងទៅ ប្រមាណ ១១,០០% ធ្លាប់មានបទពិសោធន៍បង្រៀនតាមអនឡាញខ្លះ មុនពេលមានជំងឺកូវីដ១៩ ឆ្លងរាលដាល ធៀបនឹងត្រឹម ១,៧៥% នៅតាមវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ។ បុគ្គលិកបង្រៀនមួយភាគធំ (៨៤,៩៨% នៅសាកលវិទ្យាល័យ និង ៧០,១៨% នៅវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ធ្លាប់បានទទួលការបណ្តុះបណ្តាលខ្លះ ស្តីពី ការបង្រៀនពីចម្ងាយ ក្រោយពីសាលារៀនត្រូវបិទទ្វារ។

*បញ្ហាប្រឈមក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩*

ដូចមានបង្ហាញក្នុងរូបភាព១ ភាពកម្សោយនៃបណ្តាញអ៊ីនធើណិត ភាពលំបាកក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់និស្សិតពីចម្ងាយ បញ្ហាក្នុងការពិភាក្សាជាក្រុមពីចម្ងាយ ភាពរអាក់រអួល និងការចំណាយពេលរៀបចំមេរៀន សម្រាប់បង្រៀនតាមអនឡាញ ជាបញ្ហាដែលបុគ្គលិកបង្រៀន បានលើកឡើងច្រើនជាងគេនៅក្នុងអង្កេត។ បុគ្គលិកបង្រៀន ៦៩% បានយល់ស្រប ឬយល់ស្របទាំងស្រុងថា និស្សិតមានការលំបាកក្នុងការរៀនតាមប្រព័ន្ធអនឡាញ ដោយសារបណ្តាញអ៊ីនធើណិតមានកម្លាំងខ្សោយ ឬមានកម្រិត ហើយការវាយតម្លៃលទ្ធផលសិក្សារបស់និស្សិតពីចម្ងាយក៏ពិបាកដែរ។ បញ្ហាទាំងនេះមាន បញ្ជាក់ច្បាស់ក្នុងសម្ភាសន៍ KII ជាមួយបុគ្គលិកគ្រប់គ្រង ទាំងនៅតាមសាកលវិទ្យាល័យ និងវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ បញ្ហាចម្បងជាងគេ គឺបណ្តាញអ៊ីនធើណិតពុំមានស្ថិរភាព ឬការដាច់អ៊ីនធើណិត ជាពិសេសនៅតាមជនបទ ដែលមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍គ្រប់គ្រាន់។

ចំពោះនិស្សិតក្រីក្រ តម្រូវការអ៊ីនធើណិតសម្រាប់ការរៀនសូត្រ ជាបន្ទុកហិរញ្ញវត្ថុមួយថែមទៀត ពីព្រោះគ្រួសាររបស់គាត់ទំនងជាត្រូវប៉ះទង្គិចខ្លាំងផ្នែកហិរញ្ញវត្ថុដោយកូវីដ១៩។ ដើម្បីដោះស្រាយបញ្ហានេះ គ្រឹះស្ថានឧត្តមសិក្សាមួយដែលមានការគាំទ្រពីមូលនិធិខាងក្រៅ បានផ្តល់ឲ្យនិស្សិតក្រីក្រនូវប្រាក់ឧបត្ថម្ភ ពិសេសចំនួន ៥០ដុល្លារ សម្រាប់បង់ថ្លៃអ៊ីនធើណិត និងទិញសម្ភារៀនសូត្រ។ គ្រឹះស្ថានឧត្តមសិក្សាជាច្រើនបានសារភាពថា គេពិបាកកាត់បន្ថយ ឬក៏មិនអាចទប់ស្កាត់ការក្លែងបន្លំបានទេ នៅពេលធ្វើការវាយតម្លៃការសិក្សានិស្សិតពីចម្ងាយ។

ទោះជាយ៉ាងនេះក្តី ការរៀបចំប្រព័ន្ធវាយតម្លៃការសិក្សានិស្សិតប្រកបដោយប្រសិទ្ធភាព និងតម្លាភាព មិនមែនជាអាទិភាពចម្បងសម្រាប់គ្រឹះស្ថានឧត្តមសិក្សានោះទេ ព្រោះកិច្ចការបន្ទាន់ចាំបាច់

រូបភាព២៖ កាលានុវត្តភាពយោងតាមយោបល់របស់បុគ្គលិកបង្រៀន




គឺការធានាឲ្យនិស្សិត និងគ្រូ បានស្គាល់ច្បាស់ និងអាចប្រើប្រាស់ឧបករណ៍ និងសម្ភារបច្ចេកវិទ្យា ដើម្បីសម្រួលដល់ការរៀនសូត្រ។ ចំណេះដឹង និងជំនាញរបស់និស្សិត និងកង្វះខាតឧបករណ៍សម្ភារប្រើប្រាស់ចាំបាច់ ក៏ជាក្តីបារម្ភរបស់បុគ្គលិកបង្រៀនដែរ ប៉ុន្តែបញ្ហានេះ វាមិនធ្ងន់ធ្ងរដូចបញ្ហាប្រឈមខាងលើទេ។ យោងតាមសម្ភាសន៍ KII និស្សិតភាគច្រើន យ៉ាងហោចណាស់មានទូរស័ព្ទឆ្លាតមួយដែរ ហើយនិស្សិតឆ្នាំទី៣ និងឆ្នាំបញ្ចប់ភាគច្រើនសុទ្ធតែមានកុំព្យូទ័រផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់។

ការវិភាគតាមអនុក្រុម ដូចមានចុះក្នុងតារាង២ បង្ហាញថា បុគ្គលិកបង្រៀនដែលជាស្រ្តី នៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅក្រៅរាជធានីភ្នំពេញ និងនៅតាមវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មានក្តីបារម្ភច្រើនអំពីការសិក្សាពីចម្ងាយ។ ឧទាហរណ៍ ផ្អែកតាមពិន្ទុLikert ជាមធ្យម គេអាចដឹងថា អត្រាដែលស្រ្តីយល់ស្របថា ការធ្វើអន្តរកម្មជាមួយនិស្សិតពីចម្ងាយ វាមានការលំបាក ហើយការរៀបចំមេរៀនសម្រាប់បង្រៀនតាមអនឡាញវាត្រូវការពេលច្រើន គឺមានកម្រិតខ្ពស់ជាងបុរស។ បុគ្គលិកបង្រៀននៅតាមសាកលវិទ្យាល័យឯកជន ហាក់យល់ឃើញថា ការបង្រៀនពីចម្ងាយមិនសូវជាលំបាកទេ ហើយនិស្សិត ក៏មិនសូវមានបញ្ហាទាក់ទងនឹងជំនាញ និងឧបករណ៍សម្ភារចាំបាច់សម្រាប់ការរៀនតាមអនឡាញដែរ។ ការបង្រៀនពីចម្ងាយនៅក្រៅរាជធានី ជួបឧបសគ្គច្រើនជាង ដោយសារភាពកម្សោយ ឬលក្ខណៈមិនសូវមានស្ថិរភាពនៃបណ្តាញអ៊ីនធើណិត និងកង្វះការចូលរួមរបស់និស្សិតក្នុងការពិភាក្សាតាមអនឡាញ។

បុគ្គលិកបង្រៀននៅតាមវិទ្យាស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ហាក់ជួបបញ្ហាប្រឈមច្រើន ក្នុងការបង្រៀនពីចម្ងាយ។ ឧបសគ្គដែលមានពិន្ទុមធ្យមខ្ពស់ជាង ៣,៨ មានជាអាទិ៍ ការវាយតម្លៃលទ្ធផលសិក្សារបស់និស្សិត កង្វះការពិភាក្សាតាមក្រុម កំណើនគម្លាតរៀនសូត្រ រវាងនិស្សិតធូរធារនឹងនិស្សិតក្រីក្រ និងការធ្វើអន្តរកម្ម ជាមួយនិស្សិតពីចម្ងាយ។ លើសពីនេះទៀត បុគ្គលិកបង្រៀននៅតាមវិទ្យាស្ថានអប់រំ និង

តារាង៣៖ យោបល់របស់បុគ្គលិកបង្រៀនស្តីពីកាលានុវត្តភាពផុសចេញពីកូវីដ១៩ តាមអនុក្រុម

| | ប្រុស | ស្រី | គម្លាត | រដ្ឋ | ឯកជន | គម្លាត | សាកលវិទ្យាល័យ | TVET | គម្លាត | ភ្នំពេញ | ខេត្ត | គម្លាត |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការរៀនសូត្របែបចម្រុះនៅពេលអនាគត | 4.1 | 4.1 | -0.1 | 4.0 | 4.1 | 0.0 | 4.1 | 4.1 | 0.0 | 4.0 | 4.2 | -0.2 |
| ឱកាសដាក់បញ្ចូល ICT ក្នុងការបង្រៀន | 4.1 | 4.1 | 0.0 | 4.1 | 4.1 | -0.1 | 4.1 | 4.1 | 0.0 | 4.1 | 4.2 | -0.1 |
| ការបង្កើនជំនាញ ICT | 3.8 | 4.0 | -0.3 | 3.8 | 3.8 | 0.0 | 3.8 | 3.8 | 0.0 | 3.8 | 3.8 | 0.0 |
| ការពេញចិត្តនឹងវេទិការៀនសូត្រ | 3.6 | 3.6 | 0.0 | 3.5 | 3.7 | -0.3 | 3.7 | 3.1 | 0.5 | 3.6 | 3.5 | 0.1 |
| ប្រសិទ្ធភាពនៃការរៀនសូត្រពីចម្ងាយ | 3.2 | 3.2 | 0.1 | 3.1 | 3.3 | -0.2 | 3.3 | 2.9 | 0.4 | 3.3 | 3.2 | 0.1 |
| សាលាមានប្រព័ន្ធគ្រប់គ្រងការរៀនសូត្រសមស្រប | 3.3 | 3.5 | -0.2 | 3.1 | 3.5 | -0.4 | 3.4 | 2.8 | 0.6 | 3.4 | 3.0 | 0.4 |
| ការត្រៀមខ្លួនបានល្អសម្រាប់ការរៀនសូត្រពីចម្ងាយ | 3.4 | 3.2 | 0.2 | 3.2 | 3.5 | -0.4 | 3.5 | 2.8 | 0.6 | 3.4 | 3.2 | 0.3 |
| | **3.6** | **3.7** | **0.0** | **3.5** | **3.7** | **-0.2** | **3.7** | **3.4** | **0.3** | **3.7** | **3.6** | **0.1** |

បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ក៏មានការបារម្ភជាពិសេសពី ចំណេះដឹងនិងជំនាញរបស់និស្សិត និងបញ្ហាកង្វះឧបករណ៍សម្ភារចាំបាច់ សម្រាប់ការរៀនពីចម្ងាយ។ កិច្ចសម្ភាសន៍ KII នៅតាមវិទ្យាស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ បង្ហាញថា មុខវិជ្ជាខ្លះមិនអាចរៀនពីចម្ងាយបានទេ ព្រោះវាត្រូវការអនុវត្តច្រើន ដែលតម្រូវឲ្យនិស្សិតមកហាត់រៀននៅរោងជាង ឬបន្ទប់ពិសោធន៍ដោយផ្ទាល់។

*កាលានុវត្តភាពផុសចេញពីជំងឺឆ្លងរាលដាលកូវីដ១៩*

ថ្វីបើ កូវីដ១៩ បានបង្អាក់ការរៀនសូត្រមួយរយៈ និងបង្កបញ្ហាប្រឈមធំធេងដល់ការសិក្សាថ្នាក់ឧត្ដមសិក្សាក្ដី អង្កេតបុគ្គលិកបង្រៀនបានបង្ហាញថា បុគ្គលិកបង្រៀន ក៏ទទួលស្គាល់ពីកាលានុវត្តភាពផុសចេញពីជំងឺឆ្លងរាលដាលនេះដែរ។ អ្នកឆ្លើយសម្ភាសន៍ស្ទើរគ្រប់គ្នាបានយល់ស្រប ឬយល់ស្របខ្លាំងថា គួរមានការរៀនតាមអនឡាញចម្រុះគ្នាជាមួយនឹងការរៀនផ្ទាល់តាមថ្នាក់នាពេលអនាគត ហើយនេះជាឱកាសល្អសម្រាប់ឲ្យសាលារៀនដាក់បញ្ចូលបច្ចេកវិទ្យាអប់រំ (edtech) កាន់តែច្រើននៅក្នុងការសិក្សាថ្នាក់ឧត្ដមសិក្សា។ បុគ្គលិកគ្រប់គ្រងដែលឆ្លើយសម្ភាសន៍ក៏បានយល់ស្របជាមួយគំនិតទាំងនេះ និងកំពុងពិចារណាពីការអនុវត្តការរៀនសូត្របែបចម្រុះ (blended learning) ឬការផ្ដល់វគ្គសិក្សាអនឡាញនាអនាគត នៅពេលស្ថានភាពត្រឡប់មកប្រក្រតីវិញ។

បុគ្គលិកបង្រៀនភាគច្រើន បានរាយការណ៍ថា ការបង្រៀនពីចម្ងាយបានជួយលើកកម្ពស់ជំនាញ ICT របស់គាត់ ហើយនេះជាឱកាសល្អ សម្រាប់ឲ្យសាលារៀនដាក់បញ្ចូលបច្ចេកវិទ្យាអប់រំកាន់តែច្រើនទៅក្នុងការរៀនសូត្រ។ អ្នកឆ្លើយសម្ភាសន៍ប្រមាណមួយភាគបី ពេញចិត្តនឹងវេទិកាសិក្សា ដែលគ្រឹះស្ថានឧត្ដមសិក្សារបស់គាត់កំពុងប្រើប្រាស់។ អ្នកឆ្លើយសម្ភាន៍មួយភាគធំយល់ថាពួកគាត់ត្រៀមរៀបចំខ្លួនបានល្អ ក្នុងការបង្រៀនពីចម្ងាយ។ ប៉ុន្តែសម្ភាសន៍ KII បានបង្ហាញថា គ្រឹះស្ថានឧត្ដមសិក្សាភាគច្រើនមិនអាចវិនិយោគបានធំដុំទេ ក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) ឲ្យទំនើប ឬស្របតាមបំណងខ្លួន ព្រោះចំណាយមានកម្រិតខ្ពស់ ហើយធនធានមនុស្សក៏នៅខ្វះខាត។ យោងតាមអង្កេតបុគ្គលិកបង្រៀន និងសម្ភាសន៍ KII វេទិកាសិក្សាមានការពេញនិយមជាងគេ រួមមាន Microsoft Team និង Google Classroom ហើយគ្រឹះស្ថានឧត្ដមសិក្សាមួយចំនួនតូច ប្រើតែ Telegram (កម្មវិធីផ្ញើសារអនឡាញ) ប៉ុណ្ណោះ សម្រាប់ការរៀនសូត្រពីចម្ងាយ។ បុគ្គលិកបង្រៀនមិនសូវមានសុទិដ្ឋិនិយមទេពីប្រសិទ្ធភាពនៃការរៀនពីចម្ងាយ ព្រោះមានតែ ៤០% ប៉ុណ្ណោះដែលគិតថា ការរៀនពីចម្ងាយ ជាវិធីសាស្ត្រមានប្រសិទ្ធភាពសម្រាប់ការរៀនសូត្រ។

ការវិភាគតាមអនុក្រុម ដូចមានចុះក្នុងតារាង៣ បានបង្ហាញថា បុគ្គលិកបង្រៀនទាំងពីរភេទ និងគ្រប់គ្រឹះស្ថាន មានយោបល់វិជ្ជមានលើការរៀនបែបចម្រុះ និងយល់ថាជំងឺឆ្លងរាលដាលនេះជាឱកាសល្អ សម្រាប់ឲ្យគ្រឹះស្ថានឧត្ដមសិក្សាដាក់បញ្ចូលបច្ចេកវិទ្យាអប់រំ ទៅក្នុងការរៀន និងបង្រៀន។ ពិន្ទុជាមធ្យមរបស់បុគ្គលិកបង្រៀនគ្រប់អនុក្រុម ស្ដីពីចំណុចទាំងពីរខាងលើ វាខ្ពស់ជាង ៤ (៥ ជាពិន្ទុខ្ពស់បំផុត)។ ទោះបីបុគ្គលិកបង្រៀនជាស្ត្រី ជួបបញ្ហាប្រឈមច្រើនក្ដី ពួកគាត់មានសុទិដ្ឋិនិយមប្រហាក់ប្រហែលនឹងបុគ្គលិកបង្រៀនជាបុរសដែរ ស្ដីពីផលប្រយោជន៍ផុសចេញពីជំងឺឆ្លងរាលដាលនេះ ដោយមានជំនឿថា ការបង្រៀនពីចម្ងាយបានជួយគាត់ឲ្យអភិវឌ្ឍជំនាញICTរបស់ខ្លួន។បុគ្គលិកបង្រៀននៅតាមគ្រឹះស្ថានឧត្ដមសិក្សារដ្ឋ វិទ្យាស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្ដមសិក្សានៅក្រៅរាជធានីមានអារម្មណ៍វិជ្ជមានតិចជាងពី កាលានុវត្តភាពបានមកពីជំងឺឆ្លងរាលដាលកូវីដ១៩។ ពិន្ទុមធ្យមនៃ ប្រសិទ្ធភាពការរៀនពីចម្ងាយ លក្ខណៈសមស្របនៃប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) របស់សាលា និងការត្រៀមរៀបចំខ្លួន សម្រាប់ការរៀនសូត្រពីចម្ងាយ ក្នុងចំណោមបុគ្គលិកបង្រៀននៅតាម វិទ្យាស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈមានកម្រិតទាបជាង ៣។

## សេចក្ដីសន្និដ្ឋាន

ពិតហើយថា ជំងឺឆ្លងរាលដាលកូវីដ១៩ បានបង្កផលប៉ះពាល់អវិជ្ជមានធំធេងណាស់ដល់ ការរៀនសូត្រកម្រិតឧត្ដមសិក្សានៅកម្ពុជា។ លទ្ធផលរកឃើញបង្ហាញថា បណ្ដាញអ៊ីនធើណិតមិនមានស្ថិរភាព និងការលំបាកក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់និស្សិត គឺជាឧបសគ្គធំៗជាងគេដែលរាំងស្ទះដល់ការផ្ដល់ការរៀនសូត្រពីចម្ងាយឲ្យមានប្រសិទ្ធភាព។ បុគ្គលិកបង្រៀនជាស្ត្រី និងបុគ្គលិកបង្រៀននៅតាមគ្រឹះស្ថានឧត្ដមសិក្សារដ្ឋ វិទ្យាស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្ដមសិក្សានៅក្រៅរាជធានី ទំនងជាជួបឧបសគ្គច្រើនជាង ក្នុងការបង្រៀនដោយប្រើបច្ចេកវិទ្យាអប់រំ។ ជាពិសេស បុគ្គលិកបង្រៀននៅតាមវិទ្យាស្ថានអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវការគាំទ្រផ្នែកបច្ចេកទេសច្រើនថែមទៀត ប្រសិនបើការរៀនសូត្រត្រូវផ្លាស់ប្ដូរពីថ្នាក់រៀន ទៅជាការរៀនសូត្រពីចម្ងាយ។

ទោះយ៉ាងនេះក្ដី ជំងឺឆ្លងរាលដាលនេះ បានជំរុញឲ្យគ្រឹះស្ថានឧត្ដមសិក្សានានាស្វែងរកនវានុវត្តន៍ ដូចជា ការដាក់បញ្ចូលបច្ចេកវិទ្យាអប់រំថ្មីៗទៅក្នុងការរៀននិងបង្រៀន និងការជួយគាំទ្រដល់បុគ្គលិកបង្រៀន ក្នុងការទទួលបានចំណេះដឹង និងជំនាញថ្មីៗទៀត។ វាក៏ជាកត្តាលីករជំរុញការរីកចម្រើនមួយដែរ ដែលសាលារៀន និងគ្រូ ត្រូវគិតគូរពិចារណាជាថ្មី ពីវិធីសាស្ត្រផ្សេងៗ ដូចជា ការរៀនបែបចម្រុះ និងវគ្គសិក្សាអនឡាញបើកទូលាយសម្រាប់មហាជន (massive open online courses) និងការដាក់វាបញ្ចូលទៅក្នុងវគ្គសិក្សា និងការរៀបចំកម្មវិធីសិក្សានាពេលអនាគត។ ដើម្បីធានាថា និស្សិតគ្រប់រូបនៅកម្ពុជា អាចទទួលបានអត្ថប្រយោជន៍ពីការរៀនសូត្រពីចម្ងាយ ត្រូវមានការកែលំអបណ្ដាញអ៊ីនធើណិតឆាប់រហ័ស តាមរយៈវិនិយោគខ្នាតធំលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅក្រៅរាជធានីភ្នំពេញ។

## ឯកសារយោង

Azevedo, João Pedro, Amer Hasan, Diana Goldemberg, Syedah Aroob, and Iqbal Koen Geven. 2020. *Simulating*

*តទៅទំព័រ ១៧*

# ការទូតក្នុងការគ្រប់គ្រងទឹកនៅអាងទន្លេមេគង្គ

## សេចក្ដីផ្ដើម

ទន្លេមេគង្គ ជាទន្លេវែងជាងគេលំដាប់ទី១២ ក្នុងពិភពលោក ដោយមានប្រវែងសរុប ៤.៨០០គ.ម និងហូរចេញពី ខ្ពង់រាបទីបេ កាត់តាមប្រទេសចិន មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា វៀតណាម រួចហូរចាក់ទៅសមុទ្រចិនខាងត្បូង (រូបភាព១)។ អាងទន្លេនេះឆ្លងកាត់ព្រំដែនប្រទេសជាច្រើន និងមានផ្ទៃសរុប ៧៩៥.០០០គ.ម² ពោលគឺ ជាអាងទន្លេធំជាងគេលំដាប់ទី២១ ក្នុងពិភពលោក (FAO 2011)។ អាងទន្លេនេះ អាចចែកចេញជាពីរចំណែក ពោលគឺអាងទន្លេខាងលើ នៅចិន (ដែលនៅទីនោះគេហៅទន្លេនេះថា ឡានឆាង) និងអាងទន្លេមេគង្គក្រោម ដែលលាតសន្ធឹងចាប់ពីខេត្តយុនណាន់ នៅចិន រហូតដល់វៀតណាមភាគខាងត្បូង (FAO 2011)។

រូបភាព១៖ ផែនទីអាងទន្លេមេគង្គ ដោយមានបង្ហាញព្រំប្រទល់ផ្នែកនយោបាយ




ប្រភព៖ គណៈកម្មការទន្លេមេគង្គ (MRC 2018)

ទំនាក់ទំនងពាក់ព័ន្ធនឹង ប្រភពទឹកឆ្លងកាត់ព្រំដែន តែងផ្សារភ្ជាប់ជាមួយនយោបាយជានិច្ច ព្រោះកំណត់ឡើងទៅតាម ផលប្រយោជន៍ផ្នែកសង្គមកិច្ច-នយោបាយ របស់បណ្ដារដ្ឋនៅជាប់អាងទន្លេ និងផលប្រយោជន៍ផ្នែកភូមិសាស្ត្រ-នយោបាយ របស់ប្រទេសធំៗនៅខាងក្រៅអាង (Barua, Vij and Rahman 2018; Warner et al. 2017)។ សហប្រតិបត្តិការក្នុងអាងទន្លេមេគង្គ ក៏មិនខុសប្លែកពីកន្លែងផ្សេងដែរ ព្រោះតំបន់នេះកាន់តែក្លាយជាចំណុចក្ដៅផ្នែកយុទ្ធសាស្ត្រ ភូមិសាស្ត្រ ដែលអាចពិនិត្យឃើញតាមរយៈ របៀបវារៈ និងការទាមទារប្រជែងគ្នារវាង បណ្ដាប្រទេសនៅតំបន់មេគង្គ និងដែលហាក់ដូចជាមានមហាអំណាចសកល រួមទាំង ចិន និងសហរដ្ឋអាមេរិកផង ចូលមកជំរុញដើម្បីប្រជែងយកឥទ្ធិពល (Kittikhoun and Staubli 2018)។

ភាពតានតឹងក្នុងចំណោមប្រទេសនៅតំបន់មេគង្គ លើការគ្រប់គ្រងធនធានទឹក ការប្រើប្រាស់ទឹក និងការអភិវឌ្ឍទន្លេ បានកើនឡើង ហើយប្រភពសំខាន់គឺ ការអភិវឌ្ឍវារីអគ្គិសនីលើទន្លេមេគង្គ និងដៃទន្លេរបស់វា។ ទោះយ៉ាងនេះក្ដី បញ្ហាមួយចំនួនទាក់ទងនឹងទឹក កន្លងមកអាចសម្រាល និងដោះស្រាយបានមួយភាគដោយ គណៈកម្មការទន្លេមេគង្គ (MRC) ក្នុងក្របខ័ណ្ឌនៃការទូតក្នុងការគ្រប់គ្រងទឹក (MRC 2016)។

ក្នុងអត្ថបទនេះ មានការណែនាំបង្ហាញពីក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក និងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់វា ដោយផ្ដល់នូវករណីសិក្សាបីនៃគម្រោងសាងសង់ទំនប់វារីអគ្គិសនី ដើម្បីជួយបំភ្លឺពីការអនុវត្តក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹករបស់ MRC និងមានពិភាក្សាពីបញ្ហាប្រឈមផ្សេងៗ ដែលចោទលើលទ្ធភាពរបស់ MRC ដើម្បីអនុវត្តការទូតក្នុងការគ្រប់គ្រងទឹកឲ្យមានប្រសិទ្ធភាព។ ចំណេះដឹងទទួលបានពីការសិក្សាលើទិដ្ឋភាពទាំងនេះ អាចជួយឲ្យមានការយល់ដឹងកាន់តែប្រសើរពីស្ថានភាពនៃការ

អត្ថបទនេះរៀបរៀងដោយ គាំង សារ៉ែន, អ្នកស្រាវជ្រាវ, ញ៉ង សូដាវី, ជំនួយការស្រាវជ្រាវ, និង បណ្ឌិត លន់ ពេជ្រតារា អ្នកស្រាវជ្រាវ និងជានាយក នៃមជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន។ សូមយោងអត្ថបទនេះថា៖ Keang Saren, Nhong Sodavy and Lonn Pichdara. 2020. “Water Diplomacy in the Mekong.” *Cambodia Development Review* 24 (4): 8–14.

រូបភាព២៖ ក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹករបស់ MRC




ប្រភព: ដកស្រង់ពី Kittikhoun and Staubli 2018

ទូតក្នុងការគ្រប់គ្រងទឹកនៅអាងទន្លេមេគង្គ និងការកំណត់ជំហានផ្សេងៗ ដើម្បីពង្រឹងសហប្រតិបត្តិការ រវាងប្រទេសជាសមាជិកក្នុងការទាញយកអត្ថប្រយោជន៍ឲ្យបានច្រើនបំផុតពីទន្លេមេគង្គ។

## ក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក របស់ MRC

ក្របខ័ណ្ឌនេះ មានឫសគល់ចេញពី សហប្រតិបត្តិការផ្នែកបច្ចេកទេសក្នុងវិស័យជាប់ទាក់ទងនឹងទឹក រួមមាន ការប្រមូល គ្រប់គ្រង និងចែករំលែកទិន្នន័យ, និងការឃ្លាំមើល និងព្យាករណ៍លំហូរទឹក (Kittikhoun and Staubli 2018) ហើយព័ត៌មានបានយកមកចងក្រងធ្វើជា របាយការណ៍ស្ដីពីស្ថានភាពអាងទឹក ការសិក្សានិងវាយតម្លៃនានា និងសេចក្ដីណែនាំផ្នែកបច្ចេកទេស ដើម្បីផ្ដល់ជាមូលដ្ឋានសម្រាប់ការស្វែងយល់ និងពិភាក្សាពីបញ្ហាផ្សេងៗដោយផ្អែកលើវិទ្យាសាស្ត្រ។ ដោយផ្អែកលើការយល់ដឹងបានល្អផ្នែកបច្ចេកទេសនេះ គឺមានយន្តការផ្សេងគ្នា តែជាប់ទាក់ទងគ្នាបីសម្រាប់ជួយសម្រួល និងគាំទ្រដល់ដំណោះស្រាយតាមការចរចានូវការខ្វែងគំនិតគ្នាលើបញ្ហាទឹក ភាពតានតឹង និងវិវាទផ្សេងៗ ពោលគឺ យន្តការផ្នែកច្បាប់ ស្ថាប័ន និងយុទ្ធសាស្ត្រ (រូបភាព២) (Kittikhoun and Staubli 2018)។

### *យន្តការផ្នែកច្បាប់*

កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ ដែលចុះហត្ថលេខាដោយរដ្ឋាភិបាល កម្ពុជា ឡាវ ថៃ និងវៀតណាម បានបង្កើត MRC ឡើង។ កិច្ចព្រមព្រៀងនេះ "ព្រមទាំងនីតិវិធីទាំងប្រាំរបស់ MRC សម្រាប់ឃ្លាំមើល និងចាត់ចែងលើបញ្ហា ការរក្សាលំហូរទឹក គុណភាពទឹក ការឃ្លាំមើលការប្រើប្រាស់ទឹក ការចែករំលែកទិន្នន័យនិងព័ត៌មាន និងការពិគ្រោះយោបល់លើ គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ បានបង្កើតនូវមូលដ្ឋានគ្រឹះផ្នែកច្បាប់ដ៏រឹងមាំស្ដីពី កាតព្វកិច្ចជាលក្ខណៈអន្តរជាតិក្នុងការចែករំលែក និងប្រើប្រាស់ទន្លេដែលឆ្លងកាត់ព្រំដែន" (Kittikhoun and Staubli 2018, 246)។ ក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គនេះ ប្រទេសទាំងបួនជាសមាជិក ត្រូវពិគ្រោះយោបល់គ្នាលើរាល់បញ្ហាផ្លូវច្បាប់ដែលជាប់ទាក់ទងនឹងការប្រើប្រាស់ទន្លេមេគង្គ។

### *យន្តការផ្នែកស្ថាប័ន*

គណៈកម្មការ MRC ស្ថិតក្រោមការដឹកនាំនៃ ក្រុមប្រឹក្សា MRC និងគណៈកម្មាធិការរួមគ្នានៃ MRC។ ក្រុមប្រឹក្សាMRC ធ្វើការពិនិត្យ និងសម្របសម្រួលលើ បញ្ហាផ្សេងៗនៃទន្លេមេគង្គនៅកម្រិតតំបន់

រូបភាព៣៖ រចនាសម្ព័ន្ធអភិបាលកិច្ច MRC




ប្រភព៖ ដកស្រង់ពី Kittikhoun and Staubli 2018. កំណត់សំគាល់៖ ក.ជ = ក្រុមជំនាញការ

រីឯ គណៈកម្មាធិការជាតិទន្លេមេគង្គនានា និងលេខាធិការដ្ឋានរៀងៗខ្លួន ទទួលបន្ទុកលើកិច្ចការនេះនៅកម្រិតជាតិ (Kittikhoun and Staubli 2018)។ MRC ក៏មានក្រុមជំនាញការ MRC ក្រុមដៃគូ MRC និងភាគីពាក់ព័ន្ធកម្រិតតំបន់ច្រើនទៀត ដែលធ្វើការទាំងអស់គ្នាដើម្បីសម្រេចបានការអភិវឌ្ឍ ការប្រើប្រាស់ ការគ្រប់គ្រង និងថែរក្សាទឹក និងធនធានជាប់ទាក់ទិនផ្សេងៗនៅក្នុងអាងទន្លេមេគង្គឲ្យមានចីរភាព។ ក្រុមជំនាញការទទួលបន្ទុកធ្វើផែនការសម្រាប់អាងទឹក ការគ្រប់គ្រងបរិស្ថាន ការធ្វើម៉ូដែលចាត់ចែងទិន្នន័យ និងព្យាករណ៍លំហូរទឹក (Kittikhoun and Staubli 2018)។ភាគីពាក់ព័ន្ធក្នុងតំបន់ ពាំនាំសម្លេងរបស់តួអង្គមិនមែនរដ្ឋ ដូចជា អង្គការក្រៅរដ្ឋាភិបាល (NGOs) អង្គការសង្គមស៊ីវិល (CSOs) និងវិស័យឯកជន មកជួបយោបល់គ្នានៅតុពិភាក្សា។ MRC ទទួលបន្ទុករៀបចំ និងអនុម័តនូវយុទ្ធសាស្ត្រ និងផែនការផ្សេងៗសម្រាប់អាងទន្លេ (Kittikhoun and Staubli 2018)។

## *យន្តការផ្នែកយុទ្ធសាស្ត្រ*

ធាតុផ្សំផ្នែកយុទ្ធសាស្ត្រ រួមមាន យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ ផែនការយុទ្ធសាស្ត្រ MRC, ផែនការផ្ដល់គំនិតថ្នាក់ជាតិរបស់បណ្ដាប្រទេសសមាជិក (គម្រោងរួមគ្នា) និងយុទ្ធសាស្ត្រតាមប្រធានបទ និងតាមវិស័យ។ យុទ្ធសាស្ត្រ និងផែនការទាំងនេះ "ផ្ដល់ទិសដៅ និងការណែនាំ ដើម្បីដោះស្រាយតម្រូវការក្នុងអាងទាំងមូល បញ្ហាប្រឈម និងឱកាសដែលប្រទេសមួយ មិនអាចធ្វើតែឯងបាន" (Kittikhoun and Staubli 2018, 248)។ ទិដ្ឋភាពជាយុទ្ធសាស្ត្រនេះ ជួយបំពេញលើក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក និងជួយគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥។

## រចនាសម្ព័ន្ធអភិបាលកិច្ចរបស់ MRC

ប្រទេសសមាជិក MRC រួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម។ មហាសន្និបាតបួនឆ្នាំម្ដងរបស់ MRC គឺជាព្រឹត្តិការណ៍នយោបាយកម្រិតខ្ពស់បំផុតរបស់ MRC ដែលអញ្ជើញមកជួបជុំគ្នានូវ ប្រមុខរដ្ឋាភិបាលប្រទេសសមាជិកទាំងបួន និងអ្នកដឹកនាំនយោបាយមកពីដៃគូសន្ទនា (ដែលជាបណ្ដាប្រទេសចូលរួមក្នុងកិច្ចប្រជុំសន្ទនាប្រចាំឆ្នាំរបស់ MRC) ដូចជា ចិន និង មីយ៉ាន់ម៉ា ជាដើម និងដៃគូអភិវឌ្ឍន៍នានា ដើម្បីបូកសរុបសហប្រតិបត្តិការលើទន្លេមេគង្គ និងផ្ដល់ទិសដៅជាយុទ្ធសាស្ត្រ។

គណៈកម្មការ MRC មានបីអង្គភាព។ អាជ្ញាធរខ្ពស់ជាងគេគឺក្រុមប្រឹក្សា MRC ដែលមានសមាសភាពជារដ្ឋមន្ត្រីផ្នែកទឹកនិងបរិស្ថាននៃបណ្ដាប្រទេសសមាជិក និងជួបប្រជុំមួយឆ្នាំម្ដង ដើម្បីពិភាក្សាពីបញ្ហាជាប់ទាក់ទងនឹងទន្លេមេគង្គ។ បន្ទាប់គឺ គណៈកម្មាធិការរួមគ្នា រួមមាន ប្រធាននាយកដ្ឋានដែលទទួលបន្ទុកលើកិច្ចការទន្លេមេគង្គ ដែលជួបប្រជុំពីរដង ឬច្រើនដងក្នុងមួយឆ្នាំទៅតាមតម្រូវការ ដើម្បីពិនិត្យពី សហប្រតិបត្តិការរបស់គណៈកម្មាធិការ

ជាតិទន្លេមេគង្គនានា ជាមួយនឹង ដៃគូនិងភាគីពាក់ព័ន្ធនានា (របស់ MRC) ដែលចូលរួមក្នុង ក្រុមការងារធ្វើការលើបញ្ហារៀបចំអង្គការ ការធ្វើផែនការសម្រាប់អាងទឹក ការគ្រប់គ្រងបរិស្ថាន ការធ្វើម៉ូដែលចាត់ចែងទិន្នន័យនិងព្យាករណ៍ និង ការធ្វើផែនការយុទ្ធសាស្ត្រ និងភាពជាដៃគូ។

អង្គភាពទី៣ គឺលេខាធិការដ្ឋាន MRC (MRCS) ដែលរួមមានការិយាល័យនៃអគ្គនាយកប្រតិបត្តិ និងផ្នែកទាំងបួន គឺមាន ផ្នែករដ្ឋបាល ផ្នែកធ្វើផែនការ ផ្នែកគ្រប់គ្រងបរិស្ថាន និងផ្នែកជំនួយគាំទ្របច្ចេកទេស។ MRCS ធ្វើការជាមួយគណៈកម្មាធិការរួមគ្នា និងបម្រើការជាមជ្ឈមណ្ឌលចំណេះដឹងផ្នែកបច្ចេកទេស និងជាអ្នកសម្របសម្រួលវេទិកាការទូតក្នុងការគ្រប់គ្រងទឹក ហើយធ្វើការជិតស្និទ្ធផងដែរជាមួយដៃគូសន្ទនាទាំងឡាយ រួមមាន ចិន និង មីយ៉ាន់ម៉ា និងភាគីពាក់ព័ន្ធសំខាន់ៗឯទៀត។

### ករណីសិក្សា

កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ កំណត់ថា បណ្តាប្រទេសសមាជិកត្រូវអនុវត្តដំណើរការពិគ្រោះយោបល់ជាមុន ស្របតាមនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ដើម្បីពិនិត្យឡើងវិញរួមគ្នាលើ គម្រោងអភិវឌ្ឍន៍ដែលត្រូវបានស្នើឡើង ដើម្បីប្រើប្រាស់ទឹកយកពីខ្សែទឹកចម្បងនៃទន្លេមេគង្គ ក្នុងគោលដៅឲ្យមានការមូលមតិថា គម្រោងនោះគួរ ឬមិនគួរអនុវត្ត ហើយបើគួរអនុវត្តតើក្នុងលក្ខខណ្ឌអ្វីខ្លះ។ អត្ថបទនេះពិនិត្យដោយសង្ខេបលើ បីគម្រោងវារីអគ្គិសនី ដើម្បីជួយបំភ្លឺពី បែបបទដែលក្របខ័ណ្ឌការទូត ក្នុងការគ្រប់គ្រងទឹករបស់ MRC ត្រូវបានដាក់បញ្ចូលទៅក្នុងនោះ។

#### *គម្រោងវារីអគ្គិសនីសាយបុរី (Xayaburi)*

សំណើសាងសង់ទំនប់វារីអគ្គិសនី សាយបុរី លើខ្សែទឹកចម្បងនៃទន្លេមេគង្គ គឺរដ្ឋាភិបាលឡាវបានដាក់ជូន MRCS នៅខែកញ្ញា ២០១០ សម្រាប់ការពិគ្រោះយោបល់ជាមុន។ សំណើនេះបានទាក់ទាញការយកចិត្តជាច្រើន ពីបណ្តាប្រទេសសមាជិក, ដៃគូអភិវឌ្ឍន៍, CSOs, NGOs, និងអង្គការអន្តរជាតិ ដោយសារវាអាចមានផលប៉ះពាល់លើបរិស្ថាននៅក្នុងតំបន់ និងឆ្លងកាត់ព្រំដែនជាពិសេសលើ ត្រីនិងធនធានជលផល ការដឹកជញ្ជូននិងផ្គត់ផ្គង់ដីល្បាប់ និងប្រជាជនដែលមានជីវភាពពឹងផ្អែកលើ ធនធានធម្មជាតិរបស់ទន្លេ (Kittikhoun and Staubli 2018)។ កម្ពុជា ថៃ និង វៀតណាម បានស្នើឲ្យមានពេលវេលាច្រើនថែមទៀត ដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់ឆ្លងកាត់ព្រំដែនលើបរិស្ថាន និងការពិគ្រោះយោបល់ ប៉ុន្តែឡាវមិនបានបន្ថែមរយៈពេលពិគ្រោះយោបល់ទេ (Kittikhoun and Staubli 2018)។ ប៉ុន្តែរដ្ឋាភិបាលឡាវបានបង្ហាញសុឆន្ទៈ ក្នុងការធ្វើការសិក្សាថែមទៀត ដើម្បីដោះស្រាយ បញ្ហានានាដែលបានលើកឡើងដោយ MRCS ក្នុងការពិនិត្យឡើងវិញផ្នែកបច្ចេកទេស និងក្តីបារម្ភរបស់ភាគីពាក់ព័ន្ធនៅក្នុងតំបន់។

នៅឆ្នាំ២០១១ ក្រុមប្រឹក្សា MRC បានយល់ព្រមធ្វើការសិក្សាមួយលើការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ រួមទាំង ផលប៉ះពាល់នៃគម្រោងវារីអគ្គិសនីនៅលើខ្សែទឹកចម្បងនៃទន្លេទៀតផង ដើម្បីពិនិត្យពិចារណា និងរៀនសូត្រពីដំណើរការ PNPCA សាយបុរី និងអាចយល់ដឹងកាន់តែប្រសើរពីផលប៉ះពាល់លើអាងទន្លេ ទៅតាមសេណារីយ៉ូអភិវឌ្ឍន៍ផ្សេងៗនាពេលអនាគត។ គម្រោងទំនប់វារីអគ្គិសនី សាយបុរី បានដំណើរការល្អខាងផ្នែកបច្ចេកទេស ប៉ុន្តែមិនសូវល្អទេក្នុងទិដ្ឋភាពផ្នែកស្ថាប័ននិងយុទ្ធសាស្ត្រ។ ទោះបីជាគម្រោងនេះ មានការវាយតម្លៃផលប៉ះពាល់ក្តី ប៉ុន្តែមិនមានអង្គភាពជាស្ថាប័នពេញលេញអ្វីកំណត់នូវ ផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយ សម្រាប់ដោះស្រាយបញ្ហាផ្សេងៗ ដែលផុសឡើង ក្នុងពេលអនុវត្តគម្រោងនោះទេ។

#### *គម្រោងវារីអគ្គិសនី ដនសាហុង (Don Sahong)*

ដំណើរការពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងវារីអគ្គិសនីដនសាហុង ដែលជាទំនប់ទី២ និងគ្រោងសាងសង់ឡើងនៅលើខ្សែទឹកចម្បងនៃទន្លេមេគង្គ បានចាប់ផ្តើមនៅខែកក្កដា ២០១៤។ ស្រដៀងគ្នានឹងគម្រោងវារីអគ្គិសនី សាយបុរី ដែរ គម្រោងដនសាហុង មានការរិះគន់ និងជជែកវែកញែកជាច្រើនពីផលប៉ះពាល់ដែលអាចកើតមានលើបរិស្ថាន ជាពិសេស លើពួកផ្សោតអ៊ីរ៉ាវ៉ាឌី ដែលជាពូជសត្វជានិមិត្តរូបនៃទន្លេមេគង្គ ប៉ុន្តែសព្វថ្ងៃកំពុងរងគ្រោះខ្លាំងបំផុត (Kittikhoun and Staubli 2018)។ NGOs និង CSOs ជាច្រើនក៏បានលើកពីក្តីបារម្ភអំពីជលផលនិងជីវភាពផ្សារភ្ជាប់នោះដែរ។ ជាថ្មីម្តងទៀត កម្ពុជា ថៃ និង វៀតណាម នៅមានការសង្ស័យ ហើយបានទាមទារពេលវេលាបន្ថែម សម្រាប់ធ្វើការវាយតម្លៃពីផលប៉ះពាល់ឆ្លងកាត់ព្រំដែនមុននឹងព្រមព្រៀងឲ្យអនុវត្តគម្រោងនេះ។ កម្ពុជាបានជំរុញឡាវ "ឲ្យប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បី ជៀសវាង ធ្វើការកាត់បន្ថយជាអតិបរមា និងសម្រាលឥទ្ធិពលអាក្រក់ដែលអាចកើតមានលើបរិស្ថាន" (Cambodia National Mekong Committee 2015 cited in Kittikhoun and Staubli 2018, 664) ហើយ ថៃ និង វៀតណាម ក៏មានសំណើស្រដៀងគ្នាដែរ។

ដំណើរការផ្តល់ការយល់ ព្រមឲ្យចាប់ដំណើរការគម្រោងនេះប្រើពេលយូរជាងទំនប់ សាយបុរី ពីព្រោះ MRCS តាមការណែនាំរបស់គណៈកម្មាធិការរួមគ្នា បានបន្ថែមរយៈពេលពិគ្រោះយោបល់ជាមុន ដើម្បីធ្វើការវាយតម្លៃលើឯកសារបញ្ជាក់ហេតុផលផ្សេងៗដែលឡាវបានដាក់ជូនពិនិត្យ។ ក្រោយមកកម្ពុជាក៏បានយល់ព្រមលើសំណើរបស់ឡាវ ពីព្រោះការវាយតម្លៃផលប៉ះពាល់បរិស្ថានរបស់កម្ពុជា បានសន្និដ្ឋានថា គម្រោងនេះ "មិនទំនងបង្កផលប៉ះពាល់ឆ្លងកាត់ព្រំដែនច្រើនទេទៅលើកម្ពុជា" (Kittikhoun and Staubli 2018, 664)។ កម្ពុជា និងឡាវ បានធ្វើការជាមួយគ្នាតាមរយៈកម្មវិធីឃ្លាំមើលបរិស្ថានរួមគ្នាស្តង់ដារ របស់ MRC សម្រាប់គម្រោងដនសាហុង។

ដោយបានគំនិតពីគម្រោងនេះ MRCS បានធ្វើសិក្ខាសាលាសន្ទនាគ្នាមួយស្តីពី បទពិសោធន៍ទទួលបានពី PNPCAs ទាំងពីរមុននេះ។ ព្រឹត្តិការណ៍នេះបាននាំមកជួបជុំគ្នានូវ អ្នកអនុវត្តជាក់ស្តែងមកពីបណ្តាប្រទេសសមាជិក និងអ្នកជំនាញការខាងច្បាប់

អន្តរជាតិ ដើម្បីកំណត់អនុសាសន៍ផ្សេងៗ ដែលអាចមានប្រយោជន៍ សម្រាប់ការវាយតម្លៃគម្រោង និងការចរចាទៅអនាគត។ លទ្ធផលទទួលបាន ត្រូវបានដាក់បញ្ចូលក្នុង PNPCAs ក្រោយៗមកទៀត។ គម្រោងនេះដំណើរការបានល្អទាក់ទងនឹងការចូលរួមពីភាគីពាក់ព័ន្ធ ប៉ុន្តែទិដ្ឋភាពយុទ្ធសាស្ត្រអាចកែលំអថែមទៀតបាន។

### *គម្រោងវារីអគ្គិសនីប៉ាក់បេង (Pak Beng)*

ផែនការសាងសង់ទំនប់ ប៉ាក់បេង បានដាក់ជូន MRC នៅខែវិច្ឆិកា ២០១៦ សម្រាប់ការពិគ្រោះយោបល់ជាមុន។ ក្នុងនេះ ភាគីពាក់ព័ន្ធនានាបារម្ភខ្លាំងជាងគេពីចលនាត្រី ការគ្រប់គ្រងដីល្បាប់ និងការសម្របសម្រួល និងត្រួតពិនិត្យរបៀបរៀបចំសម្រាប់អាងមានច្រើនថ្នាក់ (cascade reservoirs) (Kittikhoun and Staubli 2018)។ នៅកម្រិតមូលដ្ឋានក្តីបារម្ភភាគច្រើនបានស្តាប់ឮពីបណ្តាសហគមន៍រស់នៅតាមដងទន្លេមេគង្គ ក្នុងប្រទេសថៃ។ កម្ពុជា ថៃ និង វៀតណាម បានស្នើឲ្យមានការសិក្សាស៊ីជម្រៅជាងមុនពីផលប៉ះពាល់បូកគ្នានិងឆ្លងកាត់ព្រំដែន និងមានប្រព័ន្ធឃ្លាំមើល និងតាមដានបន្តមួយ (Kittikhoun and Staubli 2018)។

គម្រោងនេះបានទទួលអត្ថប្រយោជន៍ដូចតទៅពី PNPCA ដែលត្រូវបានកែលំអឡើង។ ក្នុងនេះ អន្តរកម្មនិងការជួបប្រជុំក្រៅផ្លូវការ និងវេទិកាបើកទូលាយកម្រិតតំបន់ ជួយឲ្យភាគីពាក់ព័ន្ធនានាទទួលបានព័ត៌មាន និងចូលរួមបានកាន់តែច្រើនក្នុងដំណើរការទាំងមូលនៃគម្រោង។ ជំហាននានាដែលបានកំណត់ច្បាស់សម្រាប់ ដំណាក់កាលរៀបចំ ដំណើរការពិគ្រោះយោបល់ជាមុន និងដំណើរការពិគ្រោះយោបល់តាមក្រោយ បានជួយឲ្យមានតម្លាភាពកាន់តែច្រើន និងការគ្រប់គ្រងកាន់តែល្អ។ ផែនការសកម្មភាពកសាងបានច្បាស់លាស់ ជួយឲ្យមាន ការចរចាប្រកបដោយលក្ខណៈកសាង និងប្រសិទ្ធភាព ក្នុងចំណោមប្រទេសសមាជិក និងសេចក្តីប្រកាសយល់ព្រមរបស់ប្រទេសទាំងនេះ នៅខែមិថុនា ២០១៧ (Kittikhoun and Staubli 2018)។

សរុបមក ដំណើរការពិគ្រោះយោបល់ជាមុនលើកទី៣ របស់ MRC មានការកែលំអគួរឲ្យកត់សំគាល់លើ ដំណើរការពីមុនទាំងពីរ។ រចនាសម្ព័ន្ធរៀបចំអង្គការ និងផែនការសកម្មភាពបានកំណត់ច្បាស់ បានជួយឲ្យមានការគ្រប់គ្រងកាន់តែល្អ ហើយការចូលរួមសហការរបស់ភាគីពាក់ព័ន្ធនានា បានជួយដោះស្រាយបញ្ហា និងនាំឲ្យមានការយល់ដឹងរួមគ្នា (Kittikhoun and Staubli 2018)។ តាមនេះ ទិដ្ឋភាពយុទ្ធសាស្ត្រក៏អាចកែលំអបាន។ ការសាងសង់ទំនប់ ប៉ាក់បេង លើខ្សែទឹកចម្បងទន្លេមេគង្គ នៅភាគខាងជើងប្រទេសឡាវ នឹងចាប់ផ្តើមនៅឆ្នាំ២០២២ ហើយគ្រោងចប់រួចរាល់នៅឆ្នាំ២០២៩ (NS Energy n.d.)។

### **បញ្ហាប្រឈមនៃការទូតក្នុងការគ្រប់គ្រងទឹករបស់ MRC**

ធនធានទឹកឆ្លងកាត់ព្រំដែនមានការតភ្ជាប់ប្រទេសនានា ដូច្នេះការប្រើប្រាស់និងគ្រប់គ្រងវាឲ្យមានចីរភាព តែងមានបញ្ហាប្រឈម និងឱកាសសម្រាប់ធ្វើសកម្មភាពរួមគ្នា។ ប៉ុន្តែសកម្មភាពបែបនេះតែងមានការរារាំង និងការបង្អាក់ប្រសិទ្ធភាព ដោយសារការគិតគូរនិងផលប្រយោជន៍ខុសៗគ្នានៃក្រុមខុសៗគ្នា។ ជារួម គេតែងយល់ថា ទឹកជាទំនិញខុស្សហកម្មឬសេដ្ឋកិច្ច (នៅទីផ្សារ) ជាទ្រព្យនយោបាយ និងជាសិទ្ធិមនុស្ស (ក្នុងរបបការិយាធិបតេយ្យ) និងជាទ្រព្យវប្បធម៌ (ទ្រព្យទ្រទ្រង់ជីវភាព) (Donahue 1997 cited in Vij, Warner and Barua 2020)។ ដោយសារតួអង្គប្រភេទខុសៗគ្នាមានការវាយតម្លៃខុសៗគ្នាពីផលប្រយោជន៍ និងតម្លៃរបស់ទឹក វាជាការងាយយល់ទៅដែលផលប្រយោជន៍ខុសៗគ្នា និងតម្រូវការប្រជែងគ្នាលើប្រភពទឹករួម អាចបង្កការប៉ះទង្គិចគ្នាលើការប្រើប្រាស់ និងគ្រប់គ្រងទឹក (Vij, Warner and Barua 2020)។ បញ្ហាចម្បងដែលការទូតក្នុងការគ្រប់គ្រងទឹករបស់ MRC ត្រូវប្រឈមមុខ វាផុសចេញពីផលប្រយោជន៍មិនស្របគ្នារវាងបណ្តាប្រទេសតាមដងទន្លេ កង្វះការយល់ដឹងពីគ្នាទៅវិញទៅមក និងភូមិសាស្ត្រនយោបាយដ៏ស្មុគស្មាញនៅក្នុងតំបន់។

### *ផលប្រយោជន៍ខុសគ្នារវាងបណ្តាប្រទេសនៅតាមដងទន្លេ*

"ដោយសារ បណ្តាប្រទេសនៅតាមដងទន្លេឆ្លងកាត់ព្រំដែនមានស្ថានភាពខុសគ្នា ផលប្រយោជន៍និងអត្ថប្រយោជន៍ផ្សេងៗដែលលែចែកទៅឲ្យប្រទេសនៅខ្សែទឹកខាងលើ និងនៅខ្សែទឹកខាងក្រោម វាមានការខុសគ្នា ហើយផលប៉ះពាល់នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធនានាទៅលើបរិស្ថាន និងសង្គម ក៏ខុសគ្នាដែរនៅតាមតំបន់ផ្សេងៗក្នុងអាងទន្លេ" (GIZ 2014, 36)។ នៅតាមដងទន្លេមេគង្គ ចិន ថៃ និងវៀតណាម កំពុងនាំមុខគេក្នុងការសាងសង់ទំនប់ទាំងធំទាំងតូច។ នាបច្ចុប្បន្នមាន ១១ទំនប់ធំៗកំពុងសាងសង់ ឬគ្រោងសាងសង់ នៅតំបន់មេគង្គក្រោម ពោលគឺ មាន ៩នៅឡាវ និង ២នៅកម្ពុជា (Oum and Roath 2020)។

បញ្ហាប្រឈមចម្បង ដែលរារាំងការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយចីរភាពនៅក្នុងតំបន់ គឺលទ្ធភាពដោះស្រាយទំនាស់ "រវាងយុទ្ធសាស្ត្រប្រើប្រាស់ទឹកតាមវិស័យផ្សេងៗ រវាងការរស់នៅតាមមូលដ្ឋាននឹងគោលដៅអភិវឌ្ឍន៍របស់ប្រទេសជាតិ និងរវាងបណ្តារដ្ឋនៅតាមដងទន្លេ ដែលមានគោលដៅអភិវឌ្ឍន៍ខុសៗគ្នា" (GIZ 2014, 49)។ ទំនប់ សាយបូរី ជាករណីទី១ ដែលមានការពិគ្រោះយោបល់ជាមុន ស្របតាមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥។ ប៉ុន្តែឡាវមិនបានសហការជាមួយប្រទេសជិតខាងទេ គឺបានចាប់ផ្តើមសាងសង់ទំនប់នេះ ទោះបីកម្ពុជា និងវៀតណាម បានប្រកាសនូវក្តីបារម្ភពី ផលប៉ះពាល់ដែលអាចកើតមានឆ្លងកាត់ព្រំដែន។ សេចក្តីសម្រេចរបស់ថៃ មានការយឺតយ៉ាវដោយសារទំនាស់ផលប្រយោជន៍រវាងក្រសួងថាមពលដែលគាំទ្រគម្រោងជាមួយនឹង ក្រសួងធនធានធម្មជាតិនិងបរិស្ថានដែលនៅមានមន្ទិលសង្ស័យមួយចំនួន (Middleton and Pritchard 2016)។ ប៉ុន្តែក្រោយមកទៀត ថៃបាន "ផ្តល់ទុនដោយស្ងាត់ៗដល់គម្រោងនេះ និងព្រមព្រៀងទិញយកថាមពលអគ្គិសនី" (Herbertson 2013, 3)។ វិធីនេះបង្ហាញពី កង្វះសហប្រតិបត្តិការជាយុទ្ធសាស្ត្រ និងជាចំណុចមួយដែល MRC គួរធ្វើអន្តរាគមន៍ជួយស្វែងរកដំណោះស្រាយដែលមានផលប្រយោជន៍ទៅវិញទៅមក និងជួយទប់ស្កាត់ទំនាស់ទៅអនាគត។

### *កង្វះការយល់ដឹងពីគ្នាទៅវិញទៅមក*

អន្តរកម្មទាក់ទងនឹងទឹកឆ្លងកាត់ព្រំដែន តែងផ្សារភ្ជាប់ជានិច្ចជាមួយនយោបាយ ដូច្នេះហើយតែងកំណត់មួយភាគធំ ដោយបរិបទធំទូលាយផ្នែកសង្គម-នយោបាយ របស់បណ្តាប្រទេសតាមដងទន្លេ (Mirumachi 2015 cited in Barua et al. 2018) ។ ក្របខ័ណ្ឌស្ថាប័នថ្នាក់តំបន់ផ្សេងៗសម្រាប់សហប្រតិបត្តិការ ដូចជា MRC មហាអនុតំបន់មេគង្គ សហប្រតិបត្តិការមេគង្គ-ឡានឆាង ជាដើម ត្រូវបានបង្កើតឡើងសម្រាប់ ការគ្រប់គ្រងទន្លេឆ្លងកាត់ព្រំដែនឲ្យមានចីរភាព។ ទោះយ៉ាងនេះក្តី ក៏ពុំមានសេចក្តីចែងណាមួយដែលកំណត់ថា ប្រទេសសមាជិកទាំងអស់ត្រូវទទួលបានការព្រមព្រៀង មុននឹង ធ្វើផែនការ អនុម័តយក ឬសាងសង់ទំនប់។ មាត្រា៤ នៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ ចែងថា ប្រទេសនីមួយៗរក្សាបានជានិច្ចនូវ "សមភាពពេញលេញ និងបូរណភាពដែនដី" ក្នុងសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីចែងនេះមានន័យថា ពុំមានកាតព្វកិច្ចតាមផ្លូវច្បាប់អ្វីឡើយក្នុងការកសាងបទបញ្ញត្តិសម្រាប់គ្រប់គ្រងអ្នកអភិវឌ្ឍទំនប់ និងក្នុងការជៀសវាងគ្រោះថ្នាក់ធ្ងន់ធ្ងរនៃការបាក់ទំនប់។

ស្ថានភាពធ្ងន់ធ្ងរនេះ បាននាំឲ្យមានទំនាស់ឆ្លងកាត់ព្រំដែនជាច្រើន រវាងអ្នកអភិវឌ្ឍន៍ទំនប់ចម្រុះរដ្ឋ-ឯកជន ជាមួយនឹងប្រជាជន និងរដ្ឋាភិបាលបណ្តាប្រទេសនៅខ្សែទឹកខាងក្រោម ដែលទំនងទទួលរងគ្រោះ (Oum and Reath 2020)។ សម្រាប់ករណីទំនប់សាយប្ញូរី នៅឡាវ យោងតាមសេចក្តីណែនាំលើការអនុវត្តនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (MRC 2005) ប្រទេសសមាជិកមានសិទ្ធិពង្រីករយៈពេលនៃការពិគ្រោះយោបល់ជាមុន (៦ខែ ប្រសិនបើគ្មានសេចក្តីចែងច្បាស់)។ ប៉ុន្តែនៅពេលមានសំណើ ឡាវមិនបានពង្រីករយៈពេលពិគ្រោះយោបល់ទេ (Kittikhoun and Staubli 2018)។ តាមការចាប់ផ្តើមការងារលើទំនប់ សាយប្ញូរី មុនពេលប្រទេសសមាជិកឯទៀត មានលទ្ធភាពធ្វើសេចក្តីសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ គឺឡាវបានធ្វើឲ្យខូចខាតដល់គោលដៅចម្បងនៃការពិគ្រោះយោបល់ជាមុន និងបានបំពានលើកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ (Herbertson 2013)។ បញ្ហានេះត្រូវមានការពិនិត្យតាមផ្លូវច្បាប់ពីសំណាក់ក្រុមប្រឹក្សា MRC និងគួរមានការពិនិត្យឡើងវិញយ៉ាងប្រុងប្រយ័ត្ននូវ ពាក្យពេចន៍ និងលក្ខខណ្ឌផ្សេងៗនៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥។

### *បញ្ហាភូមិសាស្ត្រនយោបាយរវាងមហាអំណាចខាងក្រៅ*

បញ្ហាភូមិសាស្ត្រនយោបាយលើអាងទន្លេមេគង្គ ក៏មិនខុសគ្នាអ្វីពីបញ្ហាផុសចេញពី ការប្រកួតប្រជែងដណ្តើមឥទ្ធិពលរវាងមហាអំណាច លើធនធានធម្មជាតិផ្សេងៗ ក្នុងពិភពលោកដែរ (Kittikhoun and Staubli 2018)។ ការអភិវឌ្ឍវារីអគ្គិសនីជាកម្លាំងជំរុញសំខាន់មួយនៃ និន្នាការយុទ្ធសាស្ត្រផ្សេងៗបែបនេះ នៅតំបន់មេគង្គ។ ឧទាហរណ៍ ចិនកំពុងពង្រឹងអំណាចនិងឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់ ដើម្បីអភិវឌ្ឍតំបន់មួយចំនួនតាមដងទន្លេមេគង្គ ឲ្យទៅជាតំបន់សេដ្ឋកិច្ចពិសេស។ ដូច្នេះជាការសមហេតុផលដែរដែលមហាអំណាចឯទៀតមានការបារម្ភពី បំណងប្រាថ្នារបស់ចិនលើទន្លេមេគង្គ ដែលត្រូវបានជំរុញឡើងក្រោមពាក្យស្លោក "ទន្លេរួមគ្នា អនាគតរួមគ្នា" (Oum and Reath 2020)។

បំណងពង្រឹងអនុត្តរភាព និងកំណើនឥទ្ធិពលរបស់ចិនក្នុងតំបន់មេគង្គ គួបផ្សំជាមួយចំណុចខ្វះខាតក្នុងគោលនយោបាយរបស់សហរដ្ឋអាមេរិក បាននាំឲ្យមានចន្លោះប្រហោងមួយផ្នែកនយោបាយ។ សហរដ្ឋអាមេរិកបានព្យាយាមត្រឡប់មកតំបន់នេះវិញដូចមានចែងក្នុង យុទ្ធសាស្ត្រស្នូលរបស់រដ្ឋការអូបាម៉ាសម្រាប់អាស៊ី (Obama administration’s Strategic Pivot to Asia) ដែលក្នុងនោះ សហរដ្ឋអាមេរិកបានចាប់អនុវត្ត គំនិតផ្តួចផ្តើមមេគង្គក្រោម ជាមួយបួនប្រទេសនៅតំបន់មេគង្គ (គឺក្រៅពីមីយ៉ាន់ម៉ា និងចិន ) (Oum and Reath 2020)។ ទំនាក់ទំនងរបស់ចិនជាមួយរដ្ឋទន់ខ្សោយជាងខ្លួននៅតំបន់ខ្សែទឹកខាងក្រោម បង្ហាញពីកម្លាំងអំណាចមិនស្មើគ្នា ពីព្រោះចិនមានឥទ្ធិពលខ្លាំងលើកិច្ចសន្ទនាជាទ្វេភាគី និងពហុភាគី នៅអាស៊ីអាគ្នេយ៍ និងដឹកនាំសហប្រតិបត្តិការមេគង្គ-ឡានឆាង និងគំនិតផ្តួចផ្តើមខ្សែក្រវាត់មួយផ្លូវមួយ (Middleton and Devlaeminck 2020)។

ចិនក៏បង្កើនឥទ្ធិពលគួរឲ្យកត់សំគាល់ទៅលើ ប្រទេសមួយចំនួន ដូចជា វៀតណាម ជាដើម ទាក់ទិននឹងវិវាទដែនសមុទ្រអន្តរជាតិ នៅសមុទ្រចិនខាងត្បូងដែរ (Global Conflict Tracker 2020)។ ជប៉ុនដែលជាមហាអំណាចថ្នាក់កណ្តាល ក៏អាចគិតថាកម្លាំងគ្របដណ្តប់របស់ចិននៅក្នុងតំបន់ គឺជាការគម្រាមកំហែងមួយដែរ។ ជាឧទាហរណ៍ ជប៉ុនបានលើកទឹកចិត្តជំហរតំបន់និយមដោយជំរុញប្រទេសទាំងប្រាំក្នុងមហាអនុតំបន់មេគង្គ ឲ្យបង្កើតកិច្ចសន្ទនាផ្នែកសន្តិសុខពហុភាគីមួយ ដើម្បីប្រឆាំងនឹងការទាមទារផ្សេងៗរបស់ចិននៅសមុទ្រចិនខាងត្បូង (Oum and Reath 2020)។ ក្នុងនេះ ក្រុមប្រឹក្សា MRC អាចជួយជំរុញឲ្យមានសហប្រតិបត្តិការយុទ្ធសាស្ត្រពហុភាគីកាន់តែប្រសើរ និងឲ្យចិនបានចូលរួមកាន់តែពេញលេញក្នុងកិច្ចសន្ទនាផ្សេងៗ ដើម្បីឲ្យចិនបានដឹងពីភាពបង្កទំនាស់នៃការគ្របដណ្តប់អំណាចរបស់ខ្លួននៅក្នុងតំបន់។

### **សេចក្តីសន្និដ្ឋាន**

ក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក មានធាតុផ្សំសំខាន់ៗបីពោលគឺផ្នែកច្បាប់ ស្ថាប័ន និងយុទ្ធសាស្ត្រ។ ធាតុផ្សំនីមួយៗដើរតួនាទីក្នុងការជួយគាំទ្រ និងបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក ដើម្បីសម្រេចគោលដៅចម្បង ពោលគឺ ការទូតក្នុងការគ្រប់គ្រងទឹកបានកាន់តែល្អ។ ក្រុមប្រឹក្សា MRC មានភារកិច្ចអនុម័តផែនការយុទ្ធសាស្ត្រ MRC និងធ្វើសេចក្តីសម្រេចលើរាល់បញ្ហាជាប់ទាក់ទិននឹងគោលនយោបាយស្តីពីទន្លេមេគង្គ។ អនុគណៈកម្មាធិការនៃក្រុមប្រឹក្សា MRC រួមមាន គណៈកម្មាធិការរួមគ្នានៃ MRC និងលេខាធិការដ្ឋាន MRC ។

ដើម្បីអនុវត្តគម្រោងវារីអគ្គិសនីអ្វីមួយលើទន្លេមេគង្គ ប្រទេសសមាជិកត្រូវដាក់សំណើមួយឡើង សម្រាប់ដំណើរការពិគ្រោះយោបល់ជាមុនដែលមានធាតុផ្សំទាំងបីនៃ ក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក។ គម្រោង សាយប្ញូរី ដនសាហុង និងប៉ាក់បេងសុទ្ធតែបានឆ្លងកាត់ដំណើរការពិគ្រោះយោបល់ជាមុន ថ្វីបើឡាវបានចាប់ផ្តើមសាងសង់ទំនប់ សាយប្ញូរី មុនពេលការពិគ្រោះ

យោបល់បានចប់សព្វគ្រប់ក្តី។ គម្រោងទាំងអស់នេះ មានការទិតៀន និងជួបឧបសគ្គទាក់ទិននឹងផលប៉ះពាល់លើបរិស្ថាន ប៉ុន្តែនៅចុងបញ្ចប់អាចទៅមុខបាន ក្រោយពេលមានការវាយតម្លៃយ៉ាងម៉ត់ចត់។ បទពិសោធន៍ចម្បងគេ ដែលរៀនសូត្របានពីគម្រោងទាំងបី គឺការយកចិត្តទុកដាក់លើទិដ្ឋភាពបច្ចេកទេសតែមួយមុខវាមិនគ្រប់គ្រាន់ទេ នៅពេលអនុវត្តគម្រោងខ្នាតធំលើទន្លេមេគង្គ ពីព្រោះទិដ្ឋភាព រៀបចំអង្គការ ស្ថាប័ន និងយុទ្ធសាស្ត្រ ក៏ដូចជា ការចូលរួមសព្វគ្រប់ពីសំណាក់ភាគីពាក់ព័ន្ធនានា ក៏សំខាន់ដូចគ្នាដែរ។

បញ្ហាប្រឈមដែលរារាំង MRC ក្នុងការអនុវត្តក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹករបស់ខ្លួន រួមមាន ទំនាស់ផលប្រយោជន៍រវាងបណ្តាប្រទេសតាមដងទន្លេ កង្វះការយល់ដឹងពីគ្នាទៅវិញទៅមក និង កម្លាំងជំរុញផ្សេងៗផ្អែកភូមិសាស្ត្រនយោបាយដ៏ស្មុគស្មាញ និងយុទ្ធសាស្ត្រ នៅក្នុងតំបន់។

ផ្អែកលើបញ្ហា និងភាពប្រឈមផ្សេងៗដូចខាងលើ ប្រទេសសមាជិក MRC គួរពិចារណាលើការជូនមតិដូចតទៅ៖

- គួរដាក់បញ្ចូលទិដ្ឋភាពទាំងបី (ផ្អែកច្បាប់ ស្ថាប័ន និងយុទ្ធសាស្ត្រ) នៃក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក នៅក្នុងគម្រោងសាងសង់ទំនប់ និងគម្រោងអភិវឌ្ឍន៍ធនធានទឹកផ្សេងៗទៀត។
- គួរលើកកម្ពស់ការចូលរួមរបស់សាធារណជន នៅដំណាក់កាលខាងដើមនៃការធ្វើផែនការគម្រោង ដើម្បីបំផុសគំនិតថ្មីៗ កាត់បន្ថយឧបសគ្គ និងទប់ស្កាត់ទំនាស់។
- គួរលើកទឹកចិត្តឲ្យមាន ការពិភាក្សាផ្អែកបច្ចេកទេសកាន់តែច្រើន និងកិច្ចសន្ទនាកាន់តែស៊ីជម្រៅ រវាងប្រទេសតាមដងទន្លេ ដើម្បីរកឲ្យឃើញផលប្រយោជន៍ទៅវិញទៅមក និងគោលដៅរួមគ្នា។
- គួរលើកកម្ពស់ការយល់ដឹងពីពាក្យពេចន៍ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ ឲ្យបានប្រសើរជាងមុនសម្រាប់ការអនុវត្តគម្រោងក្នុងតំបន់មេគង្គ។
- គួរជំរុញការឈានទៅមុខច្បាស់លាស់ ទៅកាន់របៀបរបបអនុវត្តផ្អែកលើវិធានមានយុត្តិធម៌ សម្រាប់ប្រទេសទាំង៦ដែលនៅជាប់ទន្លេមេគង្គ-ឡានឆាង។

## សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះ ជាចំណែកមួយនៃគម្រោងស្រាវជ្រាវរយៈពេលពីរឆ្នាំរបស់ CDRI ស្តីពី ការទូតក្នុងការគ្រប់គ្រងទឹកនៅអាងទន្លេមេគង្គ ដើម្បីឲ្យមានការប្រើប្រាស់អាងទន្លេជារួម និងសម្រេចបាននូវភាពរុងរឿង ដែលមូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង (MLC) ផ្តល់មូលនិធិឲ្យ តាមរយៈ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិនៃ ព្រះរាជាណាចក្រកម្ពុជា (MoFAIC)។

## ឯកសារយោង

Barua, Anamika, Sumit Vij and Mirza Zulfiqur Rahman. 2018. "Powering or Sharing Water in the Brahmaputra River Basin." *International Journal of Water Resources Development* 34 (5): 829–843. doi.org/10.1080/07900627.2017.1403892.

Cambodia National Mekong Committee. 2015. "Procedures for Notification, Prior Consultation and Agreement Form/ Format for Reply to Prior Consultation." Don Sahong Hydropower Project. Vientiane: Mekong River Commision.

FAO (Food and Agriculture Organisation). 2011. *AQUASTAT Transboundary River Basin Overview – Mekong*. Rome: FAO. www.fao.org/3/ca2135en/CA2135EN.pdf.

GIZ. 2014. *Training Manual: Transboundary Cooperation and Hydropower Development*. www.giz.de/en/downloads/ giz2014-en-transboundary-cooperation-hydropower-mekong.pdf.

Global Conflict Tracker. 2020. "Territorial Disputes in the South China Sea." www.cfr.org/global-conflict-tracker/ conflict/territorial-disputes-south-china-sea.

Herbertson, K. 2013. "Xayaburi Dam: How Laos Violated the 1995 Mekong Agreement." *International Rivers.*

Kittikhoun, Anoulak, and Denise Michèle Staubli. 2018. "Water Diplomacy and Conflict Management in the Mekong: From Rivalries to Cooperation." *Journal of Hydrology* 567: 654–667. doi.org/10.1016/j. jhydrol.2018.09.059.

Middleton, Carl, and David J. Devlaeminck. 2020. "Reciprocity in Practice: The Hydropolitics of Equitable and Reasonable Utilization in the Lancang-Mekong Basin." *Int Environ Agreements*. doi.org/10.1007/s10784-020-09511-6.

Middleton, Carl, and Ashley Pritchard. 2016. "Arenas of Water Justice on Transboundary Rivers: A Case Study of the Xayaburi Dam, Laos." In *Water Governance Dynamics in the Mekong Region Strategic,* edited by David J. H. Blake and Lisa Robins, 59–90. Petaling Jaya, Selangor, Malaysia: Strategic Information and Research Development Centre.

MRC (Mekong River Commission). 2005. *Guidelines on Implementation of the Procedures for Notification, Prior Consultation and Agreement.* www.mrcmekong.org/assets/ Publications/p olicies/Guidelines-on-implementation-of-the-PNPCA.pdf.

MRC. 2016. 'Regional Workshop on Water Diplomacy in the Mekong Basin: Final Report." Vientiane, Laos., 29–30 Nov 2016. https://waterandchange.org/wp-content/uploads/20 17/02/Workshop-WaterDiplomacy-Mekong-2016.pdf.

MRC. 2018. *An Introduction to MRC Procedural Rules for Mekong Water Cooperation*. www. mrcmekong.org/assets/ Publications/MRC-procedures-EN-V.7-JUL-18.pdf.

NS Energy. n.d. "Pak Beng Hydropower Project".www. nsenergybusiness.com/projects/pak-beng-hydropower-project/#:~:text=The%20construction%20of%20the%20 hydro,water %20length %20will%20be%2097km.

Oum Socheat and Roath Sovanndanit. 2020. *Cambodia-Mekong Water Diplomacy*. www. researchgate.net/ publication/340477971_Cambodia-Mekong_Water_ Diplomacy.

Vij, Sumit, Jereon Warner and Anamika Barua. 2020. "Power in Water Diplomacy." *Water International* 45: 249–253. doi.org/10.1080/02508060.2020.1778833.

Warner, Jereon, Naho Mirumachi, Rebecca L. Farnum, Mattia Grandi, Filippo Menga and Mark Zeitoun. 2017. "Transboundary 'Hydro-Hegemony': 10 Years Later." *WIREs Water* 4 (6): e1242. doi.org/10.1002/wat2.1242.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះបង្ហាញពី សូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី៣ ឆ្នាំ២០២០។ នៅពេលចងក្រងអត្ថបទនេះ ទិន្នន័យលើ កំណើន ផសស ពិតនៅកម្ពុជា មិនទាន់មាននៅឡើយទេ។

## កំណើន ផសស ពិត

គេអាចមើលឃើញភ្លាមថា នៅត្រីមាសទី៣ នេះ ប្រទេសជ្រើសរើសទាំងអស់ កំពុងស្ថិតលើផ្លូវងើបសេដ្ឋកិច្ចឡើងវិញ។ ក្រោយមានការរួមចុះខ្លាំងបំផុតនៅត្រីមាសមុននេះ គ្រប់ប្រទេសអាស៊ានជ្រើសរើស បានងើបឡើងវិញតាមល្បឿនខុសៗគ្នា ប៉ុន្តែនៅមានកំណើន ផសស ពិត ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន។ ម៉ាឡេស៊ីដែលមានការរួមចុះខ្លាំងជាងគេ រហូតដល់ -១៧,១% នៅត្រីមាសមុន បានងើបឡើងវិញលឿនជាងគេបាន ១៤,៤ ឯកតាភាគរយ ដល់កម្រិត -២,៧% (ឬ -៧,១ ឯកតាភាគរយ ទាបជាងត្រីមាសទី៣ ឆ្នាំមុន) ដែលធ្វើឲ្យម៉ាឡេស៊ីមានអត្រារួមចុះទាបជាងគេលំដាប់ទី២ នៅត្រីមាសទី៣ នេះ ពោលគឺ បន្ទាប់ពីវៀតណាម ដែលជាប្រទេសតែមួយក្នុងក្រុមនេះដែលមិនធ្លាប់មានអត្រាកំណើនអវិជ្ជមានម្ដងណាសោះ ក្នុងមួយរយៈពេលចុងក្រោយ។ ទោះយ៉ាងនេះក្ដី វៀតណាមក៏មានអត្រាកំណើន ផសស ចុះទាបបំផុតដល់ត្រឹម ០,៤% នៅត្រីមាសមុនដែរ ប៉ុន្តែបានងើបឡើងវិញ ១,៩ឯកតាភាគរយ ដល់ ២,៣% និងជាប្រទេសតែមួយក្នុងក្រុមនេះ ដែលមានអត្រាកំណើនវិជ្ជមាននៅត្រីមាសទី៣។ សិង្ហបុរីដែលមានអត្រារួមចុះខ្លាំងបំផុតលំដាប់ទី២ (-១៣,២%) នៅត្រីមាសទី២ បានងើបឡើងវិញ ៧,៤ឯកតាភាគរយ ដល់ -៥,៨% នៅត្រីមាសទី៣។ ថៃមានអត្រារួមចុះខ្លាំងជាងគេ ដល់ -៦,៤% នៅត្រីមាសទី៣។ ឥណ្ឌូនេស៊ីមានអត្រារួមចុះសេដ្ឋកិច្ចខ្លាំងបំផុតនៅត្រីមាសទី២ ដល់ -៥,៣% ប៉ុន្តែងើបឡើងវិញបាន ១,៨ ឯកតាភាគរយនៅត្រីមាសទី៣ ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស ចិន និងតៃវ៉ាន់ សម្រេចបានកំណើន ផសស រីឯ ហុងកុង និង កូរ៉េខាងត្បូង នៅតែមានការរួមចុះសេដ្ឋកិច្ច នៅត្រីមាសទី៣ នេះ។ ចិនមាន ផសស កើន ៤,៩% ឬ ១,៧ ឯកតាភាគរយខ្ពស់ជាងត្រីមាសមុន ប៉ុន្តែ ១,១ ឯកតាភាគរយ ទាបជាងត្រីមាសដូចគ្នាឆ្នាំ២០១៩។ តៃវ៉ាន់ ដែលមានការរួមចុះ ផសស ដល់ ០,៦% នៅត្រីមាសមុនបានងើបឡើងវិញ ៤,៥ ឯកតាភាគរយរហូតដល់មានអត្រាកំណើន ៣,៩% នៅត្រីមាសទី៣។ ហុងកុងមានការរួមចុះខ្លាំងជាងគេក្នុងក្រុមនេះ រហូតដល់ -៩,០% នៅត្រីមាសទី២ ប៉ុន្តែងើបឡើងវិញបាន ៥,៥ ឯកតាភាគរយ ដល់ -៣,៥% នៅត្រីមាសទី៣។ កូរ៉េខាងត្បូងងើបឡើងវិញបាន ១,៩ ឯកតាភាគរយធៀបនឹងត្រីមាសមុន ប៉ុន្តែនៅមានការរួមចុះ ដល់ -១,១% នៅត្រីមាសនេះ។

ក្នុងចំណោមប្រទេសឧស្សាហកម្មជ្រើសរើស តំបន់អឺរ៉ូ១២ ងើបសេដ្ឋកិច្ចឡើងវិញខ្លាំងជាងគេបាន ១០,៤ឯកតាភាគរយ ដោយបានកាត់បន្ថយអត្រារួមចុះពីកម្រិតខ្ពស់បំផុត ដល់ -១៤,៧% នៅត្រីមាសមុនមកត្រឹម -៤,៣%ដែលជាការរួមចុះខ្លាំងជាងគេលំដាប់ទី២ បន្ទាប់ពីជប៉ុន (-៥,៧%) ក្នុងក្រុមនេះ នៅត្រីមាសទី៣។ ថ្វីបើងើបឡើងវិញបាន ៤,២ឯកតាភាគរយ ធៀបនឹងត្រីមាសមុនក្ដី ប៉ុន្តែ ផសស ជប៉ុននៅតែមានកម្រិត ៧,៤% ទាបជាងត្រីមាសដូចគ្នាឆ្នាំមុនដែរ។ ផសស សហរដ្ឋអាមេរិក មានអត្រារួមចុះទាបបំផុត គិតតាំងពីត្រីមាសទី១ ឆ្នាំ២០២០ មក ដោយងើបឡើងវិញបាន ៦,៧ ឯកតាភាគរយធៀបនឹងត្រីមាសមុន រហូតដល់ -២,៨% នៅត្រីមាសទី៣នេះ ដែលនៅទាបជាងត្រីមាសដូចគ្នាឆ្នាំមុន ៤,៩ ឯកតាភាគរយ។

## អត្រាអតិផរណា

ក្នុងចំណោម ៦ប្រទេសអាស៊ាន ប្រទេស កម្ពុជា ឥណ្ឌូនេស៊ី និងវៀតណាម មានអត្រាអតិផរណា ២,៨% ១,៤% និង ៣,២% រៀងគ្នា រីឯប្រទេសបីទៀតមានអត្រាបរិត្តផរណា។ ម៉ាឡេស៊ីមានអត្រាបរិត្តផរណាខ្ពស់ជាងគេ (-១,៤%) បន្ទាប់មកគឺ ថៃ (-០,៨%) និងសិង្ហបុរី (-០,៣%)។ បើពិនិត្យពីការប្រែប្រួលធៀបនឹងត្រីមាសមុនវិញ មានតែនៅឥណ្ឌូនេស៊ីមួយទេ ដែលអតិផរណាបានថយចុះអស់ ០,៩ ឯកតាភាគរយ រីឯនៅកម្ពុជាវិញវាបានកើន ០,៣ឯកតាភាគរយ, នៅម៉ាឡេស៊ីកើន ១,២ ឯកតាភាគរយ, នៅសិង្ហបុរីកើន ០,៤ ឯកតាភាគរយ, នៅថៃកើន ១,៩ ឯកតាភាគរយ, និង នៅវៀតណាមកើន ០,៤ ឯកតាភាគរយ។

ក្នុងមួយរយៈពេលនេះ ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស មានតែប្រទេសចិនមួយទេដែលមិនមានបរិត្តផរណា និងមានអតិផរណា ២,៣% នៅត្រីមាសទី៣ នេះ ពោលគឺ ០,៤ ឯកតាភាគរយ ទាបជាងត្រីមាសមុន និង ០,៦ ឯកតាភាគរយ ទាបជាងត្រីមាសដូចគ្នាឆ្នាំមុន។ ហុងកុងបានជួបបរិត្តផរណាជាលើកទី១ ត្រឹម -០,៩% នៅត្រីមាសនេះ ហើយអត្រានេះ ទាបជាងត្រីមាសមុន ២,២ ឯកតាភាគរយ និងទាបជាងត្រីមាសដូចគ្នាឆ្នាំមុន ៤,៣ឯកតាភាគរយ។ កូរ៉េខាងត្បូងមានបរិត្តផរណា នៅត្រីមាសមុនត្រឹម -០,១% ដែលបានក្លាយជាអតិផរណា ០,៧% នៅត្រីមាសទី៣ ហើយអត្រានេះ ខ្ពស់ជាងត្រីមាសមុន ០,៨ ឯកតាភាគរយ និងខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំមុន ០,៦ ឯកតាភាគរយ។

ក្នុងមួយរយៈពេលនេះដែរ នៅតាមប្រទេសឧស្សាហកម្មជ្រើសរើសអត្រាអតិផរណាមានការឡើងចុះប៉ុន្តែនៅជប៉ុនវាប្រែប្រួលនៅក្បែរៗកម្រិតសូន្យ បន្ទាប់ពីមានបរិត្តផរណាមួយរយៈពេលខ្លីត្រឹម -០,១% ក្នុងឆ្នាំ២០១៦។ នៅត្រីមាសទី៣ ឆ្នាំ២០២០ អតិផរណាមានអត្រាសូន្យនៅតំបន់អឺរ៉ូ១២, មានអត្រា ០,២% នៅជប៉ុន និង ១,២% នៅសហរដ្ឋអាមេរិក។ ធៀបនឹងត្រីមាសមុន អត្រាអតិផរណាធ្លាក់ចុះ ០,៣ឯកតាភាគរយនៅតំបន់អឺរ៉ូ១២ ប៉ុន្តែកើន ០,១ឯកតាភាគរយនៅជប៉ុន និងកើន ០,៩ ឯកតាភាគរយនៅសហរដ្ឋអាមេរិក។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណាក្នុងប្រទេសទាំងនេះបានធ្លាក់ចុះ ពោលគឺ នៅតំបន់អឺរ៉ូវាធ្លាក់ចុះ

---

អត្ថបទនេះ រៀបរៀងដោយ រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

១,០ ឯកតាភាគរយ នៅជប៉ុនធ្លាក់ចុះ ០,១ ឯកតាភាគរយ នៅសហរដ្ឋអាមេរិកធ្លាក់ចុះ ០,៥ ឯកតាភាគរយ។

## អត្រាប្តូរប្រាក់

សម្រាប់រូបិយវត្ថុនៃបណ្តាប្រទេសជ្រើសរើស បើធៀបនឹងត្រីមាសមុន និងទល់នឹងប្រាក់ដុល្លារអាមេរិក ប្រាក់រៀលកម្ពុជាចុះថ្លៃ ០,១% ហើយដុល្លារសិង្ហបុរី ដុល្លារហុងកុង និងប្រាក់អឺរ៉ូនៅថេរ ត្រឹម ១,៤ ដុល្លារសិង្ហបុរី/ដុល្លារអាមេរិក, ៧,៨ ដុល្លារហុងកុង/ដុល្លារអាមេរិក និង ០,៩ អឺរ៉ូ/ដុល្លារអាមេរិក ប៉ុន្តែ ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ីឡើងថ្លៃ ១,៧% ប្រាក់រីងហ្គីតម៉ាឡេស៊ីឡើងថ្លៃ ២,៣% ប្រាក់បាតថៃឡើងថ្លៃ ០,២% ប្រាក់ដុងវៀតណាមឡើងថ្លៃ ០,២% ប្រាក់យ័នចិនឡើងថ្លៃ ២,៨% ប្រាក់វ៉ុនកូរ៉េខាងត្បូងឡើងថ្លៃ ២,៦% ដុល្លារតៃវ៉ាន់ឡើងថ្លៃ ២,០% ប្រាក់យ៉េនជប៉ុនឡើងថ្លៃ ១,៣%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន មានតែអង្ករ និងសណ្តែកសៀង ប៉ុណ្ណោះដែលបានឡើងថ្លៃ រីឯ កៅស៊ូ ប្រេងឆៅ សាំង និង ម៉ាស៊ូត បានចុះថ្លៃ។ អង្ករឡើងថ្លៃ ១៦,៧% ធៀបនឹងកាលពីមួយឆ្នាំមុន ប៉ុន្តែចុះថ្លៃ ៦,២% ធៀបនឹងត្រីមាសមុនដែលនៅពេលនោះវាបានឡើងថ្លៃខ្ពស់បំផុតដល់ ៥៤៧,៥ដុល្លារ/តោន។ សណ្តែកសៀងឡើងថ្លៃ ១១,៧% ធៀបនឹងកាលពីមួយឆ្នាំមុន និងឡើងថ្លៃ ៨,៦% ធៀបនឹងត្រីមាសមុន។ កៅស៊ូ ប្រេងឆៅ សាំង និង ម៉ាស៊ូត បានចុះថ្លៃ ៥,៣% ២៩,០% ៣១,៣% និង ៣៧,៦% រៀងគ្នា ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០១៩ ប៉ុន្តែទំនិញទាំងអស់នេះបានឡើងថ្លៃធៀបនឹងត្រីមាសមុន ពោលគឺ កៅស៊ូឡើងថ្លៃ ១៥,០% ប្រេងឆៅឡើងថ្លៃ ៣៩,៩% សាំងឡើងថ្លៃ ៤៥,០% ម៉ាស៊ូតឡើងថ្លៃ ២៧,១%។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.1 | 7.0 | 7.0 | 7.0 | 7.5 | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.2 | 4.8 | 5.0 | 5.1 | 5.2 | 5.1 | 5.0 | 5.0 | 5.0 | 3.0 | -5.3 | -3.5 |
| ម៉ាឡេស៊ី | 6.0 | 4.9 | 4.3 | 5.9 | 4.8 | 4.5 | 4.9 | 4.4 | 3.6 | 0.7 | -17.1 | -2.7 |
| សិង្ហបុរី | 3.0 | 2.0 | 2.0 | 3.8 | 3.2 | 1.3 | 0.1 | 0.5 | 0.8 | -2.2 | -13.2 | -5.8 |
| ថៃ | 1.6 | 2.8 | 3.2 | 3.8 | 4.1 | 2.8 | 2.3 | 2.4 | 1.6 | -1.8 | -12.2 | -6.4 |
| វៀតណាម | 5.9 | 6.6 | 6.1 | 6.6 | 7.2 | 6.8 | 6.7 | 7.3 | 7.0 | 3.8 | 0.4 | 2.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.3 | 7.0 | 6.7 | 6.9 | 6.6 | 6.4 | 6.2 | 6.0 | 6.0 | -6.8 | 3.2 | 4.9 |
| ហុងកុង | 2.3 | 2.3 | 1.7 | 2.8 | 3.1 | 0.6 | 0.5 | 2.9 | -2.9 | -8.9 | -9.0 | -3.5 |
| កូរ៉េខាងត្បូង | 3.4 | 2.6 | 2.6 | 3.0 | 3.0 | 1.8 | 2.1 | 2.0 | 3.4 | 1.3 | -3.0 | -1.1 |
| តៃវ៉ាន់ | 3.5 | 0.6 | 1.2 | 2.8 | 2.6 | 1.7 | 2.4 | 3.0 | 3.3 | 1.5 | -0.6 | 3.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.7 | 1.3 | 1.6 | 2.3 | 1.9 | 1.2 | 1.1 | 1.2 | 1.0 | -3.3 | -14.7 | -4.3 |
| ជប៉ុន | 0.6 | 0.3 | 0.9 | 1.8 | 0.6 | 0.9 | 1.2 | 1.7 | -0.7 | -2.0 | -9.9 | -5.7 |
| សហរដ្ឋអាមេរិក | 2.4 | 2.3 | 1.6 | 2.3 | 3.0 | 3.2 | 2.3 | 2.1 | 2.3 | 0.3 | -9.5 | -2.8 |

Sources: International Monetary Fund; *Economist*; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.9 | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.1 | 3.0 | 2.5 | 2.8 |
| ឥណ្ឌូនេស៊ី | 6.4 | 6.4 | 3.5 | 3.8 | 3.2 | 2.6 | 3.1 | 3.4 | 2.9 | 2.9 | 2.3 | 1.4 |
| ម៉ាឡេស៊ី | 3.2 | 2.1 | 2.1 | 3.9 | 1.0 | -0.3 | 0.6 | 1.3 | 1.0 | 0.9 | -2.6 | -1.4 |
| សិង្ហបុរី | 1.0 | -0.5 | -0.8 | 0.6 | 0.4 | 0.5 | 0.8 | 0.5 | 0.6 | 0.4 | -0.7 | -0.3 |
| ថៃ | 1.9 | -0.9 | 0.2 | 0.7 | 1.1 | 0.7 | 1.1 | 0.6 | 0.4 | 0.4 | -2.7 | -0.8 |
| វៀតណាម | 4.8 | 0.6 | 2.7 | 3.4 | 3.6 | 2.6 | 2.7 | 2.2 | 3.7 | 5.6 | 2.8 | 3.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.0 | 1.4 | 2.0 | 1.6 | 2.1 | 1.8 | 2.6 | 2.9 | 4.3 | 4.4 | 2.7 | 2.3 |
| ហុងកុង | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.2 | 2.7 | 3.4 | 3.0 | 2.0 | 1.3 | -0.9 |
| កូរ៉េខាងត្បូង | 1.3 | 0.7 | 0.8 | 2.0 | 1.4 | 0.6 | 0.7 | 0.1 | 0.3 | 1.2 | -0.1 | 0.7 |
| តៃវ៉ាន់ | 1.5 | 0.6 | 1.4 | 0.6 | 1.4 | 0.3 | 0.8 | 0.4 | 0.7 | 0.6 | -1.0 | -0.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.4 | 0.0 | 0.3 | 1.5 | 1.8 | 1.4 | 1.4 | 1.0 | 1.0 | 1.1 | 0.3 | 0.0 |
| ជប៉ុន | 2.8 | 0.9 | -0.1 | 0.6 | 1.0 | 0.3 | 0.7 | 0.3 | 0.5 | 0.5 | 0.1 | 0.2 |
| សហរដ្ឋអាមេរិក | 1.6 | 0.0 | 1.2 | 2.1 | 2.5 | 1.7 | 1.8 | 1.7 | 2.1 | 2.1 | 0.3 | 1.2 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

តារាង៣៖ អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១៤-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4037.6 | 4060.4 | 4053.6 | 4047.0 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 | 4101.4 | 4105.7 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 11850.2 | 13394.8 | 13338.3 | 13379.8 | 14227.6 | 14127.8 | 14246.8 | 14117.6 | 14060.5 | 14220.3 | 14944.2 | 14690.0 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.9 | 4.1 | 4.3 | 4.0 | 4.1 | 4.1 | 4.2 | 4.2 | 4.2 | 4.3 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 32.5 | 34.2 | 35.3 | 33.9 | 32.3 | 31.6 | 31.6 | 30.7 | 30.3 | 31.2 | 32.0 | 31.3 |
| វៀតណាម (ដុង) | 21138.2 | 21917.7 | 22507.5 | 22645.9 | 22663.3 | 22902.9 | 23255.5 | 23258.3 | 23217.3 | 23351.0 | 23244.6 | 23195.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.2 | 6.3 | 6.6 | 6.8 | 6.6 | 6.7 | 6.8 | 7.0 | 7.0 | 7.0 | 7.1 | 6.9 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1053.6 | 1131.9 | 1161.0 | 1130.5 | 1099.9 | 1125.0 | 1165.4 | 1193.4 | 1174.7 | 1191.5 | 1219.8 | 1188.5 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់) | 30.3 | 31.8 | 32.3 | 30.4 | 30.1 | 30.8 | 31.1 | 31.2 | 30.5 | 30.1 | 29.9 | 29.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 105.9 | 121.0 | 108.8 | 112.1 | 110.4 | 110.1 | 109.9 | 107.3 | 108.7 | 109.0 | 107.6 | 106.2 |

Sources: International Monetary Fund; Economist; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១៤-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 192.9 | 169.8 | 159.2 | 154.5 | 164.4 | 167.5 | 175.9 | 170.1 | 166.8 | 167.6 | 146.3 | 156.0 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 821.4 | 622.7 | 643.6 | 714.7 | 638.7 | 586.9 | 568.1 | 570.1 | 680.2 | 724.7 | 614.0 | 750.2 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 1755.6 | 1392.7 | 1416.1 | 1688.3 | 1401.4 | 1436.6 | 1549.5 | 1389.7 | 1410.1 | 1374.4 | 1144.4 | 1316.5 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 434.9 | 395.5 | 406.7 | 452.3 | 444.2 | 426.7 | 430.0 | 439.7 | 442.7 | 481.3 | 547.5 | 513.3 |
| សណ្ដែកសៀង (US No.1) - USA (ដុល្លារ/តោន) | 491.8 | 390.4 | 405.7 | 400.6 | 405.4 | 353.3 | 347.8 | 339.7 | 347.3 | 360.7 | 349.4 | 379.5 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 96.2 | 49.6 | 40.7 | 52.6 | 69.5 | 60.5 | 65.1 | 59.7 | 60.3 | 49.1 | 30.3 | 42.4 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 65.6 | 41.0 | 35.2 | 42.4 | 49.6 | 40.9 | 49.4 | 46.0 | 43.3 | 34.2 | 21.8 | 31.6 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 71.5 | 41.7 | 34.8 | 42.9 | 53.8 | 49.5 | 51.1 | 48.9 | 49.4 | 39.2 | 24.0 | 30.5 |

Sources: Food and Agriculture Organisation; US Energy Information Administration

*តពីទំព័រ ៧* **ការរាំងស្ទះ និង...**

*the Potential Impacts of COVID-19 School Closures on Schooling and Learning Outcomes: A Set of Global Estimates.* Policy Research Working Paper Series 9284. Washington, DC: World Bank.

Creswell, John W., and Vicki L. Plano Clark. 2018. *Designing and Conducting Mixed Methods Research.* Third Edition. Los Angeles, CA: Sage Publications.

Donitsa-Schmidt, Smadar, and Rony Ramot. 2020. “Opportunities and Challenges: Teacher Education in Israel in the Covid-19 Pandemic.” *Journal of Education for Teaching 46* (4). doi.org/10.1080/02607476.2020.1799708.

Giusti, Armando De. 2020. “Policy Brief: Education During COVID-19 and Beyond.” *Iberoamericana De Tecnología En Educación Y Educación En Tecnología* 26. doi.org/10.24215/18509959.26.e12.

Huang, Ronghuai, Dejian Liu, Changjie Chen and Haijun Zeng, et al. 2020. *Handbook on Facilitating Flexible Learning During Educational Disruption: The Chinese Experience in Maintaining Undisrupted Learning in COVID-19 Outbreak.* Beijing: Smart Learning Institute of Beijing Normal University.

Lapada, Aris Alea, Frosyl Fabrea Miguel, Dave Arthur Roldan Robledo and Zeba Farooqi Alam. 2020. “Teachers’ Covid-19 Awareness, Distance Learning Education Experiences and Perceptions towards Institutional Readiness and Challenges.” *International Journal of Learning, Teaching and Educational Research* 19 (6): 127–44.

Marinoni, Giorgio, Hilligje Van Land and Trine Jensen. 2020. “The Impact of COVID-19 on Higher Education around the World: IAU Global Survey Report.” Paris: International Association of Universities.

MoEYS 2020. “Education Congress: The Education, Youth and Sport Performance in the Academic Year 2018-2019 and Goals for the Academic Year 2019-2020.” Phnom Penh: MoEYS

Neuwirth, Lorenz S., Svetlana Jović, and B. Runi Mukherji. 2020. “Reimagining Higher Education During and Post-COVID-19: Challenges and Opportunities.” *Journal of Adult and Continuing Education* 0 (0): 1–16.

UNESCO. 2020a. “UNESCO’s Response in Cambodia Building Back Better.” Phnom Penh: UNESCO Office. https://unesdoc.unesco.org/ark:/48223/pf0000373583.

UNESCO. 2020b. “UNESCO Cambodia’s Support of the Ministry of Education, Youth and Sport to Provide an Immediate Response to the Impact of COVID-19 on Learning.” https://en.unesco.org/news/unesco-cambodias-support-ministry-education-youth-and-sport-provide-immediate-response-impact.

UNESCO, UNICEF and World Bank. 2020. “Survey on National Education Responses to COVID-19 School Closures, Round 2.” Paris; New York; Washington, DC: UNECSO, UNICEF, World Bank.

WHO. 2020. “Ministry of Health Responds to First Positive Case of New Coronavirus.” World Health Organization. News Release 28 Jan 2020. www.who.int/cambodia/news/detail/28-01-2020-ministry-of-health-responds-to-first-positive-case-of-new-coronavirus.

World Bank. 2020. “The COVID-19 Crisis Response: Supporting Tertiary Education for Continuity, Adaptation, and Innovation.” Policy Note. Washington, DC: World Bank.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

គេអាចមើលឃើញភ្លាមថា បញ្ជីវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ត្រូវបានអនុម័តនៅត្រីមាសទី៣ ឆ្នាំ២០២០ មានតិចជាងគេ បើធៀបនឹងត្រីមាសមុនៗក្នុងឆ្នាំដូចគ្នា ឬក្នុងឆ្នាំមុនៗ។ ធៀបនឹងកាលពីមួយឆ្នាំមុន ការអនុម័តវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ ធ្លាក់ចុះ ៨៤,០% ដោយសារការធ្លាក់ចុះការអនុម័តសម្រាប់ ឧស្សាហកម្ម (ចុះ ៦៣,៨%) និងសេវាកម្ម (ចុះ ៩៩,៩%) ទោះបីជា ការអនុម័តសម្រាប់កសិកម្មបានស្ទុះឡើង ១.៥៦៨,៩% ដល់ ៣១.៧លានដុល្លារក្តី។ ការអនុម័តសម្រាប់កសិកម្មបានស្ទុះឡើងនៅត្រីមាសទី៣ ក៏ពិតមែន ប៉ុន្តែវានៅមានកម្រិត ១១,៤% ទាបជាងត្រីមាសមុនដែលមានការស្ទុះឡើងពីការអនុម័តកម្រិតសូន្យនៅត្រីមាសទី១។ សម្រាប់វិស័យចម្បងៗពីរទៀត ការអនុម័តបានធ្លាក់ចុះ ទាំងធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងធៀបនឹងត្រីមាសមុនៗ។ សម្រាប់ឧស្សាហកម្ម ការអនុម័តបានធ្លាក់ចុះ ដោយសារការអនុម័តសម្រាប់ផ្នែកកាត់ដេរបានធ្លាក់ចុះ ៣៧,៣% ហើយសម្រាប់សេវាកម្ម គឺដោយសារការអនុម័តសម្រាប់សណ្ឋាគារនិងទេសចរណ៍ បានធ្លាក់ចុះ ៩៩,៦%។

គួរកត់សំគាល់ថា ទិន្នន័យទាក់ទិននឹងតម្លៃនៃការអនុម័តគម្រោងសាងសង់នៅក្រុងភ្នំពេញ មិនទាន់មានទេ ចាប់តាំងត្រីមាសទី៣ ឆ្នាំ២០១៥ មក។

ទាក់ទិននឹងភ្ញៀវទេសចរណ៍អន្តរជាតិមកដល់កម្ពុជា ទិន្នន័យបង្ហាញច្បាស់ថា ចំនួនភ្ញៀវមកដល់សរុបនៅត្រីមាសទី៣ នេះមានកម្រិតទាបជាង ក្នុងត្រីមាសនានានៃឆ្នាំមុនៗ ទោះបីវាបានកើន ៨៧,០% ធៀបនឹងត្រីមាសមុន ដល់ ៦៤.៨៥៤នាក់ (១.៤៧៥.៨៣២នាក់ នៅត្រីមាសដូចគ្នាឆ្នាំមុន) ហើយក្នុងនេះមាន ៥៥,៩% មកដល់តាមផ្លូវគោកនិងផ្លូវទឹក ៤២,៩% មកដល់តាមផ្លូវអាកាស។ ក្រៅពីភ្ញៀវ ៤,៥% ដែលមកដល់ពីប្រភពគ្មានបញ្ជាក់ច្បាស់ នេះជាលើកទី១ គិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៩ មក ដែលចំនួនសរុបនៃភ្ញៀវមកដល់ពីចិន មានត្រឹម ៤១,៩% គឺស្ថិតនៅលំដាប់ទី២ បន្ទាប់ពី ភ្ញៀវមកពីថៃដែលមានដល់ ៤៣,៨% និងដែលបានកើន ២៣៦,៤% ពីត្រឹម ៨.៤៣០នាក់ នៅត្រីមាសមុន រហូតដល់ ២៨.៣៥៨នាក់។ ធៀបនឹងត្រីមាសមុនដែរ ចំនួនភ្ញៀវមកដល់ពីប្រភពចម្បងៗ បានកើនឡើង ប៉ុន្តែដូចមានបញ្ជាក់នៅខាងលើដែរ ចំនួនទាំងនេះនៅទាបជាខ្លាំង បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០ និងជាពិសេសបើធៀបនឹងត្រីមាសនានានៅឆ្នាំមុនៗ។

ទោះបីមានជំងឺឆ្លងរាលដាលកូវីដ១៩ ក្តី ទិន្នន័យបានបង្ហាញថា ការនាំចេញរបស់កម្ពុជាបានល្អប្រសើរឡើង គឺកើន ៣០,៤% ធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ៣០,៨% ធៀបនឹងត្រីមាសមុន។ ធៀបនឹងគ្រប់ត្រីមាសចាប់តាំងពីដើមឆ្នាំ២០១៩ មក ការនាំចេញសម្លៀកបំពាក់ បានឡើងដល់កម្រិតខ្ពស់បំផុត នៅត្រីមាសទី៣ ឆ្នាំ២០១៩ និងមានការឡើងចុះនៅត្រីមាសក្រោយៗមកទៀត។ តម្លៃសម្លៀកបំពាក់នាំចេញក្នុងត្រីមាសទី៣ នេះមានកម្រិតខ្ពស់បំផុតលំដាប់ទី២ ដល់ ២.៧០៥លានដុល្លារ ឬ ១៣,៩% ទាបជាងតម្លៃខ្ពស់បំផុត នៅត្រីមាសដូចគ្នាឆ្នាំ២០១៩ ប៉ុន្តែ ៣៦,៤% ខ្ពស់ជាងត្រីមាសមុន ពីព្រោះតម្លៃនាំចូលបំពាក់នាំចេញបានកើនឡើង សម្រាប់គ្រប់ប្រទេស លើកលែងតែអាស៊ាន។ ការនាំចេញទៅសហរដ្ឋអាមេរិក (ប្រទេសនាំចូលធំជាងគេនៅត្រីមាសនេះ) បានកើន ៤៩,៦% ទៅសហភាពអឺរ៉ុប (ប្រទេសនាំចូលធំជាងគេលំដាប់ទី២) កើន ១៤,០% ទៅជប៉ុនកើន ៤៧,៣% ទៅអង់គ្លេសកើន ៦៣,៥% ទៅប្រទេសផ្សេងៗទៀតកើន ៣៩,០% ប៉ុន្តែទៅអាស៊ានបានធ្លាក់ចុះ ១០,៦% បើធៀបនឹងត្រីមាសមុន។

ការនាំចេញគ្រឿងអេឡិចត្រូនិក ក៏បានកើនឡើងគួរឲ្យកត់សំគាល់ដែរ ដោយបានឡើងខ្ពស់បំផុតដល់ ១៨៣,២លានដុល្លារនៅត្រីមាសទី៣ នេះ បើគិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៩ មក ដោយវាមានកម្រិត ២៨,៧% ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំមុន និង ៦៥,០% ខ្ពស់ជាងត្រីមាសមុន។

ការនាំចេញគ្រឿងបង្គុំរថយន្តបានធ្លាក់ចុះ ១៧,៧% ធៀបនឹងកម្រិតខ្ពស់បំផុតនៅត្រីមាសមុន ប៉ុន្តែវានៅខ្ពស់ជាង ៧ត្រីមាសមុនៗនោះទៀត។

ស្រដៀងគ្នានឹងនិន្នាការនៃគ្រឿងបង្គុំរថយន្តដែរ ការនាំចេញផលិតផលកសិកម្មបានឡើងខ្ពស់បំផុតនៅត្រីមាសទី២ និងបានធ្លាក់ចុះវិញនៅត្រីមាសទី៣ ប៉ុន្តែនៅមានតម្លៃខ្ពស់បំផុតលំដាប់ទី៣ ក្នុងរយៈពេល ៧ត្រីមាសចុងក្រោយនេះ។ ការនាំចេញផ្នែកកសិកម្មបានធ្លាក់ចុះ ៨,៩%ធៀបនឹងត្រីមាសមុន ដល់ ២៧៧,៤លានដុល្លារ ដោយសារជាសំខាន់ ការធ្លាក់ចុះការនាំចេញផលិតផលកសិកម្ម ដូចជា ឈើធ្លាក់ចុះ ៨,៣% អង្ករចុះ ៤០,៧% និងផលិតផលផ្សេងៗគ្មានបញ្ជាក់ច្បាស់ចុះ ៣០,៥% ទោះបីជាការនាំចេញកៅស៊ូបានកើនឡើង ១០៧,៨% ហើយការនាំចេញត្រីនៅថេរ (និងមានតម្លៃទាបបំផុត ក្នុងចំណោមផលិតផលកសិកម្មនាំចេញ) ត្រឹម ០,១លានដុល្លារក្តី។

គួរកត់សំគាល់ដែរពីសារៈសំខាន់នៃ ការនាំចេញផលិតផលផ្សេងៗគ្មានបញ្ជាក់ច្បាស់ ព្រោះវាមានចំណែកយ៉ាងធំរហូតដល់ ៤២,៤% នៃការនាំចេញសរុបក្នុងត្រីមាសទី៣ នេះ ដោយវាបានកើនដល់ ២.៣៦០,៧លានដុល្លារ (តម្លៃខ្ពស់បំផុតក្នុងរយៈពេល ៧ត្រីមាស) ឬកើន ៣០,៥% ធៀបនឹងត្រីមាសមុន និងកើន ២១៧,៣% ធៀបនឹងកាលពីមួយឆ្នាំមុន។

បើពិនិត្យក្នុងរយៈពេលតាំងពីត្រីមាសទី១ ឆ្នាំ២០១៩ មក ការនាំចូលនៅត្រីមាសទី៣ ឆ្នាំ២០២០ មានតម្លៃទាបបំផុតលំដាប់ទី៣ ត្រឹម ៤.៥៧១,៦លានដុល្លារ ធៀបនឹងតម្លៃទាប

---

អត្ថបទនេះ រៀបរៀងដោយ រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

បំផុតត្រឹម ៤.៣៦១,៥លានដុល្លារ នៅត្រីមាសមុន និងទាបបំផុតលំដាប់ទី២ ត្រឹម ៤.៤៣៧,៧លានដុល្លារនៅត្រីមាសទី១ ឆ្នាំ២០១៩។ នៅត្រីមាសទី៣ នេះ តម្លៃនាំចូលសរុបនៃទំនិញនាំចូលជ្រើសរើសបីមុខ គឺ សាំង ម៉ាស៊ូត និង សម្ភារសំណង់ មានចំណែកត្រឹមតែ ១៤,៤% នៃការនាំចូលសរុបប៉ុណ្ណោះ រីឯ ៨៥,៦% ទៀត គឺជា ទំនិញនាំចូលផ្សេងៗគ្មានបញ្ជាក់ច្បាស់។ ធៀបនឹងត្រីមាសមុន ការនាំចូល សាំងកើន ១,៨% ម៉ាស៊ូតកើន ៣,៤% សម្ភារសំណង់កើន ៥,៧% ហើយតម្លៃនាំចូលសរុបនៃទំនិញនាំចូលផ្សេងៗកើន ៤,០%។

ដោយសារនៅត្រីមាសទី៣ នេះ ការនាំចេញអង្ករយ៉ាងច្រើនបានលុបលើ កំណើនយ៉ាងតូចក្នុងតម្លៃនាំចូល នេះជាលើកទី១ ហើយដែលកម្ពុជាមាន ជញ្ជីងពាណិជ្ជកម្មវិជ្ជមាន (ពិនិត្យលើត្រីមាសទាំងអស់ដែលមានចុះក្នុងរបាយការណ៍នេះ) ដោយវាមានចំនួន ៩៩០,៥លានដុល្លារ ធៀបនឹង -១១០,១លានដុល្លារនៅត្រីមាសមុន។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ឆ្នាំ២០២០ ចំណូលសរុបរបស់រដ្ឋាភិបាលធ្លាក់ចុះ ៣៤,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ដល់ ៤.១៨៩,៨ប៊ីលានរៀល និងធ្លាក់ចុះ ២៤,៦% ធៀបនឹងត្រីមាសមុន។ ចំណូលចរន្តជានិច្ចជាកាលវាធំជាង ចំណូលជាមូលធន ហើយនៅត្រីមាសទី៣ នេះ វាចូលរួមចំណែក ៤.១៥០,០ប៊ីលានរៀល ឬ ៩៩,១% ក្នុងចំណូលសរុប ដោយបានធ្លាក់ចុះ ៣៤,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងធ្លាក់ចុះ ២៤,៦% ធៀបនឹងត្រីមាសមុន។ ពីមួយឆ្នាំទៅមួយឆ្នាំ ការធ្លាក់ចុះនេះជំរុញឡើងដោយការធ្លាក់ចុះ ២៨,២%ក្នុងចំណូលពន្ធ និង ៧០,៦% ក្នុងចំណូលមិនមែនពន្ធ។ ចំណូលគ្រប់ប្រភេទនៅក្នុងចំណូលពន្ធបានធ្លាក់ចុះ ហើយចំណូលមិនមែនពន្ធក៏ដូចគ្នាដែរ លើកលែងតែកំណើន ៣,០% ធៀបនឹងកាលពីមួយឆ្នាំមុនក្នុងចំណូលលើទ្រព្យសម្បត្តិ។ ធៀបនឹងត្រីមាសមុន មានតែចំណូលលើពាណិជ្ជកម្មក្រៅប្រទេសប៉ុណ្ណោះ ដែលបានកើន ៩,៨% រីឯចំណូលផ្សេងទៀតទាំងក្នុងចំណូលពន្ធ និងចំណូលមិនមែនពន្ធ គឺបានធ្លាក់ចុះ។

នៅត្រីមាសទី៣ ឆ្នាំ២០២០ ចំណាយរដ្ឋាភិបាលសរុបមានចំនួនខ្ពស់បំផុតលំដាប់ទី៣ ដល់ ៥.៦០៣,៨ប៊ីលានរៀល បន្ទាប់ពីត្រីមាសទី៤ ឆ្នាំ២០១៩ (ខ្ពស់បំផុត) និងត្រីមាសទី២ ឆ្នាំ២០២០ (ខ្ពស់បំផុតលំដាប់ទី២) ក្នុងចំណោមត្រីមាសទាំងអស់គិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៩ មក។ ចំណាយចរន្តដែលរួមមាន ចំណាយលើបៀវត្សរ៍ ចំណាយលើឧបត្ថម្ភធននិងជំនួយសង្គម និងចំណាយចរន្តផ្សេងទៀត មានចំណែក ៦៨,៦% ក្នុងចំណាយសរុប ហើយចំណាយជាមូលធនមានចំណែក ៣១,៤%។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០១៩ ចំណាយជាមូលធនកើន ២៩,៣% ប៉ុន្តែធ្លាក់ចុះ ២៣,២% ធៀបនឹងត្រីមាសមុន។ ចំណាយចរន្តធ្លាក់ចុះ ៤,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងចុះ ៥,១% ធៀបនឹងត្រីមាសមុន។ នៅក្នុងចំណាយចរន្ត មានតែចំណាយលើបៀវត្សរ៍ប៉ុណ្ណោះដែលបានកើនឡើង ទាំងធៀបនឹងកាលពីមួយឆ្នាំមុន និងធៀបនឹងត្រីមាសមុន រីឯចំណាយលើឧបត្ថម្ភធន និងជំនួយសង្គម និងចំណាយចរន្តផ្សេងទៀត បានធ្លាក់ចុះ។

សមតុល្យសរុបនៃថវិកាជាតិមានឱនភាព ១.៤១៤,០ប៊ីលានរៀល ឬកើន ៧៩,៥% ធៀបនឹងត្រីមាសមុន (ឱនភាព ៧៨៧,៨ប៊ីលានរៀល)។ ដើម្បីដោះស្រាយឱនភាពនេះ មានការបង្កើនទាំងហិរញ្ញប្បទានពីក្រៅប្រទេស និងហិរញ្ញប្បទានក្នុងស្រុក ពោលគឺហិរញ្ញប្បទានពីក្រៅប្រទេសបានកើន ១៣២,៥% ធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ១៩,៩% ធៀបនឹងត្រីមាសមុន។ ហិរញ្ញប្បទានក្នុងស្រុកបានកើន ៨៥០,៤% ធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ៥០៤,៨% ធៀបនឹងត្រីមាសមុន ដែលជាហិរញ្ញប្បទានក្នុងស្រុកធំបំផុត ធៀបទៅនឹងត្រីមាសមុនៗទាំងអស់គិតតាំងពីត្រីមាសទី១ ឆ្នាំ២០១៩ មក។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០២០ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខ (CPI) នៅភ្នំពេញ កើនដល់ ២,៨% ធៀបនឹងកម្រិត ២,៥% នៅត្រីមាសមុន។ បើធៀបនឹងគ្រប់ត្រីមាសឯទៀតគិតតាំងពីដើមឆ្នាំ២០១៩មក នេះជាសន្ទស្សន៍ខ្ពស់បំផុតលំដាប់ទី២ បន្ទាប់ពីសន្ទស្សន៍ខ្ពស់បំផុតនៅត្រីមាសទី១ ឆ្នាំ២០២០។ សន្ទស្សន៍ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រាធ្លាក់ចុះ ០,៤ឯកតាភាគរយ ប៉ុន្តែសន្ទស្សន៍ថ្លៃដឹកជញ្ជូនកើន ៦,២ឯកតាភាគរយ ដល់ -៤,៦%។

ធៀបនឹងត្រីមាសមុន ប្រាក់រៀលចុះថ្លៃ ០,២% ទល់នឹងប្រាក់ដុល្លារដល់៤.០៩៤,៦រៀល/ដុល្លារនិងចុះថ្លៃ២,៧%ទល់នឹងប្រាក់បាតថៃ ដល់ ១៣១,០រៀល/បាត ប៉ុន្តែនៅថេរទល់នឹងប្រាក់ដុងវៀតណាម ត្រឹម ១៧,៧រៀល/១០០ដុង។

មាសឡើងឡើងថ្លៃ ២០,៩% ធៀបនឹងត្រីមាសមុន ដល់ ២២៤,២ដុល្លារ/ជី ម៉ាស៊ូតឡើងថ្លៃ ១៤,១% ដល់ ២.៧៣០,៦ រៀល/លីត្រ ហើយសាំងឡើងថ្លៃ ២០,៩% ដល់ ៣.០០៣,៧ រៀល/លីត្រ។

## អង្កេតលើពលករងាយរងគ្រោះ

ផ្នែកនេះពិពណ៌នាពី ស្ថានភាពរបស់ពលករងាយរងគ្រោះ ដោយប្រើទិន្នន័យបានពី អង្កេតរបស់ CDRI នៅខែវិច្ឆិកា ២០២០ (ត្រីមាសទី៤) លើពលករងាយរងគ្រោះ ៤៨០នាក់ ក្នុងនោះមាន កម្មកររោងចក្រកាត់ដេរ ១២០នាក់ និងពលករក្នុង ៩ក្រុមផ្សេងទៀត ៣៦០នាក់ (សូមមើលតារាង៨)។ លើកលែងតែនៅត្រីមាសទី៣ ឆ្នាំ២០២០ នេះចេញ គិតតាំងពីខែកុម្ភៈ ២០១៨ មក កម្មករសំណង់មានជំនាញ គឺមានប្រាក់ចំណូលប្រចាំថ្ងៃខ្ពស់ជាងគេ ដោយឡើងខ្ពស់បំផុតដល់ ៣១.២៩៨រៀល/ថ្ងៃ នៅត្រីមាសមុន ហើយនៅត្រីមាសនេះបានធ្លាក់ចុះទាបបំផុតដល់ ២២.០៦៩រៀល/ថ្ងៃ ប៉ុន្តែនៅខ្ពស់ជាងគេលំដាប់ទី២ បើ

ធៀបនឹងពលករប្រភេទផ្សេងទៀត។ នៅត្រីមាសទី៣ នេះដែរ គឺជាលើកទី១ ដែលអ្នកលក់បន្លែតូចតាច មានចំណូលខ្ពស់បំផុត ធៀបនឹងត្រីមាសមុនៗគិតតាំងពីខែកុម្ភៈ២០១៩មក និងធៀបនឹង ប្រាក់ចំណូលរបស់ពលករប្រភេទឯទៀតក្នុងត្រីមាសទី៣ដូចគ្នា។ ក្នុងចំណោមពលករងាយរងគ្រោះ អ្នករត់តុភោជនីយដ្ឋាន និង អ្នកស៊ីឈ្នួលធ្វើស្រែ មានប្រាក់ចំណូលប្រចាំថ្ងៃទាបជាងគេជានិច្ច ត្រឹម ៨.៩១២រៀល និង ៨.៩២៤រៀលរៀងគ្នា រីឯប្រាក់ចំណូល របស់ពលករប្រភេទផ្សេងទៀត បានឡើងចុះបន្តិចបន្តួច ពីជាង ១០.០០០រៀល ដល់ប្រមាណ ២០.០០០រៀល លើកលែងតែ ប្រាក់ចំណូលរបស់ កម្មករសំណង់គ្មានជំនាញដែលឡើងដល់ ២២.៩១៦រៀលនៅខែកុម្ភៈ ២០២០។ សម្រាប់ផ្នែកនេះ ដើម្បី ពិពណ៌នាពីស្ថានភាពរបស់ពលករងាយរងគ្រោះ អ្នកនិពន្ធបាន បែងចែកពួកគាត់ជាពីរក្រុម គឺពលករក្នុងវិស័យក្រៅប្រព័ន្ធ និង ពលករក្នុងវិស័យក្នុងប្រព័ន្ធ។

ក្នុងចំណោមពលករក្នុងវិស័យក្រៅប្រព័ន្ធ ពលករមានអាយុពី ២១-២៥ឆ្នាំ មានភាគរយខ្ពស់ជាងគេ (១៥,៨%) បន្ទាប់មកគឺ អ្នកមានអាយុ ៣៦-៤០ឆ្នាំ (១៤,៤%) អាយុ ៤១-៤៥ឆ្នាំ (១១,៩%) អាយុ ៣១-៣៥ឆ្នាំ (១០,៦%) ហើយចំនួនសរុបនៃពលករក្នុង ក្រុមអាយុទាំងបួន មានជាងពាក់កណ្ដាលបន្តិចនៃកម្លាំងពលកម្ម សរុបដែលធ្វើការក្នុងប្រភេទការងារទាំង ៩។ ក្នុងចំណោមអ្នក មានអាយុ ២៦-៤១ឆ្នាំ កម្មករសំណង់គ្មានជំនាញមានភាគរយ ខ្ពស់ជាងគេ (១៦,៨%) បន្ទាប់មកគឺ កម្មករសំណង់មានជំនាញ (១៥,៣%) អ្នកលីសែង (១៤,២%) អ្នកលក់បន្លែតូចតាច (១២,៦%) អ្នករើសអេតចាយ (១២,១%) អ្នករត់តុភោជនីយដ្ឋាន (៨,៩%) អ្នករត់ស៊ីក្លូ (៥,៨%) អ្នកស៊ីឈ្នួលធ្វើស្រែ (២,៦%)។ សម្រាប់ពលករក្រៅពីក្រុមនេះ អ្នកមានអាយុលើសពី ៤៥ឆ្នាំ មាន ច្រើនជាងគេរហូតដល់ ២៥,៣% ហើយអ្នកមានអាយុតិចជាង ២៦ឆ្នាំ មាន ១០,៦%។ ក្នុងចំណោមអ្នកមានអាយុលើសពី ៤៥ឆ្នាំ អ្នកស៊ីឈ្នួលធ្វើស្រែមានច្រើនជាងគេរហូតដល់ ២៦,៥% បន្ទាប់ មកគឺ អ្នករត់ស៊ីក្លូ (២២,០) អ្នករត់ម៉ូតូឌុប (១៣,៦%) អ្នកលក់ បន្លែតូចតាច (១១,៤%) អ្នករើសអេតចាយ (៩,៨%) កម្មករ សំណង់មានជំនាញ (៧,៦%) អ្នកលីសែង (៦,៨%) កម្មករ សំណង់គ្មានជំនាញ (២,៣%)។ គួរកត់សំគាល់ដែរថា គ្មានអ្នក រត់តុភោជនីយដ្ឋានណាម្នាក់មានអាយុលើសពី ៤៥ឆ្នាំទេ ហើយ សំខាន់ជាងនេះទៀត ពួកគាត់ភាគច្រើនស្ថិតក្នុងក្រុមអាយុក្មេង ជាងគេ គឺមិនលើសពី ៣០ឆ្នាំទេ ប៉ុន្តែអ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នក រត់ស៊ីក្លូ គឺផ្ទុយគ្នាទាំងស្រុងពីអ្នករត់តុ។

ទាក់ទិននឹងយេនឌ័រវិញ ៦៣,១% នៃពលករក្នុង ៩ប្រភេទ ការងារនេះ គឺជាបុរស ប៉ុន្តែគួរពិនិត្យបន្ថែមពីរបាយក្នុងប្រភេទ ការងារនីមួយៗ។ សម្រាប់ពលករបួនប្រភេទ ពោលគឺ អ្នករត់ស៊ីក្លូ អ្នករត់ម៉ូតូឌុបអ្នកលីសែងនិងអ្នកលក់បន្លែតូចតាចចំនួនបុរសនិង ស្ត្រី មានការខុសគ្នាជាខ្លាំង។ ជាក់ស្តែង គ្មានស្ត្រីណាម្នាក់បំពេញ ការងារជា អ្នករត់ស៊ីក្លូ អ្នករត់ម៉ូតូឌុប ឬអ្នកលីសែង នោះទេ ហើយផ្ទុយទៅវិញ អ្នកលក់បន្លែតូចតាចទាំងអស់សុទ្ធតែជាស្ត្រី។ ក្រៅពីក្រុមអ្នកលក់បន្លែតូចតាច ស្ត្រីក៏មានភាគរយច្រើនជាងក្នុង ចំណោម អ្នកស៊ីឈ្នួលធ្វើស្រែ (៩៥,០%) អ្នករើសអេតចាយ (៦៥,០) និង អ្នករត់តុភោជនីយដ្ឋាន (៦៥,០%) ដែរ។ ផ្ទុយទៅវិញ ៩៧,០% នៃកម្មករសំណង់មានជំនាញ និង ៩៥,០% នៃកម្មករសំណង់គ្មានជំនាញ គឺជាបុរស។

ទាក់ទិននឹង ចំណាយមធ្យមរបស់ពលករគ្រប់ប្រភេទ អ្នក លក់បន្លែតូចតាច មានចំណាយប្រចាំខែខ្ពស់ជាងគេ រហូតដល់ ៧២០.៤៧៥រៀល រីឯ អ្នករត់តុភោជនីយដ្ឋាន មានចំណាយទាប ជាងគេត្រឹម ១៦៦.៥០០រៀល។ អ្នករត់ម៉ូតូឌុប មានចំណាយ ប្រចាំខែខ្ពស់ជាងគេលំដាប់ទី២ ដល់ ៥៦០.០០០រៀល បន្ទាប់ មកគឺ អ្នកលីសែង (៤៦៦.៧៥០រៀល) អ្នករើសអេតចាយ (៤០៤.៥០០រៀល) កម្មករសំណង់មានជំនាញ (៣៧៤.៥០០រៀល) កម្មករសំណង់គ្មានជំនាញ (៣៧១.២៥០រៀល) អ្នកស៊ីឈ្នួល ធ្វើស្រែ (៣៦១.៨៧៥រៀល) អ្នករត់ស៊ីក្លូ (៣៤១.៩៥០រៀល)។ គិតជាមធ្យម ពលករទាំងនេះចំណាយជាសំខាន់លើ ស្បៀង អាហារ (៧២,៩%) កន្លែងស្នាក់នៅ (១១,០%) ការដឹកជញ្ជូន (២,៤%) ថែទាំសុខភាព (២,៩%) និងចំណាយផ្សេងៗទៀត (១២,៨%)។

កម្មកររោងចក្រកាត់ដេរ មានស្ថានភាពមិនសូវខុសគ្នាខ្លាំង ពី ពលករប្រភេទផ្សេងទៀតទេ។ ប្រាក់ចំណូលប្រចាំថ្ងៃបានកើន ឡើងធៀបនឹងត្រីមាសមុនដល់ ១៤.៣៩១រៀល ប៉ុន្តែធ្លាក់ចុះ ១៣,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ប្រាក់ចំណូលនេះយក ទៅចំណាយជាសំខាន់លើ ស្បៀងអាហារ (៦៧,៤%) កន្លែង ស្នាក់នៅ (២៤,២%) ការដឹកជញ្ជូន (០,៧%) ការថែទាំសុខភាព (៦,៤%) និងចំណាយផ្សេងៗទៀត(៥,៧%)។ អ្នកឆ្លើយសម្ភាសន៍ សឹងគ្រប់គ្នា (៩៩,២%) ក្នុងក្រុមនេះ គឺជាស្ត្រី ហើយភាគច្រើន លើសលុបរហូតដល់ ៨៦,៧% មានអាយុតិចជាង ៤០ឆ្នាំ ១១,៧% មានអាយុ ៤១-៥០ឆ្នាំ ហើយ ១,៧% មានអាយុលើសពី ៥០ឆ្នាំ។ ទាក់ទិននឹងស្ថានភាពគ្រួសារ កម្មកររោងចក្រកាត់ដេរ ៦១,៧% មានប្ដី/ប្រពន្ធ, ២៩,២% នៅលីវ, ៩,២% មេម៉ាយ /ពោះម៉ាយ។ ពួកគាត់មកពី ១៥ខេត្ត/ក្រុង ក្នុងនេះ អ្នកមកពី ព្រៃវែងមានច្រើនជាងគេ (២៥,០%) បន្ទាប់មកគឺ អ្នកមកពី ខេត្ត/ក្រុងជិតខាងនោះ រួមមាន ស្វាយរៀង (១៥,០%) កំពង់ធំ (១០,០%) កំពង់ចាម (១០,០%) ភ្នំពេញ (៧,៥%) ត្បូងឃ្មុំ (៥,៨%) កំពង់ស្ពឺ (៥,៨%) តាកែវ (៥,០%) កណ្ដាល (៤,២%) ពោធិ៍សាត់ (២,៥%) កំពត (២,៥%) កំពង់ឆ្នាំង (២,៥%) មណ្ឌលគិរី (១,៧%) ឧត្ដរមានជ័យ (១,៧%) សៀមរាប (០,៨%)។ អ្នកមកពីគ្រួសារមានសមាជិកបីនាក់ មានច្រើនជាង គេ (២៤,២%) បន្ទាប់មកគឺ អ្នកមកពីគ្រួសារមានសមាជិក ៤នាក់ (២៣,៣%) សមាជិក ៥នាក់ (១៩,២%) សមាជិក ៦នាក់ (១៩,២%) ៧នាក់ (៦,៧%) ២នាក់(៤,២%) ១នាក់(១,៧%) ៨នាក់ (០,៨%) ៩នាក់ (០,៨%)។

## តារាង១៖ គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១៤-២០

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 56.5 | 169.8 | 117.1 | 62.9 | 214.9 | 17.2 | 48.2 | 1.9 | 27.5 | 0.0 | 35.8 | 31.7 |
| ឧស្សាហកម្ម | 1002.5 | 1014.7 | 1436.4 | 982.2 | 1186.2 | 292.9 | 113.7 | 302.0 | 919.9 | 234.0 | 737.0 | 109.3 |
| *. សម្លៀកបំពាក់* | 393.5 | 225.2 | 380.7 | 211.1 | 187.3 | 73.9 | 34.4 | 47.3 | 74.1 | 106.0 | 55.5 | 29.7 |
| សេវាកម្ម | 622.6 | 2734.4 | 1664.3 | 3858.6 | 4351.8 | 1625.6 | 2518.2 | 849.7 | 1440.4 | 682.1 | 481.2 | 43.4 |
| *. សណ្ឋាគារ និងទេសចរណ៍* | 446.9 | 98.6 | 1366.9 | 2759.6 | 1584.0 | 1618.8 | 2518.2 | 808.7 | 1703.8 | 133.0 | 202.4 | 3.5 |
| សរុប | 1583.9 | 3918.9 | 3217.7 | 4903.7 | 5752.9 | 1935.6 | 2680.1 | 1153.5 | 2387.8 | 916.1 | 1254.1 | 184.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 4.9 | 38.5 | -57.0 | 107.0 | -61.6 | 36.9 | -85.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -63.4 | 147.4 | -17.9 | 52.4 | 17.3 | 312.5 | 12.6 | 8.9 | 29.4 | -52.7 | -53.2 | -84.0 |

Note: Including expansion project approvals. Source: Cambodian Investment Board

## តារាង២៖ តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ ផ្ទះ និងផ្ទះល្វែង | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 227.3 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | - |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣៖ ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១៤-២០

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| ចិន | 560.3 | 694.7 | 830.0 | 1210.8 | 2024.4 | 683.4 | 609.1 | 572.5 | 496.9 | 259.7 | 15.9 | 27.2 |
| វៀតណាម | 905.8 | 987.8 | 959.7 | 835.4 | 800.1 | 186.9 | 214.8 | 235.7 | 271.5 | 179.5 | 0.2 | 1.1 |
| កូរ៉េខាងត្បូង | 424.4 | 395.3 | 357.2 | 345.0 | 301.8 | 95.7 | 43.6 | 47.4 | 68.1 | 41.7 | 1.0 | 1.8 |
| ថៃ | 279.5 | 349.9 | 398.1 | 394.9 | 382.3 | 97.9 | 76.3 | 113.9 | 178.4 | 152.7 | 8.4 | 28.4 |
| សហរដ្ឋអាមេរិក | 191.4 | 217.5 | 238.7 | 256.5 | 250.8 | 79.0 | 53.2 | 45.5 | 71.2 | 42.7 | 0.3 | 1.4 |
| ជប៉ុន | 215.8 | 193.3 | 191.6 | 203.4 | 210.5 | 60.2 | 40.4 | 48.9 | 58.2 | 39.8 | 0.2 | 0.7 |
| បារាំង | 141.1 | 145.7 | 150.3 | 166.4 | 170.8 | 59.4 | 27.3 | 32.9 | 44.5 | 41.8 | 0.1 | 0.7 |
| ចក្រភពអង់គ្លេស | 133.3 | 154.3 | 159.5 | 171.2 | 162.4 | 59.4 | 29.7 | 28.5 | 45.6 | 44.2 | 0.1 | 0.3 |
| ម៉ាឡេស៊ី | 144.4 | 149.4 | 152.8 | 179.3 | 201.1 | 48.7 | 43.2 | 46.5 | 64.6 | 24.9 | 0.1 | 0.3 |
| តាមផ្លូវអាកាស | 2273.5 | 2476.0 | 2778.0 | 3312.7 | 6405.6 | 1299.1 | 1054.8 | 1039.9 | 1010.2 | 663.6 | 26.3 | 36.3 |
| តាមផ្លូវគោក និងទឹក | 2229.3 | 2299.2 | 2331.4 | 2289.4 | 3242.2 | 578.7 | 405.8 | 436.0 | 786.1 | 491.6 | 8.4 | 28.5 |
| សរុប | 4502.8 | 4775.2 | 4980.4 | 5602.2 | 9647.7 | 1877.9 | 1460.6 | 1475.8 | 1796.3 | 1155.2 | 34.7 | 64.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 2.9 | -22.2 | 1.0 | 21.7 | -35.7 | -97.0 | 87.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 7.0 | 6.1 | 4.3 | 12.5 | 72.2 | 9.7 | 13.2 | 7.4 | -1.6 | -38.5 | -97.6 | -95.6 |

Source: Ministry of Tourism

## តារាង៤៖ ការនាំចេញ និងនាំចូល ឆ្នាំ២០១៤-២០ *

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 8106.0 | 9256.4 | 10043.3 | 10772.9 | 12783.8 | 3222.7 | 3379.0 | 4263.9 | 3524.9 | 3550.1 | 4251.5 | 5562.2 |
| សម្លៀកបំពាក់ | 5960.5 | 6827.0 | 7308.0 | 8020.3 | 9506.0 | 2463.4 | 2526.3 | 3143.8 | 2530.9 | 2647.2 | 1983.8 | 2705.4 |
| - សហរដ្ឋអាមេរិក | 1963.6 | 2009.4 | 1831.5 | 1923.8 | 2483.2 | 739.8 | 802.9 | 1006.5 | 848.0 | 945.9 | 694.3 | 1038.6 |
| - សហភាពអឺរ៉ុប | 2403.7 | 2903.9 | 2928.7 | 2782.2 | 3155.3 | 719.2 | 801.1 | 965.4 | 716.2 | 706.3 | 579.9 | 661.2 |
| - អាស៊ាន | 83.3 | 103.4 | 98.4 | 106.9 | 135.3 | 38.1 | 41.3 | 48.2 | 53.1 | 54.6 | 54.6 | 48.8 |
| - ជប៉ុន | 383.1 | 524.2 | 655.5 | 701.2 | 890.8 | 262.9 | 175.8 | 291.2 | 236.8 | 262.9 | 156.7 | 230.8 |
| - ចក្រភពអង់គ្លេស | - | - | 439.8 | 904.0 | 1007.0 | 211.5 | 197.7 | 272.9 | 200.3 | 190.2 | 136.6 | 223.4 |
| - ប្រទេសផ្សេងៗ | 1126.8 | 1286.3 | 1354.2 | 1602.2 | 1834.3 | 491.7 | 507.5 | 559.7 | 476.4 | 487.3 | 361.7 | 502.8 |
| គ្រឿងអេឡិចត្រូនិក | - | - | - | 380.0 | 328.7 | 71.9 | 123.8 | 142.3 | 116.3 | 113.0 | 111.0 | 183.2 |
| គ្រឿងបង្គុំថយន្ត | - | - | - | 11.6 | 94.4 | 20.4 | 18.2 | 22.7 | 24.1 | 26.0 | 43.0 | 35.4 |
| កសិកម្ម | 624.4 | 548.8 | 534.1 | 706.4 | 850.9 | 210.4 | 177.7 | 211.0 | 288.1 | 262.9 | 304.5 | 277.4 |
| - កៅស៊ូ | 153.9 | 165.4 | 165.3 | 273.5 | 217.6 | 43.8 | 42.2 | 60.0 | 73.3 | 30.8 | 40.0 | 83.1 |
| - ឈើ | 132.0 | 46.3 | 47.2 | 100.5 | 142.3 | 22.2 | 35.2 | 42.4 | 47.5 | 44.0 | 93.8 | 86.0 |
| - ត្រី | 0.8 | 0.5 | 0.6 | 0.6 | 1.3 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 | 0.1 |
| - អង្ករ | 248.5 | 315.3 | 300.8 | 255.1 | 413.6 | 122.4 | 72.2 | 84.5 | 140.2 | 145.9 | 105.5 | 62.6 |
| - ផលិតផលកសិកម្មផ្សេងៗ | 89.1 | 21.3 | 20.2 | 76.7 | 76.2 | 21.9 | 28.1 | 24.1 | 26.9 | 42.2 | 65.1 | 45.6 |
| ផ្សេងៗ | 1520.1 | 1880.2 | 2201.2 | 1654.7 | 2003.8 | 456.6 | 532.9 | 744.0 | 565.6 | 501.0 | 1809.2 | 2360.7 |
| ការនាំចូលសរុប | 10295.4 | 11494.5 | 15013.4 | 16815.4 | 16904.7 | 4437.7 | 5328.6 | 5091.4 | 5324.3 | 5250.9 | 4361.5 | 4571.6 |
| សាំង | 334.7 | 377.3 | 384.8 | 256.7 | 320.5 | 121.1 | 117.1 | 118.6 | 121.9 | 131.4 | 122.6 | 124.8 |
| ម៉ាស៊ីត | 602.3 | 607.8 | 709.1 | 472.9 | 594.1 | 228.2 | 250.2 | 166.4 | 248.9 | 248.1 | 265.1 | 274.2 |
| សម្ភារសំណង់ | 117.6 | 164.4 | 253.2 | 304.3 | 564.5 | 170.8 | 231.4 | 271.2 | 224.4 | 177.0 | 213.5 | 260.8 |
| ផ្សេងៗ | 9240.7 | 10345.1 | 13666.3 | 15781.6 | 15425.7 | 3917.7 | 4729.9 | 4535.2 | 4729.1 | 4694.4 | 3760.4 | 3911.9 |
| ជញ្ជីងពាណិជ្ជកម្ម | -2184.3 | -2238.1 | -4970.0 | -5974.1 | -4120.9 | -1215.0 | -1990.6 | -827.5 | -1799.4 | -1700.9 | -110.1 | 990.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 7.0 | 2.6 | 24.4 | -19.5 | 4.6 | -25.1 | 36.4 |
| ការនាំចេញសរុប | - | - | - | - | - | 2.8 | 7.8 | 26.2 | -17.3 | 0.7 | 19.8 | 30.8 |
| ការនាំចូលសរុប | - | - | - | - | - | 6.0 | 27.2 | -4.5 | 4.6 | -1.4 | -16.9 | 4.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 10.7 | 14.5 | 7.0 | 9.7 | 18.5 | 17.7 | 12.8 | 9.5 | 9.9 | 7.5 | -21.5 | -13.9 |
| ការនាំចេញសរុប | 16.1 | 14.2 | 8.5 | 7.9 | 17.9 | 13.7 | 12.6 | 11.8 | 12.4 | 10.2 | 25.8 | 30.4 |
| ការនាំចូលសរុប | 19.7 | 11.7 | 30.6 | 12.0 | 0.5 | 4.6 | 18.5 | 28.0 | 27.1 | 18.3 | -18.1 | -10.2 |

Note: Import data includes tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce; and Customs and Excise Department, Ministry of Economy and Finance (website)

## តារាង៥៖ ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១៤-២០ (ប៊ីលានរៀល)

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 10543.4 | 11879.9 | 14201.5 | 16582.0 | 19743.1 | 5097.5 | 6357.1 | 6364.5 | 6930.3 | 5544.2 | 5554.9 | 4189.8 |
| ចំណូលចរន្ត | 10359.4 | 11759.0 | 14088.7 | 16481.4 | 19549.0 | 5066.8 | 6322.2 | 6309.2 | 6869.7 | 5524.0 | 5504.1 | 4150.0 |
| ចំណូលពន្ធ | 8995.2 | 10502.4 | 12196.5 | 14314.3 | 17019.2 | 4524.3 | 5663.5 | 5415.1 | 6009.8 | 4697.1 | 5236.7 | 3886.8 |
| ពន្ធក្នុងស្រុក | 7226.5 | 8591.7 | 10185.8 | 12338.7 | 14648.3 | 3904.9 | 4944.9 | 4634.1 | 5215.9 | 4076.5 | 4787.8 | 3393.8 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1822.7 | 1910.7 | 2010.7 | 1875.6 | 2370.9 | 619.4 | 718.6 | 781.0 | 793.9 | 620.6 | 448.9 | 493.0 |
| ចំណូលមិនមែនពន្ធ | 1310.3 | 1256.6 | 1892.2 | 2167.2 | 2520.9 | 542.5 | 658.7 | 894.1 | 859.9 | 826.9 | 267.4 | 263.2 |
| ចំណូលលើទ្រព្យសម្បត្តិ | 88.5 | 77.3 | 116.0 | 127.2 | 197.3 | 177.4 | 34.0 | 30.2 | 22.9 | 289.6 | 36.8 | 31.1 |
| លក់ទំនិញ និងសេវា | 871.2 | 1,047.1 | 1248.3 | 1517.0 | 2075.6 | 330.7 | 531.2 | 798.5 | 750.0 | 500.9 | 211.6 | 190.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 350.5 | 132.2 | 528.0 | 523.1 | 253.9 | 34.5 | 93.5 | 65.5 | 87.1 | 36.4 | 47.5 | 41.5 |
| ចំណូលជាមូលធន | 184.0 | 121.0 | 113.4 | 100.5 | 194.1 | 30.7 | 35.0 | 55.4 | 60.7 | 20.2 | 50.8 | 39.8 |
| ចំណាយសរុប | 13306.5 | 13834.9 | 13775.4 | 17250.9 | 19027.2 | 4150.4 | 4997.6 | 5386.5 | 7676.7 | 5301.8 | 6342.7 | 5603.8 |
| ចំណាយជាមូលធន | 5590.7 | 5290.3 | 3785.3 | 5207.2 | 5730.2 | 1025.0 | 1392.7 | 1358.6 | 3195.4 | 1259.3 | 2289.2 | 1757.1 |
| ចំណាយចរន្ត | 7715.8 | 8544.6 | 9990.1 | 12043.7 | 13297.0 | 3125.4 | 3604.9 | 4027.9 | 4481.3 | 4042.5 | 4053.5 | 3846.7 |
| បៀវត្សរ៍ | 3755.5 | 4271.9 | 5381.7 | 6647.4 | 7558.4 | 1820.2 | 1911.1 | 2102.0 | 1883.3 | 2058.0 | 1934.4 | 2132.8 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1627.0 | 1742.9 | 1774.9 | 2314.8 | 2505.4 | 729.2 | 1061.9 | 855.5 | 1620.3 | 1288.2 | 1435.6 | 701.5 |
| ចំណាយចរន្តផ្សេងទៀត | 2333.4 | 2529.8 | 2833.5 | 5394.3 | 5738.6 | 1305.2 | 1693.8 | 1925.8 | 2598.1 | 1984.4 | 2119.2 | 1713.9 |
| សមតុល្យជាទូទៅ | -2763.1 | -1955.0 | 426.1 | -668.9 | 715.9 | 947.1 | 1359.5 | 978.0 | -746.4 | 242.4 | -787.8 | -1414.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 3972.1 | 3729.4 | 1878.9 | 3358.1 | 716.1 | 652.8 | 895.5 | 608.8 | 1383.3 | 369.5 | 1180.5 | 1415.7 |
| ហិរញ្ញប្បទានក្នុងស្រុក | -1428.7 | -2034.9 | -1858.7 | -2454.1 | 2513.5 | -44.4 | -7.6 | 11.9 | -18.0 | 3.2 | 18.7 | 113.1 |

Source: Ministry of Economy and Finance website

## តារាង៦៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១៤-២០

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.9 | 1.2 | 3.1 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.0 | 3.0 | 2.5 | 2.8 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 4.9 | 4.0 | 5.6 | 3.4 | 2.5 | 2.1 | 1.6 | 2.2 | 2.4 | 3.7 | 4.9 | 4.5 |
| - ដឹកជញ្ជូន | -1.0 | -9.2 | -6.9 | 4.1 | 2.9 | -3.8 | -1.5 | -2.5 | -1.4 | 2.6 | -10.8 | -4.6 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4036.2 | 4060.4 | 4053.7 | 4047.5 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 | 4087.0 | 4094.6 |
| រៀលក្នុង ១ បាតថៃ | 124.9 | 119.4 | 115.5 | 120.0 | 125.9 | 127.4 | 128.9 | 133.7 | 134.9 | 130.7 | 127.5 | 131.0 |
| រៀលក្នុង ១០០ ដុងវៀតណាម | 19.1 | 18.7 | 18.2 | 17.9 | 17.7 | 17.4 | 17.5 | 17.7 | 17.6 | 17.6 | 17.7 | 17.7 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 152.3 | 140.6 | 151.2 | 151.5 | 152.8 | 156.6 | 157.1 | 175.7 | 178.1 | 188.3 | 185.5 | 224.2 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4852.1 | 3771.3 | 3004.0 | 3385.8 | 3808.7 | 3413.9 | 3595.4 | 3499.7 | 3499.5 | 3343.5 | 2393.0 | 2730.6 |
| ថ្លៃសាំង (រៀល/លីត្រ) | 5083.3 | 3951.7 | 3336.8 | 3716.0 | 3982.5 | 3405.7 | 3770.2 | 3629.3 | 3685.9 | 3538.8 | 2483.8 | 3003.7 |

Sources: National Institute of Statistics, National Bank of Cambodia, CDRI

## តារាង៧៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៤-២០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 26699.7 | 26665.5 | 31814.5 | 42575.3 | 55214.3 | 58148.8 | 55238.0 | 58667.0 | 60182.9 | 57001.8 | 63515.6 | 68060.7 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 15859.8 | 22157.6 | 25802.3 | 28743.5 | 33228.9 | 33997.2 | 55274.0 | 34814.3 | 34856.1 | 62221.0 | 60598.8 | 64552.9 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -4359.1 | -6428.8 | -8148.5 | -11066.5 | -14803.7 | -17381.0 | -19828.0 | -21574.8 | -23884.4 | -24650.6 | -24152.1 | -24395.1 |
| ឥណទានដល់វិស័យឯកជន | 36244.6 | 46071.0 | 56458.8 | 66922.6 | 82419.3 | 86575.2 | 111686.0 | 119358.9 | 125629.4 | 131815.3 | 132849.9 | 139899.7 |
| រូបិយវត្ថុទូទៅ | 42559.5 | 48823.1 | 57616.6 | 71318.9 | 88443.2 | 92146.0 | 110512.0 | 116766.5 | 118436.4 | 119222.8 | 124114.4 | 132613.6 |
| រូបិយវត្ថុ | 6308.4 | 6741.4 | 7273.0 | 9428.4 | 10226.8 | 10782.0 | 9883.0 | 11933.4 | 11906.3 | 12880.5 | 12650.4 | - |
| រូបិយវត្ថុផ្សេងៗ | 26699.7 | 42081.7 | 50343.8 | 61890.4 | 78216.4 | 81364.0 | 95196.0 | 98378.3 | 99650.6 | 99700.8 | 103956.6 | - |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ | 29.9 | 14.7 | 18.0 | 23.8 | 24.0 | 24.0 | 22.6 | 21.3 | 20.4 | 29.4 | 12.3 | 13.6 |
| រូបិយវត្ថុ | 29.3 | 6.9 | 7.9 | 29.6 | 8.5 | 8.5 | 12.6 | 18.0 | 32.7 | 19.5 | 28.0 | - |
| រូបិយវត្ថុផ្សេងៗ | 30.0 | 16.1 | 19.6 | 22.9 | 26.4 | 26.4 | 24.1 | 21.7 | 18.8 | 22.5 | 9.2 | - |

Source: National Bank of Cambodia

## តារាង៨៖ ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | | | | | | 2020 | | | |
| | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នករត់ស៊ីក្លូ | 10793 | 11764 | 10567 | 11114 | 12046 | 10997 | 9081 | 10779 | 10775 | -14.1 | -3.0 | -10.6 |
| អ្នកលីសែង | 14942 | 15882 | 17323 | 16560 | 18802 | 18246 | 17856 | 15346 | 19493 | 3.1 | -7.3 | 3.7 |
| អ្នកលក់បន្លែតូចតាច | 17015 | 18912 | 21472 | 19197 | 18651 | 15207 | 20181 | 19479 | 23206 | -6.0 | 1.5 | 24.4 |
| អ្នករើសអេតចាយ | 11591 | 12941 | 12685 | 13123 | 13099 | 14759 | 8322 | 10742 | 11198 | -34.4 | -18.1 | -14.5 |
| អ្នករត់តុភោជនីយដ្ឋាន* | 22901 | 8299 | 8348 | 8564 | 8724 | 8706 | 8420 | 8997 | 8912 | 0.9 | 5.1 | 2.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 17341 | 8209 | 7909 | 9180 | 9376 | 9154 | 8812 | 8712 | 8924 | 11.4 | -5.1 | -4.8 |
| កម្មកររោងចក្រកាត់ដេរ | 14231 | 16073 | 15166 | 16076 | 16578 | 16483 | 13271 | 14211 | 14391 | -12.5 | -11.6 | -13.2 |
| អ្នករត់ម៉ូតូឌុប | 8093 | 14705 | 15104 | 14219 | 14904 | 17748 | 9081 | 15210 | 14427 | -11.9 | 7.0 | -3.2 |
| កម្មករសំណង់គ្មានជំនាញ | 8055 | 19820 | 17987 | 18322 | 18814 | 22916 | 19741 | 17870 | 14947 | 9.7 | -2.5 | -20.6 |
| កម្មករសំណង់មានជំនាញ | 14093 | 26265 | 24743 | 25235 | 27225 | 27164 | 26778 | 31298 | 22069 | 8.2 | 24.0 | -18.9 |

Notes: * Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. November 2015 data are not available. Source: CDRI

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ...**

លំហ សម្រាប់ឲ្យក្រសួងសំខាន់ៗ និងអង្គការក្រៅរដ្ឋាភិបាល ធ្វើការចែករំលែកបទពិសោធន៍ ចំណេះដឹងស៊ីជម្រៅ និងគំនិតផ្សេងៗ ដែលគម្រោងអាចយកទៅសិក្សាពង្រីកបន្ថែម។ អ្នកចូលរួម មានមកពីខាង មជ្ឈមណ្ឌលសាមគ្គីភាព (Solidarity Centre) អង្គការអុកស្វាម (កម្ពុជា) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី និងមជ្ឈមណ្ឌលសិក្សាគោលនយោបាយ។

**នាយកប្រតិបត្តិ CDRI បានថ្លែងសុន្ទរកថាគន្លឹះនៅសន្និសីទជាតិលើកទី១៣ ស្តីពី អភិបាលកិច្ចដីធ្លី និងធនធានធម្មជាតិ។** ព្រឹត្តិការណ៍នេះ បានប្រព្រឹត្តទៅនៅក្រុងភ្នំពេញ នៅថ្ងៃទី២៧ តុលា និងមានអ្នកចូលរួមជាង ១៥០នាក់ មកពីបណ្តាខេត្ត ក្រសួង មន្ទីរសំខាន់ៗ និងរួមមាន អ្នកតំណាងនៃសហគមន៍ប្រជាជនដើម សមាជិកសភា អភិបាលខេត្តនានា និងអ្នកដឹកនាំ (សង្ឃមួយអង្គ) នៃ សមាគមព្រៃឈើផ្អែកលើសហគមន៍ ដែលបានធ្វើការចាប់អារម្មណ៍ខ្លីៗមួយចំនួនផងដែរ។

**ការប្រជុំតាមអនឡាញនៃក្រុមប្រឹក្សាភិបាល CDRI៖** ការប្រជុំនេះបានប្រព្រឹត្តទៅនៅថ្ងៃទី៣ វិច្ឆិកា ហើយសមាជិកក្រុមប្រឹក្សាទាំង ១០នាក់ បានចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា។ នាពេលនោះ ក្រុមប្រឹក្សាបានទទួលស្វាគមន៍សមាជិកក្រុមប្រឹក្សាថ្មីពីរនាក់ គឺលោក Roland Rajah ជាសេដ្ឋវិទូនាំមុខគេ និងនាយកនៃកម្មវិធីសេដ្ឋកិច្ចអន្តរជាតិនៃវិទ្យាស្ថាន Lowy នៃសាកលវិទ្យាល័យជាតិអូស្ត្រាលី (ANU) និងលោក Zhang Bao ជាប្រធានអ្នកយកព័ត៌មាននៃការិយាល័យនៅកម្ពុជា នៃទិនានុប្បវត្តិសេដ្ឋកិច្ច (ប្រទេសចិន) និងអតីតអ្នកស្រាវជ្រាវនៃ វិទ្យាស្ថានអភិវឌ្ឍន៍ពិភពលោក នៃ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍ នៃក្រុមប្រឹក្សារដ្ឋ ប្រទេសចិន។

ក្រុមប្រឹក្សាភិបាល CDRI បានពិនិត្យឡើងវិញ និងពិភាក្សាពីការអភិវឌ្ឍស្ថាប័ន ការស្រាវជ្រាវនិងបោះពុម្ពផ្សាយ និងស្ថានភាពហិរញ្ញវត្ថុរបស់ CDRI និងបានពិនិត្យឡើងវិញ និងផ្តល់មតិលើឯកសារព្រាងដំបូងនៃផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២៦ របស់ CDRI។ សរុបមក CDRI បានជឿនលឿនច្រើនក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រពីខែកក្កដា ២០១៦ ដល់ មិថុនា ២០២១ របស់ខ្លួន ដែលផ្តោតលើការស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មានខាងផ្នែកកសិកម្ម សេដ្ឋកិច្ច អប់រំ បរិស្ថាន អភិបាលកិច្ច និងខាងបញ្ហាពាក់ព័ន្ធច្រើនវិស័យនៃសមភាពយេនឌ័រ ការប្រែប្រួលអាកាសធាតុ ចីរភាព សុខុមាលភាពសង្គម សមធម៌ និងភាពសម្រាប់គ្រប់គ្នា។

**ការប្រជុំស្តាប់យោបល់របស់អ្នកតំណាងអង្គការសង្គមស៊ីវិល។** នៅថ្ងៃទី២៦ វិច្ឆិកា នាយកប្រតិបត្តិ និងនាយកមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចនិងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍របស់ CDRI បានចូលរួមការប្រជុំស្តាប់យោបល់របស់ អនុគណៈកម្មាធិការអង្គការសង្គមស៊ីវិលនៃកម្មវិធីជួយគាំទ្រចម្លើយតបសកម្ម និងចំណាយសម្រាប់កូវីដ១៩ (CARES) ដែលផ្តល់មូលនិធិ (ប្រមាណ ២៥០លានដុល្លារ) ដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងរៀបចំដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អ្នកតំណាងអង្គការសង្គមស៊ីវិល បានលើកសំណួរ និងផ្តល់មតិលើបញ្ហាសំខាន់ៗមួយចំនួន។ ការប្រជុំស្តាប់យោបល់នេះ មានគោលដៅជំរុញឲ្យសង្គមស៊ីវិលចូលពាក់ព័ន្ធ ដើម្បីទទួលបានធាតុចូល សម្រាប់កម្មវិធី CARES ដែលសំដៅជួយគាំទ្រដល់ចម្លើយតបនឹងជំងឺឆ្លងរាលដាលកូវីដ១៩ នៅកម្ពុជា។

## ការស្រាវជ្រាវ

### មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ (CDET)

មជ្ឈមណ្ឌលនេះបានដំណើរការវគ្គទី១ នៃសិក្ខាសាលាតាមអ៊ីនធើណិតមួយខ្សែ ដើម្បីចាប់ផ្តើមគម្រោងស្តីពី *ផលប៉ះពាល់នៃកូវីដ១៩ លើការអភិវឌ្ឍសម្រាប់គ្រប់គ្នា និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ៖ ការវាយតម្លៃលឿន ក្រោយពេលមានជំងឺឆ្លងរាលដាលនៅអនុតំបន់មេគង្គ*។ ព្រឹត្តិការណ៍នេះបាននាំមកជួបមតិគ្នានូវ អ្នកស្រាវជ្រាវ និងអ្នកតំណាងមកពីបណ្តាក្រសួងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល (NGOs) អង្គការសង្គមស៊ីវិល (CSOs)។ មតិយោបល់ផ្សេងៗ ទទួលបានពីព្រឹត្តិការណ៍នេះ ក្រុមស្រាវជ្រាវបានយកមកពិនិត្យ និងដាក់បញ្ចូលក្នុងការរចនារៀបចំការស្រាវជ្រាវ។ វគ្គនេះមានកំណត់ត្រាអាចយកមើលបានក្នុង https://youtu.be/XcZpUd-_xoM។ សកម្មភាពគម្រោងនេះ ចាប់ផ្តើមនៅខែមករា ២០២១។

ក្រុមស្រាវជ្រាវនៃ CDET បន្តធ្វើការប្រមូល និងវិភាគទិន្នន័យសម្រាប់ការស្រាវជ្រាវ ក្នុងគម្រោង *អង្កេតវាយតម្លៃជំនាញផ្នែកឌីជីថល*។ លទ្ធផលរកឃើញដំបូងៗ បានយកទៅលើកបង្ហាញនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT) និងសិក្ខាសាលាតាមអ៊ីនធើណិតស្តីពី *ការទទួលយកបច្ចេកវិទ្យាឌីជីថលនៅតាម សហគ្រាសខ្នាតតូច និងមធ្យម (SMEs) នៅកម្ពុជា* ដែលជាចំណែកមួយនៃ សប្តាហ៍សហគ្រិនភាពសាកល (GEW) ឆ្នាំ២០២០។ ជំងឺឆ្លងរាលដាលកូវីដ១៩ ដែលបានចាប់ផ្តើមនៅថ្ងៃ ២៨ វិច្ឆិកា នៅកម្ពុជា បានបង្កឧបសគ្គស្មុគស្មាញ និងការយឺតយ៉ាវមួយកម្រិត ដល់ការប្រមូលទិន្នន័យសម្រាប់អង្កេតនេះ។

ដំណាក់កាលទី២ នៃគម្រោង *ការចូលរួមចំណែកនៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ដល់កំណើន និងការប្រែក្លាយឧស្សាហកម្មសម្រាប់គ្រប់គ្នា៖ ការវិភាគពីកត្តាសំខាន់ៗក្នុង ៦ប្រទេស* បានចាប់ផ្តើមនៅខែកញ្ញា។ ក្រុមស្រាវជ្រាវ បានចូលរួមក្នុងការពិភាក្សាមួយខ្សែជាមួយ ក្រុមការងារបច្ចេកទេសនៃគម្រោងនេះ ដើម្បីកំណត់សំណួរ និងរបៀបរចនារៀបចំការស្រាវជ្រាវ។

**មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ** (CERI)

នៅត្រីមាសទី៤ ឆ្នាំ២០២០ មជ្ឈមណ្ឌលនេះបានចេញផ្សាយឯកសារបី ស្តីពី *១) ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)៖ ក្តីសង្ឃឹម និងការពិត ២) ការរាំងស្ទះ និងឱកាសល្អក្នុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩ ក្នុងឧត្តមសិក្សានៅកម្ពុជា៖ ការយល់ឃើញរបស់បុគ្គលិកបង្រៀន និង ៣) សាលារៀនជំនាន់ថ្មី៖ ដំណោះស្រាយមួយសម្រាប់ បញ្ហាប្រឈមជាប្រចាំក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពនៅកម្ពុជា។* ឯកសារទាំងនេះចេញផ្សាយក្នុងទម្រង់ជា ឯកសារពិភាក្សា និងអត្ថបទចុះក្នុង ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា (CDR) ហើយការស្រាវជ្រាវទទួលបានមូលនិធិពី ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ (SDC) និងពី ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) តាមរយៈ អង្គការមូលនិធិអាស៊ី (TAF)។ ឯកសារទាំងបីបានបង្ហាញពី បញ្ហាប្រឈម និងកត្តាផ្សេងៗដែលរារាំង ១) ការផ្តល់ប្រកបដោយប្រសិទ្ធភាពនៅកម្ពុជានូវ កម្មវិធីសិក្សា នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ផ្តោតលើការអនុវត្ត ២) ការរៀន និងបង្រៀនកំពុងបន្តទៅមុខនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា នៅពេលកំពុងទប់ទល់នឹងជំងឺឆ្លងរាលដាលកូវីដ១៩ និង ៣) ជំហានសំខាន់ៗគួរអនុវត្ត ដើម្បីកែលំអគុណភាពការអប់រំ និងទស្សនៈនៃការគ្រប់គ្រងផ្អែកលើសាលារៀនក្នុងការសិក្សាអប់រំទូទៅនៅកម្ពុជា។

លើសពីនេះទៀត មានការសិក្សាស្រាវជ្រាវបី ជាប់ទាក់ទងនឹងឧត្តមសិក្សានៅកម្ពុជា ដែលបានចងក្រងឯកសារទស្សនទានរួចហើយនិងកំពុងស្ថិតក្នុងដំណាក់កាលរៀបចំប្រមូលទិន្នន័យ ពោលគឺ *១) ទិដ្ឋភាពសេដ្ឋកិច្ចនៃជម្រើសជំនាញចម្បង ក្នុងការសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា (STEM) ២) ការវាស់វែងកម្រិតអន្តរជាតូបនីយកម្មនៃ ឧត្តមសិក្សានៅកម្ពុជា និង ៣) សហគ្រិនភាពក្នុងឧត្តមសិក្សានៅកម្ពុជា។*

ការសិក្សាមួយមានចំណងជើងថា *ការចាប់អនុវត្តដោយបង្ខំនូវបច្ចេកវិទ្យាអប់រំ ក្នុងអំឡុងពេលមានជំងឺឆ្លងរាលដាលកូវីដ១៩៖ ករណីស្ថាប័នឧត្តមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយ* ដែលសម្រាប់វាស់វែងភាពត្រៀមស្រេចបាច់ផ្នែកបច្ចេកវិទ្យា និងការចាប់អនុវត្តបច្ចេកវិទ្យារៀនសូត្រតាមអនឡាញ ក្នុងឧត្តមសិក្សានៅកម្ពុជា គឺកំពុងស្ថិតក្នុងដំណាក់កាលសរសេររបាយការណ៍។ ការសិក្សានេះរំពឹងថា នឹងជួយរួមចំណែកដល់ការកសាងគោលនយោបាយ និងការពិភាក្សាលើ ការកែសម្រួលក្រោយពេលមានជំងឺឆ្លងរាលដាលកូវីដ១៩ នៅឯ ក្រសួងអប់រំ យុវជន និងកីឡា ហើយនិង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការសិក្សានេះទទួលបានមូលនិធិពី DFAT (តាមរយៈ TAF) ហើយនិងមូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង។

នៅត្រីមាសទី៤ នេះ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ បានដំណើរការវគ្គបណ្តុះបណ្តាលកសាងសមត្ថភាព ៥វគ្គ។ សកម្មភាពបែបនេះ តែងត្រូវបានសំគាល់ថាជា សមាសភាគសំខាន់បំផុតក្នុងដំណើរការទាំងមូលនៃការអនុវត្តគម្រោងស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ដើម្បីជួយឲ្យអ្នកស្ម័គ្រចិត្ត និងអ្នកស្រាវជ្រាវដែលនៅមានបទពិសោធន៍តិច បានកើនចំណេះដឹង និងបទពិសោធន៍ព្រមទាំងមានជំនាញច្រើនមុខ និងទំនុកចិត្ត ដើម្បីធ្វើការខាងស្រាវជ្រាវ។ ម្យ៉ាងទៀត មានការកសាងសមត្ថភាពផ្ទៃក្នុងមួយខ្សែចុងក្រោយផ្តោតលើ ស្ថិតិ និងសូហ្វវែរទំនើបៗ ដូចជា Stata និង RStudio ជាដើម សម្រាប់ការវិភាគទិន្នន័យ និងស្ថិតិ។

នៅថ្ងៃទី១៦ និង ១៧ វិច្ឆិកា ២០២០ អ្នកស្រាវជ្រាវម្នាក់នៃ CERI បានលើកបង្ហាញពី លទ្ធផលរកឃើញដំបូងៗនៃ *ការវាយតម្លៃជំនាញឌីជីថល៖ អង្កេតលើនិស្សិត* និងបានចូលរួមក្នុងការពិភាក្សាក្រុមវាគ្មិនស្តីពី *ការទទួលយកបច្ចេកវិទ្យាឌីជីថលនៅតាម SMEs នៅកម្ពុជា* ដែលដំណើរការរួមគ្នាដោយសមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC) និងបណ្តាញសហគ្រិនភាពសាកល (GEN)។ ម្យ៉ាងទៀត នាយកមជ្ឈមណ្ឌល CERI ក្នុងឋានៈជាតំណាង CDRI បានចូលរួមវិភាគទានដល់ ការកសាងផែនទីបង្ហាញផ្លូវ ការអនុវត្តគោលនយោបាយផ្នែក វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍នៅកម្ពុជាឆ្នាំ២០២០-២០៣០។ ការពិគ្រោះយោបល់គ្នា គឺមានក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (UNESCAP) ទទួលរៀបចំ។

**មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា** (CGIS)

មជ្ឈមណ្ឌលនេះ បានអនុវត្តឡើងវិញនូវ ការសិក្សាផ្នែកជាតិពន្ធុវិទ្យា ដែល CDRI ធ្លាប់បានធ្វើក្នុងឃុំមួយចំនួននៅកម្ពុជា ក្នុងឆ្នាំ២០០៧ ដើម្បីកំណត់ថា តើថ្នាក់ដឹកនាំនៅតាមជនបទកម្ពុជាបានផ្លាស់ប្តូរយ៉ាងណាក្នុង ១២ឆ្នាំកន្លងមក។ ក្រុមស្រាវជ្រាវបានពិនិត្យឡើងវិញលើឯកសារមានស្រាប់ និងបានរៀបចំនីតិវិធីសម្រាប់ធ្វើសម្ភាសន៍ និងបញ្ជីសំណួរសម្រាប់ធ្វើសម្ភាសន៍ដល់កន្លែង។ ការប្រមូលទិន្នន័យក្នុងឃុំមួយបានចប់រួចរាល់ ហើយនៅឃុំពីរទៀតគឺគ្រោងធ្វើនៅខែមករា ២០២១។

មជ្ឈមណ្ឌល ពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា ក៏បានចូលរួមក្នុងគម្រោងស្រាវជ្រាវពីរ ដោយបានរួមសហការជាមួយ Royal Holloway នៃសាកលវិទ្យាល័យឡុងដុន ពោលគឺ គម្រោងទី១ ស្តីពី *ការពិនិត្យតាមកញ្ចក់យេនឌ័រលើភាពធន់នឹងអាកាសធាតុ ឥណទាន និងអាហារូបត្ថម្ភក្នុងចលនាឆ្លងតំបន់នៅកម្ពុជា និងតំណាភាគខាងត្បូង* និងគម្រោងទី២ ស្តីពី *ការរចនារៀបចំឡើងវិញ៖ កិច្ចការពារសង្គម និងផលប៉ះពាល់ផ្នែកយេនឌ័រនៃកូវីដ១៩ នៅប្រទេសកម្ពុជា។* អង្កេតជុំទី១ លើកម្មកររោងចក្រកាត់ដេរ ២០០នាក់ បានចប់សព្វគ្រប់។ គម្រោងមួយទៀតដែលអនុវត្តឡើង ដោយរួមសហការជាមួយ សាកលវិទ្យាល័យ McGill នៅប្រទេសកាណាដា ឈ្មោះ

ថា *ការស្វែងយល់ពី ឧបសគ្គ និងមាគ៌ាការងារសម្រាប់ការចូលរួមរបស់ស្ត្រីក្នុងនយោបាយ* បានអនុវត្តទៅមុខ ហើយគ្រោងចប់រួចរាល់នៅត្រឹមាសទី១ ឆ្នាំ២០២១។

អ្នកស្រាវជ្រាវនៅ CGIS ម្នាក់ក៏បានធ្វើការសិក្សាសាកល្បងដំបូងមួយ ស្ដីពី *តម្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់អ្នកស្រាវជ្រាវជាស្ត្រី នៅវិទ្យាស្ថាន CDRI* សម្រាប់ឆ្លើយនឹងសំណួរចម្បងមួយថា តើវិទ្យាស្ថាន CDRI គួរធ្វើយ៉ាងណា ដើម្បីទាក់ទាញ និងរក្សាទុកអ្នកស្រាវជ្រាវជាស្ត្រី និងជួយគាំទ្រអ្នកទាំងនេះ ក្នុងការស្រាវជ្រាវ និងតួនាទីដឹកនាំ។ ក្រៅពីសកម្មភាពនានាដែលជាប់ទាក់ទងនឹងការស្រាវជ្រាវ មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា បានជ្រើសចូលអ្នកហាត់ការម្នាក់ ដើម្បីអាចមករៀនសូត្រ និងជួយធ្វើការមជ្ឈមណ្ឌលនេះ ហើយកន្លងមក អ្នកហាត់ការរូបនេះ បានចូលរួមធ្វើការនៅក្នុងសកម្មភាពគម្រោងជាច្រើនរបស់មជ្ឈមណ្ឌល។

## មជ្ឈមណ្ឌលធនធានធម្មជាតិនិងបរិស្ថាន (CNRE)

មជ្ឈមណ្ឌលCNREបានអនុវត្តគម្រោងស្រាវជ្រាវមួយដោយរួមសហការជាមួយ បណ្ដាប្រទេសជាដៃគូក្នុងតំបន់មេគង្គ-ឡានឆាង លើប្រធានបទ *ការទូតក្នុងការគ្រប់គ្រងទឹក នៅអាងទន្លេមេគង្គ ដើម្បីឱ្យមានការប្រើប្រាស់អាងទន្លេជារួម និងសម្រេចបានភាពរុងរឿង*។ CNRE ក៏កំពុងដឹកនាំគម្រោងស្រាវជ្រាវមួយទៀតស្ដីពី *ស្ថានភាពសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា* ដែលជាគម្រោងមានច្រើនមជ្ឈមណ្ឌលចូលរួម ក្នុងនេះក៏មាន មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នាផងដែរ។

មជ្ឈមណ្ឌលធនធានធម្មជាតិនិងបរិស្ថាន បានទទួលរៀបចំការបណ្ដុះបណ្ដាលផ្ទៃក្នុងមួយ សម្រាប់អ្នកស្រាវជ្រាវនៅមានបទពិសោធន៍តិច ស្ដីពីការកសាងសំណើស្រាវជ្រាវ ការជ្រើសរើសសំណាក សម្រាប់ការស្រាវជ្រាវបែបបរិមាណវិស័យ ការវិភាគបែបគុណវិស័យដោយប្រើសូវ៉ែរ Nvivo 12 និងការយល់ដឹងជាមូលដ្ឋានពីសូវ៉ែរ STATA 14។ បន្ទាប់ពីបានចងក្រងលទ្ធផលស្រាវជ្រាវឃើញក្នុងគម្រោង *ផលប៉ះពាល់នៃកម្មវិធីពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ* មជ្ឈមណ្ឌលនេះបានដំណើរការសិក្ខាសាលាថ្នាក់ជាតិមួយ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់អ្នកពាក់ព័ន្ធនានា។

នាបច្ចុប្បន្ន មជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន កំពុងរៀបចំសំណើស្រាវជ្រាវផ្សេងៗ ដើម្បីដាក់ជូនទៅ វិទ្យាស្ថានសម្រាប់យុទ្ធសាស្ត្រសកលផ្នែកបរិស្ថាន (IGES) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគំនិតផ្ដួចផ្ដើម ផ្នែកអាកាសធាតុអន្តរជាតិ (IKI)។

## មជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ (CARD)

មានគម្រោង ៦ កំពុងអនុវត្តទៅមុខដោយ CPARD ៖

អត្ថបទសង្ខេបសម្រាប់គម្រោងស្ដីពី *ការវិភាគយេនឌ័រ និងការអភិវឌ្ឍសម្រាប់គ្រប់គ្នា (GIDA)* គឺទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដែលជាអ្នកផ្ដល់មូលនិធិ បានទទួលយកយ៉ាងពេញចិត្ត ហើយរបាយការណ៍សម្រេចនឹងផ្ដល់ជូន USAID នៅចុងឆ្នាំនេះ។

សេចក្ដីព្រាងនៃ ឯកសារពិភាក្សាសម្រាប់គម្រោងផ្ដល់មូលនិធិដោយ ទីភ្នាក់ងារសម្រាប់ សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ស្ដីពី *ការអនុវត្តស្តង់ដាសុវត្ថិភាពក្នុងសាកវប្បកម្មនៅកម្ពុជា៖ ករណីដំណាំបន្លែ* បានចប់សព្វគ្រប់ និងបានធ្វើជូនអ្នកមានជំនាញដូចគ្នា ជួយពិនិត្យ និងផ្ដល់យោបល់រួចរាល់ច្រើនហើយ។

ការប្រមូលទិន្នន័យជាដំបូង និងសិក្ខាសាលាពិគ្រោះយោបល់ បានអនុវត្តរួចហើយសម្រាប់ការសិក្សាទី១ ស្ដីពី *ការដាក់បញ្ចូលម្ចាស់ដីតូចៗ ទៅក្នុងបណ្ដាញពាណិជ្ជកម្មតាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈនឹងឯកជន* នៅក្នុងគម្រោងថ្នាក់តំបន់ ស្ដីពី *បណ្ដាញក្រុមផ្ដល់ទស្សនទានផ្នែកកសិកម្ម និងអភិវឌ្ឍន៍ជនបទសម្រាប់បណ្ដាប្រទេសនៅអនុតំបន់មេគង្គ (NARDT)* ដែលផ្ដល់ថវិកាដោយ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។

ការសរសេររបាយការណ៍ សម្រាប់គម្រោងផ្ដល់មូលនិធិដោយ Sida ស្ដីពី *ការវិភាគខ្សែសង្វាក់តម្លៃផ្លែស្វាយ* ត្រូវពន្យាពេលមួយរយៈ ដោយសារក្រុមស្រាវជ្រាវកំពុងមមាញឹកក្នុងគម្រោង GIDA។ ឯកសារទស្សនទាន សម្រាប់ការសិក្សាមួយផ្ដល់មូលនិធិដោយ Sida *ស្ដីពី ស្ថានភាពបច្ចុប្បន្ននៃឧស្សាហកម្មកែច្នៃកសិផល និងសក្ដានុពលសម្រាប់វិនិយោគទៅអនាគត* កំពុងលូតលាស់ទៅមុខហើយ។

គម្រោងស្រាវជ្រាវថ្នាក់តំបន់ថ្មីមួយកំពុងចាប់ដំណើរការ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃកូវីដ១៩ ទៅលើវិស័យកសិកម្មនៅ កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ។ *ការស្រាវជ្រាវពីគោលនយោបាយសន្តិសុខស្បៀង សមត្ថភាព និងឥទ្ធិពល* ដែលដឹកនាំដោយ មន្ទីរពិសោធន៍នវានុវត្តន៍ផ្ដល់ស្បៀងទៅអនាគត នៃសកលវិទ្យាល័យរដ្ឋមីឈីហ្គាន (Feed the Future Innovation Lab of Michigan State University) គឺជាគម្រោងស្រាវជ្រាវដោយរួមសហការគ្នាមួយរវាងបណ្ដាវិទ្យាស្ថានស្រាវជ្រាវពីគោលនយោបាយស្បៀងអន្តរជាតិ នៅកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ។

# ឯកសារបោះពុម្ពផ្សាយថ្មីៗ










# ឯកសារនឹងបោះពុម្ពផ្សាយ



# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

**គណៈប្រតិភូ CDRI ធ្វើទស្សនកិច្ចនៅ សាលាជំនាន់ថ្មីព្រះស៊ីសុវត្ថិ។** នៅថ្ងៃទី២ តុលា នាយិកាស្រាវជ្រាវនៃវិទ្យាស្ថាន CDRI, នាយកមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍អប់រំ និងអ្នកស្រាវជ្រាវផ្នែកអប់រំមួយចំនួននៃ CDRI បានធ្វើទស្សនកិច្ចនៅ សាលាជំនាន់ថ្មីព្រះស៊ីសុវត្ថិ (NGS) ដើម្បីពិនិត្យស្រាវជ្រាវពីគោលគំនិតនៃការគ្រប់គ្រង និងអភិបាលកិច្ចផ្អែកលើសាលារៀន ដែលបានក្លាយជារបៀបវារៈយ៉ាងសំខាន់មួយសម្រាប់កំណែទម្រង់សាលារៀនរបស់រដ្ឋ និងសម្រាប់ស្វែងយល់ពី គោលនយោបាយ និងនីតិវិធីទទួលឲ្យចូលរៀន លទ្ធផលសិក្សារបស់សិស្ស និងការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូ។ នាពេលនោះ លោកនាយករងសាលា បានរាយការណ៍ជូនគណៈប្រតិភូពីលទ្ធផលនៃ NGS ក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាព កែលំអលទ្ធផលសិក្សារបស់សិស្ស និងអនុវត្តវិធីសាស្ត្របង្រៀន និងរៀនសូត្រប្រកបដោយនវានុវត្តន៍ សម្រាប់ភាពជាពលរដ្ឋសាកលនៅសតវត្សរ៍ទី២១។ បទពិសោធន៍ និងគំនិតផ្សេងៗដែលទទួលបានពីទស្សនកិច្ចនេះ អាចជួយមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍អប់រំ បានច្រើនក្នុងការកសាងសំណើស្រាវជ្រាវឲ្យបានសមស្របតាមផែនការយុទ្ធសាស្ត្ររបស់ ក្រសួងអប់រំ យុវជន និងកីឡា។

**សកម្មភាពតាមដានបន្តជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។** នៅថ្ងៃទី១៣ តុលា នាយកប្រតិបត្តិ នាយកមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ និងមន្ត្រីទំនាក់ទំនងខាងក្រៅនៃ CDRI បានជួបជាមួយ ឯ.ឧ ឈាង វណ្ណារិទ្ធ អគ្គនាយកផ្នែកគោលនយោបាយនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីជាន់ខ្ពស់ និងអ្នកស្រាវជ្រាវមួយចំនួននៃ ក្រសួងហិរញ្ញវត្ថុដើម្បីរួមគ្នា ពិនិត្យស្រាវជ្រាវពីលទ្ធភាពសហការគ្នា ធ្វើការស្រាវជ្រាវពីគោលនយោបាយ សម្រាប់អនុវត្តក្នុងបញ្ហាជាប់ទាក់ទងគ្នានៃទឹក ថាមពល និងសន្តិសុខស្បៀង ធ្វើការវិភាគពីខ្សែសង្វាក់តម្លៃផ្នែកទេសចរណ៍ និងធ្វើការសិក្សាផ្នែកសង្គម។ កិច្ចសហការនេះផ្អែកលើ អនុស្សរណៈយោគយល់មួយរវាង CDRI ក្រសួងហិរញ្ញវត្ថុ នឹងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលបានចុះហត្ថលេខាតាំងពីខែកក្កដា ២០២០។ ឯកសារទស្សនទានមួយចំនួនត្រូវបានកសាងឡើង សម្រាប់ដាក់ជូនក្រសួងហិរញ្ញវត្ថុពិនិត្យដើម្បីយកទៅអនុវត្តរួមគ្នាដោយ អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងហិរញ្ញវត្ថុ និង CDRI ក្នុងប៉ុន្មានខែខាងមុខ។

**ការចុះហត្ថលេខាលើ អនុស្សរណៈយោគយល់រវាងវិទ្យាស្ថាន CDRI នឹងវិទ្យាស្ថានសភាកម្ពុជា។** នៅថ្ងៃទី១៦ តុលា វិទ្យាស្ថាន CDRI និងវិទ្យាស្ថានសភាកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់មួយស្តីពី សហប្រតិបត្តិការ និងភាពជាដៃគូ សម្រាប់ការស្រាវជ្រាវផ្នែកគោលនយោបាយ និងការអភិវឌ្ឍសមត្ថភាពរួមគ្នា។ អនុស្សរណៈនេះ សម្រួលឲ្យវិទ្យាស្ថានស្រាវជ្រាវទាំងពីរអាចធ្វើការរួមគ្នា ក្នុងការស្រាវជ្រាវផ្នែកគោលនយោបាយ ច្បាប់ និងប្រធានបទផ្សេងទៀត និងធ្វើការអភិវឌ្ឍសមត្ថភាពក្នុងផ្នែកមានផលប្រយោជន៍ទៅវិញទៅមក ដូចជា ការផ្លាស់ប្តូរគ្នានូវបទពិសោធន៍ស្រាវជ្រាវ សកម្មភាពស្រាវជ្រាវ និងបោះពុម្ពផ្សាយ ការរៀបចំនិងចូលរួមក្នុងសិក្ខាសាលា សន្និសីទ ការស្តាប់មតិជំនាញការ និងសកម្មភាពជាប់ទាក់ទិនផ្សេងៗ ការផ្លាស់ប្តូរគ្នានូវឯកសារ និងព័ត៌មានផ្នែកសិក្សាអប់រំ និងស្រាវជ្រាវ និងសកម្មភាពផ្នែកសិក្សាអប់រំផ្សេងៗទៀត។

**ការប្រជុំពិគ្រោះយោបល់លើ គម្រោងការរចនារៀបចំឡើងវិញ។** នៅថ្ងៃទី២១ តុលា មជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ចនិងសង្គមសម្រាប់គ្រប់គ្នា បានរៀបចំការប្រជុំពិគ្រោះយោបល់មួយលើគម្រោងការរចនារៀបចំឡើងវិញ (ReFashion)៖ កិច្ចការពារសង្គម និងផលប៉ះពាល់ផ្នែកយេនឌ័រនៃកូវីដ១៩ នៅកម្ពុជា។ គម្រោងរយៈពេល ១៨ខែនេះ ត្រូវអនុវត្តរួមគ្នាដោយ សាកលវិទ្យាល័យនៅអង់គ្លេស និង CDRI។ ការប្រជុំនេះមានគោលដៅផ្តល់ព័ត៌មានស្តីពីគម្រោង ទៅដល់អ្នកពាក់ព័ន្ធសំខាន់ៗ និងផ្តល់

*តទៅទំព័រ ២៤*

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី២៤ លេខ៤ ខែធ្នូ ឆ្នាំ២០២០

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ សម្រាប់ការពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់នូវការវាយតម្លៃឯករាជ្យពីដំណើរការសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក្តី។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ពផ្សាយ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ពផ្សាយ ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ +៨៥៥២៣៨៨១៧០១/៨៨១៩១៦/៨៨៣៦០៣ +៨៥៥២៣៨៨០៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសម្រួលៈ អ៊ុំ ចាន់ថា
កែសម្រួលផលិតកម្មៈ ម៉ែន ច័ន្ទធីតា
សហគ្រាសបោះពុម្ព Go Invent Media (GIM), រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០២០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈវេបសាយ www.cdri.org.kh